ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2018, 09:00
CMS/CFO: Ly Bunloung



[00166785]

**ពោធិ៍ចិនតុងបានបិទទ្វារចរាចរណ៍ពាណិជ្ជកម្ម៖ យន្តហោះដឹកជម្លៀសរបស់សហរដ្ឋអាមេរិកនៅបន្ត**

ហុងកុង ទីភ្នាក់ងារសារព័ត៌មានអាអេហ្វប៉េ (AFP) ជាភាសាអង់គ្លេសម៉ោង ១០៥៣ ម៉ោងសកល (GMT) ៥ មីនា ១៩៧៥ បាងកង (BK)

[អត្ថបទដកស្រង់] ភ្នំពេញ ៥ មីនា (AFP)--ភ្នំពេញ-ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុងបានបិទទ្វារចរាចរណ៍ពាណិជ្ជកម្មនាថ្ងៃនេះ ដោយរងការវាយប្រហារដោយគ្រាប់ផ្លោងរបស់ខ្មែរក្រហម ប៉ុន្តែយន្តហោះដឹកជម្លៀសចេញ និងជើងយន្តហោះយោធារបស់អាមេរិកនៅបន្តដំណើរការធម្មតា ។

ព្រលានយន្តហោះពោធិ៍ចិនតុងបានបិទចរាចរណ៍ក្នុងប្រទេស និងក្រៅប្រទេសបន្ទាប់ពីបានទទួលរងនូវការវាយប្រហារដោយគ្រាប់រ៉ុក្កែតចំនួនប្រហែល៤០គ្រាប់ មកលើទីតាំងព្រលាន និងតំបន់ជុំវិញបរិវេណនោះ ។ ប្រភពនានាមកពីព្រលាននេះបាននិយាយថា ជើងយន្តហោះទាំងអស់ចេញពីរដ្ឋធានានេះត្រូវបានលុបចោលទាំងអស់រហូតមកដល់ថ្ងៃសុក្រ ។ ការបិទព្រលានយន្តហោះនេះមានន័យថា ភ្នំពេញដូចជាត្រូវបានកាត់ផ្តាច់ទាំងស្រុងចេញពីទំនាក់ទំនងជាមួយនឹងទីតាំងដទៃទៀតនៅក្នុងទូទាំងប្រទេស ដោយសារផ្លូវថ្នល់ឆ្ពោះមកកាន់ភ្នំពេញ និងទន្លេមេគង្គបានកាន់កាប់ដោយខ្មែរក្រហម ។

របាយការណ៍នានាជាបឋមបានរាយការណ៍ថា មិនមានរងការគ្រោះថ្នាក់ពីការវាយប្រហារដោយគ្រាប់ផ្លោងនោះទេ ។ គ្រាប់ផ្លោងនោះគឺគ្រាប់រ៉ុក្កែតទំហំ ១០៧ មីលីម៉ែត្រ និងគ្រាប់ផ្លោងទំហំ ១០៥ មីលីម៉ែត្រ ដែលមានលក្ខណៈសុក្រឹតជាងគ្រាប់រ៉ុក្កែត ។ ក៏ប៉ុន្តែវាបានធ្វើឲ្យមានការស្លន់ស្លោនៅក្នុងចំណោម

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

បុគ្គលិកស៊ីវិលនៅឯព្រលានយន្តហោះ ហើយប្រភពគួរឲ្យទុកចិត្តបាន បានរាយការណ៍ថា អ្នកដែលទទួលខុសត្រូវខាងចាក់ប្រេងយន្តហោះបានបដិសេធមិនទៅធ្វើកិច្ចការរបស់ខ្លួន ។

ទីតាំងយោធារបស់ព្រលានយន្តហោះពោធិ៍ចិនតុង ស្ថិតនៅផុតពីរយៈចម្ងាយកាណុងរបស់ខ្មែរក្រហម ។ យន្តហោះទម្លាក់-ប្រយុទ្ធ បានបន្តហោះឡើងនិងចុះចត ខណៈយន្តហោះ DC-8 និង C-130 ដែលនាំភស្តុភាមកកាន់រដ្ឋធានីដែលរងការខ្ទេចខ្ទាំនេះ នៅតែបន្តបេសកកម្មរបស់ខ្លួន ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166786]

**ឡុង បូរ៉េតបញ្ជាក់ថា លន់ នល់ នឹងចុះពីតំណែង ដើម្បីសម្រេចឲ្យបានសន្តិភាព**

ហុងកុង ទីភ្នាក់ការងារសារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោង ១៣២៥ ម៉ោងសកល GMT ៥ មីនា ១៩៧៥ បាងកក (BK)

[អត្ថបទ] ភ្នំពេញ ៥ មីនា [AFP] -- នាយករដ្ឋមន្ត្រីកម្ពុជា ឡុង បូរ៉េត បានបញ្ជាក់នៅទីនេះ ថ្ងៃនេះថា ប្រធានាធិបតីលន់ នល់ បានត្រៀមខ្លួននឹងចុះចេញពីតំណែង ប្រសិនបើការធ្វើដូច្នេះ នឹងនាំឲ្យមានសន្តិភាព ។

[00166787]

ក្រោយពីបានសាកសួរនៅឯសន្និសីទសារព័ត៌មានមួយ អំពីរបាយការណ៍ថ្មីៗ ដែលថាលន់ នល់ អាចនឹងលាលែងពីតំណែង ដើម្បីបើកផ្លូវឲ្យមានការចរចា លោកឡុង បូរ៉េត បានមានប្រសាសន៍ថា លោកប្រធានាធិបតី "បានត្រៀមខ្លួនជាស្រេចនឹងធ្វើពលិកម្មរាល់អ្វីៗទាំងអស់ ដើម្បីជួយឲ្យប្រទេសជាតិរបស់លោកបានចាប់ផ្តើមងាកមកដើរលើផ្លូវទៅកាន់សន្តិភាពវិញ" ។

លោកនាយករដ្ឋមន្ត្រីបានបន្តថា ៖ "យើងទាំងអស់គ្នាបានត្រៀមខ្លួនជាស្រេច ដើម្បីចុះពីតំណែង ។ ខ្ញុំអាចចុះពីតំណែងស្អែកនេះ ។ ប៉ុន្តែយើងនឹងមិនធ្វើដូច្នេះទេ ដរាបណាយើងមិនទាន់មានការបញ្ជាក់ច្បាស់ថា ការចុះចេញពីតំណែងនឹងនាំមកនូវសន្តិភាព ។" លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា រដ្ឋាភិបាលបានធ្វើអ្វីៗទាំងអស់ក្នុងការព្យាយាមចាប់ផ្តើមឲ្យមានការចរចាជាមួយពួកកុម្មុយនីស្ត ប៉ុន្តែខ្មែរក្រហមទាំង

នោះ “នៅតែចចេសចង់បានដំណោះស្រាយតាមផ្លូវយោធា ។” គាត់បន្តថា ៖ “យើងនឹងមិនទម្លាក់អាវុធចុះចូលឡើយ ។”

ស្តីអំពីសំណើរបស់កម្ពុជាសុំជំនួយយោធារបស់សហរដ្ឋអាមេរិកបន្ថែម លោកឡុង បូរ៉េត មានប្រសាសន៍ថា ការបដិសេធរបស់សភាអាមេរិក នឹងបណ្តាលឲ្យមានផលវិបាក “យ៉ាងវិនាសកម្មធ្ងន់ធ្ងរ” ហើយនឹងបណ្តាលឲ្យមានការបង្ហូរឈាម ។

[00166788]

វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា (NUFC) មើលឃើញនូវទីបញ្ចប់ក្នុងពេលឆាប់ៗនេះរបស់មេដឹកនាំក្រុងភ្នំពេញ

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយចំពោះកម្ពុជាម៉ោង ០៤០០ ម៉ោងសកល GMT ៥ មីនា ១៩៧៥ បាងកក (BK)

[អត្ថបទ] រដ្ឋការហ្វូត-ឃីស៊ីងជ័រ មិនមានវិធីណាអាចជួយសង្គ្រោះជនក្បត់ជាតិដែលជាអាយ៉ងរបស់ខ្លួននៅទីក្រុងភ្នំពេញបានឡើយ ។ នៅក្នុងជំហរបច្ចុប្បន្ន ពួកអាយ៉ងទីក្រុងភ្នំពេញប្រៀបដូចជាមនុស្សកំពុងលង់ទឹក ហើយមូលហេតុតែមួយគត់ដែលមនុស្សនោះអាចមានដង្ហើមរស់បានកន្លងមក គឺដោយសារមានជំនួយរបស់ពួកចក្រពត្តិអាមេរិក ។ ចាប់តាំងពីដើមឆ្នាំមក កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង (CPNLAF) បានចាប់ផ្តើមវាយលុកធ្វើឲ្យជនក្បត់ជាតិទាំង៧រូប និងរបបរបស់ខ្លួន

ទទួលនូវការបរាជ័យទាំងស្រុង ហើយមធ្យោបាយក្នុងការបន្តរស់របស់ពួកវា ឥឡូវនេះត្រូវបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ។ ដោយមូលហេតុនេះហើយ រដ្ឋការហ្វត-ឃីស៊ីងជ័រ កំពុងតែមានការខ្វាយខ្វល់យ៉ាងខ្លាំង ហើយកំពុងតែដើរគោះគ្រប់ទ្វារនៅក្នុងទីក្រុងវ៉ាស៊ីនតោន ដើម្បីស្វែងរកចម្លើយ ។ បណ្ដាអ្នកសង្កេតការណ៍នយោបាយនៅសហរដ្ឋអាមេរិកបាននិយាយថា ពួកគេមិនដែលឃើញនៅក្នុងរដ្ឋការនេះមានការភ័យស្លន់ស្លោយ៉ាងដូច្នេះទេ ដែលឥឡូវនេះរដ្ឋការភ័យខ្លាចថា នឹងមានការបរាជ័យឆាប់ៗនៃពួកអាយ៉ងភ្នំពេញរបស់ខ្លួន ។ នេះជាមូលហេតុដែលរដ្ឋការបានព្យាយាមយ៉ាងខ្លាំង ដើម្បីសុំជំនួយយោធា ដើម្បីជួយអាយ៉ងរបស់ខ្លួននៅភ្នំពេញ ។

យោងទៅតាមមតិអន្តរជាតិ រួមទាំងមតិសាធារណជនសហរដ្ឋអាមេរិកផង រដ្ឋការហ្វត-ឃីស៊ីងជ័រ នឹងមិនអាចជួយសង្គ្រោះអាយ៉ងក្បត់ជាតិ លន់ នល់ ដែលមានសមាជិក ៧រូបនោះបានឡើយ ទោះជារដ្ឋការនេះប្រឹងប្រែងយ៉ាងណាក៏ដោយ ។ ពួកអាហ្វត និងឃីស៊ីងជ័រ បានដឹងខ្លួនតាមរបៀបណាមួយហើយថា ពួកអាលន់ នល់ និងកូនចៅរបស់ខ្លួនឥឡូវនេះក្លាយទៅដូចជាសាកសពតែប៉ុណ្ណោះ ហើយមិនមាននរណាមួយអាចជប់ឲ្យពួកអាយ៉ងនេះរស់ឡើងវិញបានទេ ទាំងខាងវិស័យនយោបាយ ខាងយោធា ឬខាងសេដ្ឋកិច្ច ។

ដោយបានលើកទឹកចិត្តពីការទទួលបាននូវជ័យជម្នះកាលពីដើមរដូវប្រាំងនេះ ប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាទូទាំងប្រទេស បានឆ្លើយតបទៅនឹងការអំពាវនាវ២៦កុម្ភៈរបស់មហាសន្និបាតជាតិលើកទី២ ហើយបានប្ដេជ្ញាចិត្តបើកការវាយលុកកាន់តែខ្លាំងមួយកម្រិតទៀត ដោយមិនដកថយ ដោយមិនសម្របសម្រួល និងដោយមិនចរចា រហូតទទួលបាននូវជ័យជម្នះពេញលេញ និងរំដោះបានទាំងស្រុងប្រទេសកម្ពុជា ។ ទន្លេមេគង្គ បានបិទទាំងស្រុង ហើយព្រលានយន្តហោះពោធិ៍

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ចិនតុង ដែលជាផ្លូវភស្តុភាចុងក្រោយរបស់ខ្មាំង នឹងត្រូវកម្ទេចទាំងស្រុង ។ យើងច្បាស់ជានឹងឈ្នះ! ខ្មាំងប្រាកដជានឹងត្រូវចាញ់ទាំងស្រុង!

[00166791]

IV. ៧ មីនា ១៩៧៥ H ២ កម្ពុជា

រដ្ឋមន្ត្រីក្រសួងព័ត៌មានថ្កោលទោសគ្រាប់ផ្លោងរបស់កុម្មុយនីស្ត

ភ្នំពេញ សេវាក្នុងស្រុក ជាភាសាខ្មែរ ម៉ោង 0000 ម៉ោងសកល GMT ៧ មីនា ១៩៧៥ បាងកក (BK)

[នេះច្បាស់ជាអត្ថបទនៃសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន ស្តីអំពីការវាយប្រហារគ្រាប់រ៉ុក្កែតរបស់ខ្មែរក្រហមមកលើទីក្រុងភ្នំពេញ ៖ កាលបរិច្ឆេទមិនមាន-- អានដោយអ្នកផ្សាយព័ត៌មាន]

[អត្ថបទ] រដ្ឋមន្ត្រីក្រសួងព័ត៌មានថ្កោលទោសការវាយប្រហាររបស់ពួកកុម្មុយនីស្តប្រល័យពូជសាសន៍ដោយគ្រាប់រ៉ុក្កែតចិនទំហំ ១០៧ មីលីម៉ែត្រ ដែលបានវាយប្រហារមកលើផ្នែកផ្សេងៗនៃទីក្រុងភ្នំពេញ តាំងពីថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៥ ។ ការបាញ់គ្រាប់រ៉ុក្កែតទាំងនេះបានបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជនស៊ីវិលជាច្រើន ។ ជាការចាំបាច់សូមបញ្ជាក់ថា ការបាញ់គ្រាប់រ៉ុក្កែតដោយគ្មានហេតុផលត្រឹមត្រូវទាំងនេះមកលើទីក្រុង ដែលមានប្រជាជនយ៉ាងច្រើនកកកុញ កំណត់បានជាអំពើគិតទុកជាមុន ដែលមានគោលបំណងតែមួយគត់ គឺបង្កនូវអំពើភេរវកម្ម ។

គ្រាប់ខ្លះនៃបណ្តាគ្រាប់ផ្លោងរបស់សត្រូវបានបាញ់ធ្លាក់ចូលទីក្រុងក្នុងពេលថ្ងៃ បានធ្លាក់ចំផ្លូវនានាដែលមានមនុស្សច្រើនកកកុញនៅក្នុងទីក្រុង ប៉ុន្តែមិនមានគ្រាប់ណាបានធ្លាក់ចំគោលដៅយោធាឡើយ ។

រដ្ឋមន្ត្រីក្រសួងព័ត៌មានបានអំពាវនាវដល់មតិអន្តរជាតិ ឲ្យថ្កោលទោសនូវការបាញ់ផ្លោងអាវកម្មទាំងនេះ ហើយឲ្យប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីជួយបញ្ចប់ភ្លាមៗនូវអំពើទាំងនេះ ។ ដើម្បីសម្តែងនូវការស្អប់ខ្ពើមរបស់ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ និងរដ្ឋាភិបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មានអំពាវនាវដល់រដ្ឋាភិបាល និងរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត និងបណ្តាអង្គការបរទេសដែលស្រឡាញ់សន្តិភាពទាំងឡាយ ឲ្យជួយបញ្ចប់ភ្លាមៗនូវការកាប់សម្លាប់របស់ពួកកុម្មុយនីស្តប្រល័យពូជសាសន៍មកលើជនស៊ីវិលដែលគ្មានកំហុស ។

វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា (NUFC) គូសបញ្ជាក់នូវការអំពាវនាវរបស់មហាសន្និបាតនាថ្ងៃទី២៦ ខែកុម្ភៈ

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរ ផ្សាយចំពោះកម្ពុជាម៉ោង ០៤០០ ម៉ោងសកល GMT ៣មីនា ១៩៧៥ បាងកក (BK)

[អត្ថបទ] នៅថ្ងៃទី២៤ និង២៥ ខែកុម្ភៈ មហាសន្និបាតជាតិដ៏អស្ចារ្យមកពីគ្រប់ជាន់ថ្នាក់នៃបណ្តាអង្គការ និងតំណាងរណសិរ្សរួបរួមជាតិកម្ពុជា នៃបណ្តាអង្គការមហាជនផ្សេងៗ ព្រមទាំងអង្គភាពទាំងបីនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានបើកធ្វើពិធីជាលើកទី២របស់ខ្លួន នៅក្នុងតំបន់រំដោះនៃកម្ពុជា ។ នៅថ្ងៃទី២៦ ខែកុម្ភៈ មហាសន្និបាតបានចេញសេចក្តីថ្លែងការណ៍សំខាន់មួយ បញ្ជាក់ជាចម្បងអំពីបញ្ហាបន្ទាន់នាពេលបច្ចុប្បន្ន ទាក់ទងទៅនឹងជោគវាសនានៃជនក្បត់ជាតិធំៗទាំង៧នៃទីក្រុង

ភ្នំពេញ លន់ នល់ សេរីមៈតៈ ស៊ឺន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ។ ជនក្បត់ជាតិទាំង៧រូបនេះ គឺជាមេចូលដៃជាមួយបរទេសឈ្លានពានប្រឆាំងនឹងជាតិសាសន៍ឯង និងជាមេធ្វើរដ្ឋប្រហារដែលបានផ្តួលរំលំកម្ពុជាអព្យាក្រឹត សន្តិភាព និងឯករាជ្យ ហើយបានស្នើឲ្យចក្រពត្តិអាមេរិកឈ្លានពានកម្ពុជា ទម្លាក់គ្រាប់មកលើប្រទេសយើង និងបង្កវិនាសកម្មដែលមិនធ្លាប់មានពីមុនមក ។

ប្រជាជនកម្ពុជា រណសិរ្សកងកម្លាំងរំដោះជាតិប្រជាជនកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជារបស់យើង មិនអាចអត់ឱនបានចំពោះជនក្បត់ជាតិទាំងនេះ ។ យើងត្រូវតែលុបបំបាត់ពួកវា និងផលលំបាកនៃឧក្រិដ្ឋកម្មយ៉ាងមហាឃោរឃៅហ្វាស៊ីសប្រឆាំងជាតិឯងរបស់ពួកវា ។ ចំពោះជនរួមជាតិរបស់យើងនៅទីក្រុងភ្នំពេញ និងតំបន់នានាក្រោមការគ្រប់គ្រងរបស់ខ្មាំងជាបណ្តោះអាសន្ន រួមមានទាំងអ្នករដ្ឋការ ទាហាន ជនស៊ីវិល អ្នកនយោបាយ និងឥស្សរជនគ្រប់ប្រភេទ និងគ្រប់លំដាប់ថ្នាក់ មហាសន្និបាតជាតិដ៏អស្ចារ្យបានប្រកាសយ៉ាងឱឡារិកថា ពួកគេមានសេរីភាពយ៉ាងពេញលេញនៅក្នុងការចុះចូលជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជា ដរាបណាពួកគេបញ្ចប់សហការជាមួយជនមហាក្បត់ទាំង៧រូបនោះ ។

អាស្រ័យហេតុនេះបុគ្គលិករដ្ឋាភិបាល អ្នកនយោបាយ ឥស្សរជន ជាមិត្តដែលបានធ្វើការនៅគ្រប់ទីភ្នាក់ងារនៃរបបក្បត់ជាតិ បងប្អូនជានាយទាហាន ពលទាហាន នគរបាល សមាជិកអង្គភាពស្វ័យការពារ និងជនរួមជាតិជាទីស្នេហាផ្សេងៗទៀតទាំងអស់នៅទីក្រុងភ្នំពេញ ព្រមទាំងនៅទីរួមខេត្តនានា ក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង គួរតែដឹងថា នាពេលនេះគឺជាពេលដែលត្រូវសម្រេចចិត្ត ។ លោកអ្នកត្រូវតែលះបង់ចោលនូវជនមហាក្បត់ទាំង៧រូបនៅទីក្រុងភ្នំពេញ ដែលកំពុងតែឈឺចាប់ត្រដររកខ្យល់មុនពេលដួលរលំក្នុងពេលឆាប់ៗនេះរបស់ពួកគេ ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ដូចលោកអ្នកដឹងហើយ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់ពួកយើង បានរំដោះរួចហើយ និងកាន់កាប់យ៉ាងរឹងមាំនៅតាមទន្លេមេគង្គ ។ ជនក្បត់ជាតិទាំង៧រូបនេះនឹងស្លាប់ក្នុងពេលឆាប់ៗនេះ ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនរបស់យើងទូទាំងប្រទេស នឹងបើកការវាយលុកផ្តួលរំលំពួកវា និងរបបរបស់ពួកវាទាំងនៅទីក្រុងភ្នំពេញ និងបណ្តាទីរួមខេត្តដែលស្ថិតនៅក្រោមការក្តោបក្តាប់ជាបណ្តោះអាសន្នរបស់ពួកវា ។

[00166792]

ជាមួយគ្នានេះ យើងសូមធ្វើការអំពាវនាវដូចខាងក្រោមដល់បណ្ដាព្រះសង្ឃ និងជនរួមជាតិទាំងអស់នៅទីក្រុងភ្នំពេញ និងទីក្រុងនានាដែលខ្មាំងកំពុងកាន់កាប់ជាបណ្ដោះអាសន្ន ៖

១. លោកអ្នកត្រូវតែឆ្លើយតបទៅនឹងសេចក្ដីប្រកាសរបស់មហាសន្និបាតលើកទី២ ដែលបានអំពាវនាវដល់ព្រះសង្ឃ ឧបាសក កម្មករ គ្រូបង្រៀន ឲ្យងើបឈរឡើងរួបរួមគ្នា និងចាត់វិធានការតស៊ូគ្រប់ទម្រង់ដើម្បីវាយប្រហារទៅលើជនក្បត់ជាតិទាំង៧រូបចេញមកពីខាងក្នុងវិញ តាមរយៈការធ្វើការប្រជុំគ្នា ធ្វើបាតុកម្ម ធ្វើកូដកម្ម ហើយតវ៉ាទៅនឹងការកែនទាហាន និងការបង្អត់អាហារ វាយឆ្មក់ទៅលើឃ្លាំងសម្ភារនិងស្រូវអង្ករ វាយយកអាវុធខ្មាំង ដើម្បីវាយទៅលើខ្មាំង និងកម្ទេចចោលសាលាខេត្ត សាលាក្រុង ស្ថានីយវិទ្យុ ស្ថានីយនគរបាល ស្ថានីយអាវុធហត្ថ ជំរំទាហាន ទីបញ្ជាការយោធា ព្រមទាំងរចនាសម្ព័ន្ធនយោបាយយោធា និងសេដ្ឋកិច្ចផ្សេងៗទៀត ។ បងប្អូនយុវជន សិស្សសាលា និស្សិត គ្រូបង្រៀន និងបងប្អូនផ្សេងទៀតនៅក្នុងខេត្តបាត់ដំបង ក្រុងព្រះសីហនុ និងភ្នំពេញបានងើបឡើងបះបោរប្រឆាំងទៅនឹងបណ្ដាជនក្បត់តាំងពីថ្ងៃ២១ ខែកុម្ភៈ សូមបន្តក្រោកឈរឡើង ។ ចំណែកឯបងប្អូននៅទីរួមខេត្តផ្សេងៗទៀត ក៏សូមក្រោកឈរឡើងនិងបះបោរ ។

២. បងប្អូនាយទាហាន ទាហាន នគរបាល សមាជិកស្វ័យការពារ បុគ្គលិករដ្ឋាភិបាល អ្នកនយោបាយ និងឥស្សរជនគ្រប់ផ្នែក សូមចូលរួមនៅក្នុងសកម្មភាពរបស់អ្នករស់នៅភ្នំពេញ និងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់ខ្មាំង ងើបឡើងប្រឆាំងនឹងមេក្បត់ជាតិតាមមធ្យោបាយដែលអាចធ្វើទៅបាន បំផ្លាញរចនាសម្ព័ន្ធរដ្ឋបាលក្បត់ជាតិ ទីតាំងយោធា ស្ថានីយនគរបាល ឃ្លាំងអាវុធ ឃ្លាំងភស្តុភា ឃ្លាំងសាំង ហើយតម្រង់ចុងអាវុធរបស់លោកអ្នកទៅកាន់ពួកវា ដូច្នេះលោកអ្នក

បានចូលរួមវិភាគទានដោយខ្លួនឯងផ្ទាល់ ចំពោះការរំដោះជាតិ និងប្រជាជនរបស់យើង ។ បងប្អូនដែលកំពុងប្រយុទ្ធនៅបណ្តាសមរភូមិផ្សេងៗ សូមឈប់ប្រយុទ្ធជាមួយនឹងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ។ បងប្អូនគួរទម្លាក់អាវុធរបស់ខ្លួន ហើយចូលរួមជាមួយនឹងកងកម្លាំងរបស់យើង ។ បងប្អូននឹងទទួលបាននូវរង្វាន់ និងការគាំទ្រយ៉ាងកក់ក្តៅនិងសមស្របពីសំណាក់ប្រជាជន អង្គការចាត់តាំងរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ។

៣. ប្រសិនចាំបាច់ បងប្អូនសូមអញ្ជើញចុះចូលជាបន្ទាន់ជាមួយនឹងតំបន់រំដោះ ។ បងប្អូននឹងទទួលបានការស្វាគមន៍ និងការគាំទ្រយ៉ាងកក់ក្តៅពីអង្គការចាត់តាំងរបស់រណសិរ្សរួបរួមជាតិកម្ពុជារបស់យើងនៅគ្រប់ទីកន្លែង ។ បងប្អូនប្រជាជនបុគ្គលិករដ្ឋាភិបាល ទាហាន និងស៊ីវិល មិនគួរព្រួយបារម្ភចំពោះជីវភាពនៅក្នុងតំបន់រំដោះទេ ។ តំបន់រំដោះរបស់យើងមិនប្រើក្រដាសប្រាក់របស់ពួកអាយ៉ងក្បត់ជាតិភ្នំពេញទេ ។ សូមចុះចូលមកតំបន់រំដោះ ហើយបងប្អូននឹងទទួលបាននូវការធានាជីវភាព ។

វិចារណកថារណសិរ្សរួបរួមជាតិកម្ពុជា អបអរសាទរសេចក្តីសម្រេចនានារបស់មហាសន្និបាតជាតិលើកទី២ សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរ ផ្សាយមកកម្ពុជាម៉ោង ០៤០០ ម៉ោងសកល GMT ថ្ងៃទី៤ មីនា ឆ្នាំ១៩៧៥ បាងកក (BK) [វិចារណកថា ៖ "មតិជាតិ និងអន្តរជាតិ គាំទ្រយ៉ាងកក់ក្តៅនូវសេចក្តីប្រកាសថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ នៃមហាសន្និបាតជាតិលើកទី២ របស់កម្ពុជា"]

[អត្ថបទ] សេចក្តីប្រកាសនាថ្ងៃ២៦ កុម្ភៈ ឆ្នាំ១៩៧៥ របស់មហាសន្និបាតជាតិនៃគ្រប់ស្រទាប់វណ្ណៈរបស់តំណាងអង្គការចាត់តាំងរណសិរ្សរួបរួមជាតិកម្ពុជា តំណាងអង្គការមហាជនទាំងអស់ តំណាងនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាទាំងបី ដែលបានប្រព្រឹត្តទៅជាលើកទី២ នៅក្នុងតំបន់រំដោះនៃកម្ពុជា បានទទួលនូវការអបអរសាទរយ៉ាងខ្លាំងទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ។ ប្រជាជន

របស់យើងនៅក្នុងតំបន់រំដោះ ក៏ដូចជានៅក្នុងតំបន់ដែលកាន់កាប់ជាបណ្ដោះអាសន្នរបស់ខ្មាំង មានសេចក្ដីរីករាយក្រៃលែង ហើយគាំទ្រអស់ពីចិត្តពីថ្លើម ហើយបងប្អូនជាមិត្តភក្ដិជិតក្ដី ឆ្ងាយក្ដី ទូទាំងពិភពលោកបានធ្វើការចាប់អារម្មណ៍ខ្ពស់ និងគាំទ្រដល់សេចក្ដីសម្រេចជាប្រវត្តិសាស្ត្រនៃមហាសន្និបាតជាតិលើកទី២ ដែលតំណាងឲ្យមនសិការជាតិ និងប្រជាជនកម្ពុជាទាំងមូល រណសិរ្សរួបរួមជាតិកម្ពុជា រដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ។ មតិជាតិនិងអន្តរជាតិបានធ្វើការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបញ្ហាទាំងអស់ដែលបានលើកឡើងនៅក្នុងមហាសន្និបាតជាតិ [អត្ថបទអាចអានបាន] ស្ដីអំពីជនក្បត់ទាំង៧ រូប លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្ដែន ហ្វេណង់ដេ ។ ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា តាំងពីមុនមកដល់ពេលនេះមិនដែលបានធ្វើការប្ដេជ្ញាចិត្តច្បាស់ដូចពេលនេះទេ ។

[00166793]

នៅក្រោមស្ថានភាពដែលអំណោយផលបំផុតនៃបដិវត្តន៍កម្ពុជា ដែលបានឈានមកដល់ដំណាក់កាលចុងក្រោយនៃជ័យជម្នះរបស់ខ្លួន ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា *រាជ*រដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានសម្រេចចិត្តអភ័យទោសទៅដល់បុគ្គលិករដ្ឋាភិបាល ដែលជាបងប្អូនមានឋានៈទាបខ្ពស់នៅក្នុងចំណោមសេវាផ្សេងៗ ផ្នែកផ្សេងៗនៃនាយទាហាន ពលទាហាន អ្នកនយោបាយ ឥស្សរជននានា សមាជិកថ្នាក់ក្រោម ឬថ្នាក់លើទាំងអស់នៃទីភ្នាក់ងារទាំងអស់របបរបស់ពួកក្បត់ជាតិ ។ មានតែមេក្បត់ជាតិទាំង៧រូបតែប៉ុណ្ណោះ ដែលត្រូវទទួលទណ្ឌកម្មរបស់ប្រជាជន និងប្រជាជាតិកម្ពុជារបស់យើង រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរមហាហ្វាស៊ីស និងប្រឆាំងជាតិឯងរបស់ពួកវា ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ក្រៅអំពីជនក្បត់ជាតិស្អុយរលួយទាំង៧រូបនេះ បណ្តាជនរួមជាតិជាបងប្អូនទាំងអស់នៅភ្នំពេញនិងតំបន់ដទៃទៀតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង អាចចុះចូលជាមួយជួររណសិរ្សរំដោះជាតិកម្ពុជា ប្រជាជាតិ និងប្រជាជនកម្ពុជា ។ សេចក្តីសម្រេចរបស់មហាសន្និបាតជាតិនេះ គឺមានអត្ថន័យជាប្រវត្តិសាស្រ្ត ។ មហាជន មន្រ្តីរដ្ឋការថ្នាក់ទាប និងថ្នាក់ខ្ពស់ នាយទាហាន និងពលទាហាន អ្នកនយោបាយឥស្សរជនគ្រប់លំដាប់ថ្នាក់នៅភ្នំពេញ និងតំបន់ដទៃទៀតក្រោមការក្តោបក្តាប់បណ្តោះអាសន្នរបស់ខ្មាំងមានសេចក្តីរីករាយឥតឧបមា ហើយបានប្តេជ្ញាចិត្តស្វែងរកគ្រប់មធ្យោបាយដើម្បីបដិសេធ និងកម្ទេចជនក្បត់ទាំង៧រូប ហើយមកចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ។ នេះគឺជាសេចក្តីសម្រេចរបស់ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា--ពោលគឺជាសេចក្តីសម្រេចដែលមិនធ្លាប់មានពីមុនមកនៅក្នុងរយៈពេល៥ឆ្នាំចាប់តាំងការធ្វើរដ្ឋប្រហារប្រតិកិរិយារបស់ចក្រពត្តិអាមេរិក និងអាយ៉ងពួកវានៅថ្ងៃទី១៨ មីនា ១៩៧០ ។

២. បញ្ហាសំខាន់ និងមិនដែលមានពីមុនមកមួយទៀត គឺថា មហាសន្និបាតជាតិបានសម្រេចបះបង់ចោលនូវក្រដាសប្រាក់រៀលរបស់ពួកជនក្បត់ជាតិ ហើយបានជំនួសដោយក្រដាសប្រាក់ថ្មីរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលនឹងត្រូវដាក់ឲ្យប្រើប្រាស់ទូទាំងតំបន់រំដោះ ។ សេចក្តីសម្រេចនេះមានប្រសិទ្ធភាពស្មើនឹងការបោកគ្រាប់បែកចំចំពោះមុខជនក្បត់ទាំង៧រូប ហើយបានបណ្តាលឲ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះក្រដាសប្រាក់របស់អាយ៉ងលន់ នល់ ដែលមិនមានតម្លៃស្មើនឹងក្រដាសបង្គន់ផង ។ ជាលទ្ធផលនៃសេចក្តីសម្រេចនេះ ក្រដាសប្រាក់ដែលមិនមានស្ថេរភាពរួចទៅហើយនោះ ព្រមទាំងសេដ្ឋកិច្ចរបស់ជនក្បត់ទាំងនោះបានដួលរលំទាំងស្រុង ។ សេចក្តីសម្រេចនេះបង្ហាញដល់មតិជាតិ និងអន្តរជាតិឲ្យឃើញថា សេដ្ឋកិច្ចតំបន់រំដោះរបស់យើងមិនត្រឹមតែមានស្ថេរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរីកលូតលាស់ និងអភិវឌ្ឍយ៉ាង

លឿនមិនធ្លាប់មានពីមុនមក ។ តំបន់រំដោះរបស់យើងគឺជាប្រទេសឯករាជ្យ និងអធិបតេយ្យភាពនៅក្នុងគ្រប់វិស័យនយោបាយ យោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្រដាសប្រាក់ វប្បធម៌ សង្គម និងនៅក្នុងទូរគមនាគមន៍ក៏ដូចជាវិស័យនយោបាយជាតិ និងការបរទេស ។ ពួកអាយ៉ងក្បត់ជាតិទាំង៧រូបមិនមានទឹកដី សេដ្ឋកិច្ចប្រជាជន និងស្រូវអង្ករ ហើយឥឡូវនេះមិនមានក្រដាសប្រាក់ ។

៣. បញ្ហាសំខាន់មួយទៀត គឺបញ្ហាទំនាក់ទំនងអន្តរជាតិ ។ យើងមានទំនុកចិត្តជាពិសេសថា ប្រជាជននិងបណ្ដាអ្នកស្រឡាញ់សន្តិភាពអាមេរិក បានធ្វើការយកចិត្តទុកដាក់បំផុតចំពោះសេចក្ដីប្រកាសថ្ងៃទី២៦ កុម្ភៈ ឆ្នាំ១៩៧៥ នៃមហាសន្និបាតជាតិលើកទី២ របស់ប្រជាជាតិ និងប្រជាជនកម្ពុជា ។ មហាសន្និបាតជាតិបានគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កំពុងធ្វើការតស៊ូដោយមិនមានចេតនាអន្តរាគមន៍ទៅក្នុង ឬឈ្លានពានប្រឆាំងនឹងប្រជាជាតិ ឬប្រជាជនសហរដ្ឋអាមេរិក ឬប្រទេសណាផ្សេងមួយឡើយ និងប្រជាជនជិតក្ដីឆ្ងាយក្ដី ។ យើងធ្វើការតស៊ូនេះដើម្បីការពារសិទ្ធិរបស់យើង ឯករាជ្យភាពជាតិ និងកិត្តិយសជាតិរបស់យើងមិនច្រើនជាងនេះ ហើយក៏មិនតិចជាងនេះដែរ ។

ប្រជាជនកម្ពុជាមានទំនុកចិត្តថា ប្រជាជន និងអ្នកស្រឡាញ់សន្តិភាពអាមេរិក នឹងរួមចំណែកក្នុងការប្រឹងប្រែងបច្ចុប្បន្នដើម្បីបញ្ចប់សង្គ្រាមរបស់ចក្រពត្តិអាមេរិក និងអាយ៉ងរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា តាមរយៈការបង្ខំរដ្ឋការហ្វត-ឃីស៊ីងជ័រ ឲ្យបញ្ចប់ការផ្ដល់ជំនួយមកកាន់អាយ៉ងលន់ នល់ ដែលជាជនក្បត់ជាតិបង្កនូវវិនាសកម្ម ។ ការបញ្ឈប់នូវការចរាចរក្រដាសប្រាក់ទៅកាន់លន់ នល់ មានន័យថាបញ្ឈប់នូវចរាចរកាំភ្លើងទៅកាន់អាយ៉ងភ្នំពេញក្បត់ជាតិ ដែលប្រើប្រាស់ដើម្បីសម្លាប់ប្រជាជនកម្ពុជា ។ ប្រជាជន និងអ្នកស្រឡាញ់សន្តិភាពអាមេរិក នឹងឆ្លើយតបយ៉ាងពេញចិត្តចំពោះសេចក្ដីអំពាវនាវ ដែលបានធ្វើឡើងដោយមហាសន្និបាតជាតិលើកទី២របស់យើងនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ។ ប្រជាជនកម្ពុជា

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

សូមសម្តែងនូវការថ្លែងអំណរគុណចំពោះប្រជាជនអាមេរិក និងអ្នកស្រឡាញ់សន្តិភាពអាមេរិកទាំងអស់ ។ សរុបទៅ យើងនឹងកសាងឡើងវិញនូវសន្តិភាពនៅកម្ពុជា ហើយយើងនឹងកសាងឡើងវិញ និងពង្រឹងមិត្តភាពរវាងប្រជាជនយើងទាំងពីរប្រកបទៅដោយទស្សនវិស័យថ្មីជាប្រវត្តិសាស្ត្រ ។

[00166794]

**វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា កោតសរសើរជ័យជម្នះផ្នែកយោធាថ្មីៗរបស់កងកម្លាំងរំដោះជាតិ ប្រជាជនកម្ពុជា**

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរ ផ្សាយមកកម្ពុជាម៉ោង ០៤០០ ម៉ោងសកល GMT ថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[វិចារណកថា ៖ "ជ័យជម្នះដ៏រុងរឿង និងថ្មីៗផ្សេងៗទៀតទទួលបានដោយកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជានៅបណ្តាសមរភូមិជុំវិញភ្នំពេញ"]

[អត្ថបទ] ខណៈដែលមហាសន្និបាតជាតិលើកទី២ នាថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ បានប្រព្រឹត្តទៅដោយជោគជ័យ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏ក្លាហានរបស់យើងបានបើកការប្រយុទ្ធយ៉ាងខ្លាំងក្លាបំផុតមកលើខ្មាំងនៅសមរភូមិភ្នំពេញ និងតំបន់ជុំវិញភ្នំពេញ ដោយបានទទួលនូវជ័យជម្នះដ៏រុងរឿង និងអស្ចារ្យជាច្រើនកាលពីចុងខែកុម្ភៈ ។ ការរំដោះបានទីតាំងទួលលាបដ៏ធំកាលពីថ្ងៃទី២៧ ខែកុម្ភៈ ដោយយុទ្ធជន និងកម្មាភិបាលដ៏ក្លាហានរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា នៅសមរភូមិភាគខាងលិចនៃទីក្រុងភ្នំពេញ បានជះឥទ្ធិពលយ៉ាងខ្លាំងទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។ ព្រឹត្តិការណ៍នេះក៏បានរុញច្រានផងដែរ ឲ្យខ្មាំងរួមមានទាំងចក្រពត្តិអាមេរិក និងជនក្បត់ជា

អាយ៉ងទាំង៧រូប ធ្លាក់ទៅក្នុងសភាពស្ពន់ស្លោយ៉ាងខ្លាំង ដោយសារការរំដោះបានទីតាំងទួលលាប មានអត្ថន័យជាយុទ្ធសាស្ត្រដ៏សំខាន់ ។

ទួលលាបមានពោរពេញទៅដោយទីតាំងខ្មាំងមួយចង្កោមធំ ស្ថិតនៅចម្ងាយ៧គីឡូម៉ែត្រភាគខាងលិចពោធិ៍ចិនតុង ហើយវាគាំទ្រដល់ការការពារភាគខាងលិចនៃទីក្រុងភ្នំពេញ និងព្រលានយន្តហោះពោធិ៍ចិនតុង ។ នៅក្នុងខែមករា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាបានធ្វើការវាយប្រហារមួយយ៉ាងឆាប់រហ័ស ហើយបានឈានចូលទៅដល់បរិវេណនៃទីតាំងនោះ ។ នៅក្នុងខែកុម្ភៈ យើងបានបន្តប្រយុទ្ធខ្មាំងនៅទីតាំងទាំងអស់ជុំវិញទួលលាបចាប់ពីផ្លូវលេខ៤ (ថ្នាក់ឈើនាង) កំបូល និងពូនភ្នំ ដែលជាសមរភូមិមួយចម្ងាយ១០ គីឡូម៉ែត្រ [ពាក្យមិនអាចអានបាន] ។ នៅក្នុងថ្ងៃបន្តបន្ទាប់ យើងរំដោះបាន [ថ្នាក់ឈើនាង] ភាគខាងត្បូងនៃកំបូល វត្តភ្នៀត និងសុមាលី ទួលលាប និងតំបន់ដែលនៅជុំវិញនោះ ពូនខ្នុរ វត្តក្តុស ភាគនិរតីនៃទួលលាប និងជំរំលេខ១៥ ភាគខាងជើងនៃបែកចាន ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ឥឡូវបានចូលដល់ស្ថានីយរថភ្លើងនៅសំរោង ដែលមានចម្ងាយតែពីរគីឡូម៉ែត្រភាគខាងជើងពោធិ៍ចិនតុង ។ មូលដ្ឋានជើងអាកាសពោធិ៍ចិនតុង--ដែលជាទីសង្ឃឹមចុងក្រោយរបស់ពួកក្បត់ជាតិ--កំពុងស្ថិតក្នុងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ។ ក្នុងកំឡុងពេល២ខែចុងក្រោយនេះ កងកាំភ្លើងធំរបស់យើងបានផ្តោងជាប្រចាំទៅលើទីតាំងយុទ្ធសាស្ត្ររបស់ខ្មាំងនៅខាងក្នុងទីក្រុងភ្នំពេញ និងមូលដ្ឋានពោធិ៍ចិនតុង រំខានបានមួយផ្នែកធំដល់សកម្មភាពដឹកជញ្ជូនរបស់ខ្មាំង ។ ខ្មាំងឥឡូវនេះកំពុងស្ថិតក្នុងដង្ហើមចុងក្រោយ ពីព្រោះទន្លេមេគង្គត្រូវបានកាត់ផ្តាច់អស់រយៈពេល២ខែមកហើយ ហើយផ្លូវអាកាស និងផ្លូវទំនាក់ទំនងទាំងអស់ផ្សេងទៀតនឹងត្រូវកាត់ផ្តាច់នៅក្នុងពេលឆាប់ៗខាងមុខនេះ ។

នៅឯសមរភូមិផ្លូវលេខ៤ និងភាគនិរតី ៖ ក្នុងខែកុម្ភៈ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏ក្លាហានរបស់យើងបានកម្ទេចទាហានខ្មាំងមួយចំនួនធំ ជាពិសេសកងពលធំលេខ៣ កងពលតូច

លេខ១៣ និងកងពលតូចមួយចំនួនផ្សេងទៀត ។ អាឧត្តមសេនីយ ហែម ប៉ោ ត្រូវបានកម្ទេចដោយយុទ្ធជនដ៏ក្លាហានរបស់យើង នៅម្តុំកំបូល ។ អាឧត្តមសេនីយ ងួន លីឃាង មេបញ្ជាការកងពលធំលេខ៣ បានរងរបួសយ៉ាងធ្ងន់ធ្ងរ ខណៈដែលឧទ្ធម្ភាគចក្ររបស់វា ត្រូវគ្រាប់មួយក្នុងចំណោមគ្រាប់ផ្លោងរបស់យើងនៅម្តុំព្រៃប៉ូច-វត្ត និងសមរភូមិពោងពាយ ។ យុទ្ធជនកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងទទួលបាននូវជ័យជម្នះដ៏រុងរឿង និងអស្ចារ្យមួយទៀតនៅឯសមរភូមិច្រាំងខាងកើតនៃទន្លេមេគង្គទល់មុខទីក្រុងភ្នំពេញ កាលពីថ្ងៃទី២៥, ២៦ និង២៧ ខែកុម្ភៈ ។ យើងរំដោះបានទីតាំងខ្លាំងធំៗចំនួន៣ ៖ ព្រែកអំពិល ព្រែកហ្លួង និងព្រែកថោង ។ ទីតាំងទាំងនេះស្ថិតនៅចម្ងាយ១០, ៧ និង៦ គីឡូម៉ែត្របន្តបន្ទាប់បើគិតពីទីក្រុងភ្នំពេញ ។ ការរំដោះបាននូវទីតាំងសំខាន់ទាំង៣នេះ ដោយកូនចៅដ៏អង់អាចក្លាហាននៃប្រជាជនយើង បានពង្រីកបន្ថែមទៀតនូវតំបន់រំដោះដ៏ធំរបស់យើង ដែលជាតំបន់មួយលាតសន្ធឹងទៅដល់ព្រែកឡៅ ដែលមានចម្ងាយតែប្រាំគីឡូម៉ែត្រពីរាជវាំង ។ បន្ថែមទៅលើទីតាំងតូចនៅព្រែកតាម៉ាក់ ដែលនៅតែកំពុងកាន់កាប់ដោយខ្មាំង តំបន់ទាំងមូលចាប់ពីព្រែកឡៅឥឡូវនេះក្លាយទៅជាផ្នែកមួយនៃតំបន់រំដោះដ៏ធំរបស់យើង ។

នៅបណ្តាតំបន់ទល់មុខនឹងផ្នែកខាងក្រោមទីក្រុងភ្នំពេញ ៖ បន្ទាប់ពីកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងរំដោះបានកំពង់តាស្រី និងទីតាំងផ្សេងៗទៀត ខ្មាំងនៅសល់តែទីតាំងមួយចំនួនតូច ដែលយើងបានហ៊ុំព័ទ្ធហើយវាយប្រហារជាប្រចាំ ។ លើសពីនេះទៀតមួយផ្នែកធំនៃខ្សែការពារភាគកើតនៃទីក្រុងភ្នំពេញ នៅច្រាំងខាងកើតនៃទន្លេទល់មុខនឹងទីក្រុង បានទទួលបរាជ័យ ។

[00166795]

ជ័យជម្នះដ៏អស្ចារ្យពីរផ្សេងទៀតបានទទួលនៅតំបន់ភាគពាយ័ព្យនៃទីក្រុងភ្នំពេញ ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង បានវាយប្រហារនិងរំដោះបានជំរំត្រពាំងព្រាយ--ដែល

ជាទីបញ្ជាការរបស់កងពលតូចលេខ៧ និងកងពលធំលេខ៧ ដែលជាក់ស្តែងកម្លាំងរបស់យើងបានវាយកម្ទេច ។ កងកម្លាំងខ្មាំងនៅឈរជើងតែនៅភាគខាងត្បូងភ្នំបាសិទ នៅភាគខាងកើតភូមិពោន និងព្រែកញ្ញៅ ។ ទាហានទាំងនេះត្រូវបានកាត់ផ្តាច់ទំនាក់ទំនងឲ្យនៅឯកោទាំងស្រុង ហើយបានដាក់ឲ្យស្ថិតនៅក្រោមការវាយប្រហាររបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ។ ទីរួមខេត្តឧដុង្គ និងផ្នែកទាំងអស់នៃខេត្តឧដុង្គ ដែលធ្លាប់ជាខ្សែត្រៀមការពារភាគពាយ័ព្យត្រូវរំដោះបានកាលពីថ្ងៃទី២៥ ខែកុម្ភៈ ។ នៅឯភាគខាងជើង ភាគឦសាន និងភាគអាគ្នេយ៍នៃទីក្រុងភ្នំពេញ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏ក្លាហានរបស់យើង បានបន្តឈរជើងការពារទីតាំងរបស់ខ្លួនយ៉ាងរឹងមាំ ។ កម្លាំងខ្មាំងបានព្យាយាមដណ្តើមយកទៅវិញ [ពាក្យមិនអាចអានបាន] ព្រែកតាគង់ ផ្លូវលេខ៧ ចាប់ពីចំបក់មាស រហូតដល់ព្រៃលាប និងកោះដាច់-ខ្សាច់កណ្តាល ប៉ុន្តែកម្លាំងសត្រូវត្រូវបានរុញច្រានចេញ ឬត្រូវបានកម្ទេចដោយកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ។

នៅភាគអាគ្នេយ៍នៃទីក្រុងភ្នំពេញ ក៏ដូចជាផ្លូវលេខ៣៨ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងបានឈរជើងការពារបានយ៉ាងរឹងមាំនូវបណ្តាទីតាំងរបស់ខ្លួន ហើយបានបន្តដាក់សម្ពាធទៅលើខ្មាំង ។ នៅតំបន់ភាគអាគ្នេយ៍នៃទីក្រុងភ្នំពេញ ជាពិសេស យើងបានកម្ទេចខ្សែត្រៀមខ្មាំង ហើយបានពង្រីកតំបន់រំដោះរបស់យើងចាប់ពីទន្លេបាសាក់ រហូតដល់ផ្លូវលេខ១ ។ ខ្មាំងនៅដីឥដ្ឋ តាមផ្លូវជាតិលេខ១ ឥឡូវនេះកំពុងប្រឈមនឹងសភាពធ្ងន់ធ្ងរ ។ យើងថ្មីៗនេះបានរុញច្រានចេញនូវប្រាំវរសេនាតូចរបស់អាឌៀន ខែល ដែលបានព្យាយាមសម្រុកចូលក្នុងខ្សែត្រៀមរបស់យើង ។ អាឌៀន ខែល បានរងរបួសធ្ងន់ ។ ជាង៣០គីឡូម៉ែត្រនៃផ្លូវជាតិលេខ១ ត្រូវបានកាន់កាប់យ៉ាងរឹងមាំដោយកងកម្លាំងរបស់យើង ។ យោងតាមបណ្តារបាយការណ៍ស្ថិតិជាបឋមនៅក្នុងខែកុម្ភៈ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងនៅសមរភូមិឧដុង្គ និងលង្វែក និងជុំវិញភ្នំពេញ កម្ទេចបានទាហានខ្មាំងជាង៦ពាន់នាក់ និងរថក្រោះ

៩១គ្រឿង ពន្លិច ឬផុតចោលកប៉ាល់ផ្សេងៗ៣៥គ្រឿង ព្រមទាំងចាប់បានអាវុធផ្សេងៗប្រហែល១,៥០០ ដើម ក្នុងនោះរួមមានទាំងកាណុង១០៦មីលីម៉ែត្រផងដែរ ។

សរុបមកខ្សែការពារទីក្រុងភ្នំពេញឥឡូវនេះត្រូវបានរំខានពីគ្រប់ទិសទី ហើយទន្លេមេគង្គត្រូវបានកាត់ផ្តាច់ទំនាក់ទំនងទាំងស្រុង ។ ពោធិ៍ចិនតុងនឹងត្រូវបិទ ហើយខ្មាំងនឹងត្រូវស្លាប់ក្រោមការវាយប្រហារដ៏ខ្លាំងក្លារបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជានៅជុំវិញទីក្រុងភ្នំពេញ ព្រមទាំងការវាយប្រហាររបស់កងកម្លាំងប្រដាប់អាវុធ និងប្រជាជនរបស់យើងនៅទូទាំងប្រទេស ។

នេះគឺជាការអបអរសាទរ និងមោទនភាពបដិវត្តយ៉ាងពិតប្រាកដ ដែលប្រជាជនកម្ពុជាទូទាំងប្រទេសផ្ញើនូវការជូនពរយ៉ាងកក់ក្តៅរបស់គេជូនចំពោះយុទ្ធជនកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជានៅឯគ្រប់សមរភូមិទាំងអស់ នៅក្នុងទីក្រុងភ្នំពេញ និងនៅក្នុងទីក្រុង និងទៅចំពោះកូនចៅ និងកម្មាភិបាលដ៏អង់អាចក្លាហានរបស់គេ ឲ្យទទួលបាននូវសុខភាពល្អ និងកម្លាំងមាំមួន ដើម្បីធ្វើការវាយប្រហារឲ្យបានខ្លាំងក្លាទៅលើខ្មាំង ដើម្បីរំដោះទីក្រុងភ្នំពេញ និងមាតុភូមិកម្ពុជាជាទីស្នេហាបានទាំងស្រុង។ សូមអបអរសាទរចំពោះកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏អង់អាចក្លាហាន និងដ៏ជោគជ័យនៅសមរភូមិជុំវិញទីក្រុងភ្នំពេញ។

ការអំពាវនាវបន្ថែមសូមឲ្យប្រជាជនចូលរួមជាមួយនឹងការតស៊ូរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា

សំឡេងវិទ្យុរំដោះជាតិប្រជាជនកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយមកកម្ពុជា ម៉ោង០៤០០ ម៉ោងសកល GMT ថ្ងៃទី៧ ខែមីនា ១៩៧៥ បាងកក (BK)

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[អត្ថបទ] ពួកអាលន់ នល់ កំពុងស្ថិតនៅក្នុងការលំបាកដង្ហើមចុងក្រោយ ។ បងប្អូនព្រះសង្ឃពុទ្ធសាសនា និងជនរួមជាតិទាំងអស់ត្រូវតែក្រោកឡើង និងកម្ទេចបណ្ដាជនក្បត់ជាតិ ដើម្បីបញ្ចប់នូវការលំបាករបស់បងប្អូន ។ ប្រជាជនរបស់យើង និងពិភពលោកបានឃើញហើយថា ពួកអាលន់ នល់ នឹងមិនអាចឈរជើងបានយូរទៀតទេ ។ ទោះបីជាចក្រពត្តិអាមេរិកព្យាយាមយ៉ាងខ្លាំងដើម្បីជួយសង្គ្រោះពួកវាយ៉ាងណាក៏ដោយ ពួកគេនឹងមិនអាចជួយបានឡើយ ។ ថ្ងៃអវសានរបស់ពួកក្បត់លន់ នល់ កាន់តែខិតមកជិតហើយ ។

[00166796]

ព្រះសង្ឃពុទ្ធសាសនាជាទីគោរព ជនរួមជាតិជាទីស្នេហានៅទីក្រុងភ្នំពេញ និងនៅទីក្រុង*មួយចំនួនតូច*ផ្សេងទៀតដែលកំពុងស្ថិតនៅក្រោមការត្រួតត្រាជាបណ្តោះអាសន្នរបស់ខ្មាំង--រួមមានទាំងកម្មករ យុវជន សិស្ស និស្សិត គ្រូបង្រៀន អ្នករដ្ឋការគ្រប់វិស័យ អ្នកនយោបាយ មន្ត្រីជាន់ខ្ពស់ នាយទាហាន ពលទាហាន នគរបាល និងសមាជិកស្វ័យការពារ ៖ មួយថ្ងៃនៃការបន្តអត្ថិភាពនៃពួកអាយ៉ងទីក្រុងភ្នំពេញ មានន័យថា មួយថ្ងៃទៀតនៃការរងទុក្ខវេទនា ឬមានមនុស្សក្នុងចំណោមបងប្អូនរាប់ពាន់នាក់ត្រូវស្លាប់ ។ ពួកក្រុមចោរនោះមានតែ៧ក្បាល ហើយអាស្រ័យហេតុនេះបងប្អូនត្រូវតែចាត់វិធានការដូចខាងក្រោម ៖

១. បងប្អូនទាំងអស់ ព្រះសង្ឃពុទ្ធសាសនា និងជនរួមជាតិផ្សេងៗទៀត ត្រូវតែក្រោកឈរឡើងរួបរួមគ្នាចាត់គ្រប់វិធានការតស៊ូបកអាក្រាត និងថ្កោលទោសពួកអាយ៉ង តាមរយៈការឃោសនារបស់បងប្អូនផ្សព្វផ្សាយនូវពាក្យដែលបានឮ ជួបប្រជុំជាក្រុមតូចនិងធំនៅក្នុងបណ្តាវត្តអារាម តាមផ្លូវក្នុងភូមិ និងតាមផ្ទះ ឈប់ទៅសាលារៀន បដិសេធមិនសហការជាមួយបណ្តាសកម្មភាពរបស់ពួកអាយ៉ងទាំងអស់ ធ្វើបាតុកម្មតូចធំ រួមទាំងការវាយឆ្មក់ទៅលើឃ្លាំងអាហាររបស់ពួកជនក្បត់ និងដុតបំផ្លាញបណ្តាសាលាក្រុង និងការិយាល័យរបស់ចៅហ្វាយខេត្ត ។ បងប្អូនត្រូវតែយកគំរូតាមបងប្អូនសិស្ស និស្សិត យុវជន កម្មករ ពលករ និងប្រជាជនរាប់ពាន់នាក់ផ្សេងទៀតនៅខេត្តបាត់ដំបង និងព្រះសីហនុ ដែលបានចាប់ផ្តើមធ្វើបាតុកម្មរបស់គេកាលពីថ្ងៃទី២៥ ខែកុម្ភៈ និងដែលបានបន្តធ្វើបាតុកម្មនៅថ្ងៃទី២៦, ២៧ និងថ្ងៃទី២៨ ខែកុម្ភៈ ហើយបន្តនៅក្នុងខែមីនា ។

យុទ្ធជនកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង និងប្រជាជនកម្ពុជាទូទាំងប្រទេស អបអរសាទរ និងគាំទ្រយ៉ាងពេញទំហឹងចំពោះបងប្អូនកម្មករ ពលករ យុវជន សិស្ស និស្សិត និងគ្រូបង្រៀន និងយុទ្ធជនពិការទាំងអស់ដែលបានប្រយុទ្ធជាមួយនឹងកម្លាំងដ៏មុតស្រួចរបស់ពួកក្បត់ជាតិ តាម

រយៈការវាយសម្រុកទៅលើឃ្លាំងស្រូវរបស់ពួកក្បត់ជាតិនៅផ្សារអូរឫស្សី ។ បងប្អូនត្រូវតែបន្តតស៊ូតទៅមុខទៀត ។ ចំពោះកូនចៅរបស់ប្រជាជនដែលបានស្នាក់នៅតាមបណ្ដាវត្តអារាមផ្សេងៗ និងដែលបានទទួលការអប់រំនៅក្នុងសភាពការណ៍ដ៏លំបាកក្នុងពេលបច្ចុប្បន្ន បងប្អូនត្រូវតែសហការជាមួយនឹងព្រះសង្ឃពុទ្ធសាសនារបស់យើងដើម្បីពង្រឹងចលនាតស៊ូរបស់បងប្អូន ។ បងប្អូនគ្រូបង្រៀនទាំងពីរភេទ ហើយដែលមានប្រពៃណីនៃការតស៊ូ ត្រូវតែជួយលើកទឹកចិត្តចលនាតស៊ូ ។ បងប្អូនកម្មករ និងពលករ ដែលមិនមានកាន់អាវុធ ក៏ត្រូវតែក្រោកឈរឡើងដែរ ។ ព្រះសង្ឃពុទ្ធសាសនា ក៏ត្រូវតែចូលរួមការតស៊ូដែរ ។

២. យុទ្ធជនកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាកាន់តែខិតមកជិតបងប្អូនមកពីគ្រប់ទិសទី ។ ឥឡូវនេះគឺជាពេលវេលាមួយដ៏អស្ចារ្យ ។ បងប្អូនត្រូវតែកាន់អាវុធ ដណ្ដើមយកកាំភ្លើងពីខ្មាំង ហើយយកមកប្រឆាំងនឹងខ្មាំងវិញ ។ បងប្អូនត្រូវតែកម្ទេចសាលាក្រុង ការិយាល័យចៅហ្វាយខេត្ត ជំរំយោធា បណ្ដាទីតាំងទីបញ្ជាការយោធា ស្ថានីយនគរបាល ស្ថានីយកងអាវុធហត្ថ និងដុតបំផ្លាញស្ថាប័ន និងអាគារយោធា នយោបាយ និងសេដ្ឋកិច្ចរបស់ខ្មាំងទាំងអស់ ។

ចំពោះបងប្អូនជានាយទាហាន ពលទាហាន នគរបាល កងឈ្លប ដែលមានកាន់អាវុធនៅក្នុងដៃរបស់បងប្អូន បងប្អូនត្រូវតែប្រើអាវុធរបស់បងប្អូនប្រឆាំងនឹងពួកក្បត់លន់ នល់ សេរីមៈតៈ ស៊ឺន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ។ ពួកវាមានតែ៧ រូបតែប៉ុណ្ណោះ បើគ្មានពួកវាប្រជាជាតិ និងប្រជាជនកម្ពុជា នឹងមានសន្តិភាព ។

[00166798]

**សីហនុអបអរសាទរខៀវ សំផន ស្ដីអំពីជ័យជម្នះ និងមហាសន្និបាត**

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ភ្នាក់ងារព័ត៌មានកម្ពុជា [សម្ងាត់] ជាភាសាបារាំង ផ្សាយទៅអាស៊ីបូព៌ា ម៉ោង១១០០ ម៉ោងសកល GMT ថ្ងៃទី៨ មីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទ] កម្ពុជាថ្ងៃទី៨ មីនា ភ្នាក់ងារព័ត៌មានកម្ពុជា (AKI) -- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងអគ្គបញ្ជាការកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ខៀវ សំផន បានទទួលនូវសារស្វាគមន៍មួយមកពីប្រមុខរដ្ឋ និងប្រធានរណសិរ្សរួបរួមជាតិកម្ពុជា នរោត្តម សីហនុ នៅក្នុងឱកាសនៃជ័យជម្នះក្នុងវិស័យយោធាដែលទទួលបាននាពេលថ្មីៗ និងជោគជ័យនៃមហាសន្និបាតជាតិលើកទី២របស់កម្ពុជា ។ សារលិខិតនោះបាននិយាយថា ៖

នៅក្នុងឱកាសន័យជ័យជម្នះដ៏អស្ចារ្យថ្មីនេះ ដែលទទួលបានដោយកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏រុងរឿង ហើយជាពិសេសការរំដោះបាននៃក្រុងឧដុង្គ និងមោងឫស្សី ព្រមទាំងទីតាំងឈរជើងយុទ្ធសាស្ត្រ ដូចជាទួលលាប គាស់ក្រឡ ព្រែកហ្លួង និងនៅក្នុងឱកាសនៃការសម្រេចបានដោយរីករាយនូវមហាសន្និបាតជាតិរបស់ប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ខ្ញុំសូមស្នើបងប្អូន និងប្រជាជនកម្ពុជាជាទីគោរព និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរំដោះជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ទទួលយកនូវការស្វាគមន៍ដ៏កក់ក្ដៅដ៏ប្រកបដោយការកោតសរសើរ និងពេញចិត្ត ជាមួយនឹងការជូនពរយ៉ាងកក់ក្ដៅរបស់ខ្ញុំ ចំពោះជ័យជម្នះយ៉ាងពេញលេញ ។

គ្រាប់ផ្លោងនៅពោធិ៍ចិនតុង របស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា កម្ទេចនិងធ្វើឲ្យខូចខាតយន្តហោះ

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ភ្នាក់ងារព័ត៌មានកម្ពុជា [សម្ងាត់] ជាភាសាបារាំង ផ្សាយទៅអាស៊ីបូព៌ា ម៉ោង១១១៩ ម៉ោងសកល GMT ថ្ងៃទី៨ មីនា ១៩៧៥ បាងកក (BK)

[អត្ថបទដកស្រង់] កម្ពុជា ថ្ងៃទី៨ មីនា ភ្នាក់ងារព័ត៌មានកម្ពុជា (AKI) -- នៅភាគខាងលិចនៃទីក្រុងភ្នំពេញ នៅថ្ងៃទី៥ ខែមីនា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានបន្តបាញ់គ្រាប់រ៉ុក្កែតដាក់ពោធិ៍ចិនតុង កម្ទេចយន្តហោះ C-123 មួយគ្រឿង និងធ្វើឲ្យខូចយន្តហោះមួយគ្រឿង DC-8 ។ យន្តហោះដឹកទំនិញទាំងនេះបានប្រើប្រាស់ជាស្ពានអាកាសបង្កើតឡើងដោយចក្រពត្តិអាមេរិក ដើម្បីផ្គត់ផ្គង់បម្រុងដល់ពួកក្បត់នៅទីក្រុងភ្នំពេញ ។

[00166803]

AFP រាយការណ៍អំពីការអំពាវនាវរបស់មន្ត្រីរដ្ឋាភិបាល

ហុងកុង AFP ជាភាសាអង់គ្លេស GMT ថ្ងៃទី១០ មីនា ១៩៧៥ បាងកក (BK)

[អត្ថបទដកស្រង់] ថ្ងៃទី១០ ខែមីនា (AFP) -- ការបាញ់គ្រាប់រ៉ុក្កែត និងគ្រាប់ផ្លោងធុនធ្ងន់របស់ខ្មែរក្រហមដែលគាំទ្រដោយកុម្មុយនីស្តបានកម្ទេចយន្តហោះដឹកជញ្ជូនប្រភេទ DC-3 មួយគ្រឿងនៅឯព្រលានយន្តហោះពោធិ៍ចិនតុងនៅទីក្រុងភ្នំពេញ នាថ្ងៃនេះ នេះបើយោងតាមប្រភពយោធា ។

[00166804]

នៅក្នុងពេលនោះដែរ អគ្គបញ្ជាការកងទ័ពកម្ពុជាលោកឧត្តមសេនីយសុស្តែន ហ្វេណង់ដេ បានធ្វើការអំពាវនាវយ៉ាងប្រញាប់ប្រញាល់តាមវិទ្យុទៅកាន់ប្រជាជននៅទីក្រុងភ្នំពេញ ឲ្យមកប្រយុទ្ធស្នាក់ៀកស្មា

ជាមួយនឹងទាហានរដ្ឋាភិបាល ដែលត្រូវបានហ៊ុំព័ទ្ធហើយលោកសន្យាថា លោកនឹងមិនបោះបង់ចោលទាហានរបស់គាត់ឡើយ ។ សាររបស់គាត់តាមវិទ្យុនេះ បានថតកាលពីម្សិលមិញ ខណៈដែលលោកកំពុងធ្វើអធិការកិច្ចសមរភូមិប្រយុទ្ធនៅជិតព្រលានយន្តហោះពោធិ៍ចិនតុង ហើយសារនេះបានប្រកាសតាមវិទ្យុម្តងហើយម្តងទៀតកាលពីយប់មិញ និងថ្ងៃនេះ ។

លោកឧត្តមសេនីយបានស្រែកប្រកាសថា "កងទ័ពរបស់យើងនៅតែប្រយុទ្ធ" ។ "កងទ័ពយើងនឹងមិនទទួលជាដាច់ខាតនូវការបរាជ័យ ។" លោកមានប្រសាសន៍ថា "ពាក្យចចាមអារ៉ាមឆ្កួតៗ" បានផ្សព្វផ្សាយក្នុងបំណងបំបាក់ស្មារតី ។ លោកក៏បានអំពាវនាវផងដែរដល់អាជ្ញាធរស៊ីវិលឲ្យចលនាប្រជាជននៅទីក្រុង "ធ្វើយ៉ាងណាឲ្យប្រជាជនមកចូលរួម និងប្រយុទ្ធស្មាកៀកស្មាជាមួយនឹងកងកម្លាំងប្រដាប់អាវុធ ។"

រដ្ឋមន្ត្រីក្រសួងព័ត៌មាន ឆាង សុង មានប្រសាសន៍ថា របាយការណ៍ "ដែលមានបង្កប់នូវគោលដៅអ្វីមួយនោះ" នៅក្នុងសារព័ត៌មានបរទេស ដែលផ្សាយថា ការទម្លាក់អាវុធដោយមានលក្ខខណ្ឌរបស់ទីក្រុងភ្នំពេញទៅចុះចូលជាមួយខ្មែរក្រហម អាចនឹងចៀសមិនផុត គឺផ្អែកទៅលើ "ពាក្យចចាមអារ៉ាម និងការទស្សន៍ទាយក្នុងបំណងទុច្ចរិត" ។

[00166807]

វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា គូសបញ្ជាក់ឡើងវិញនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា ស្តីអំពីបញ្ហាសំខាន់ៗ

វិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរ ផ្សាយទៅកម្ពុជា ម៉ោង០៤០០ ម៉ោងសកល GMT ថ្ងៃទី១១ មីនា ឆ្នាំ១៩៧៥ បាងកង (BK)

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[បទអត្ថាធិប្បាយ ៖ “នៅក្នុងការតស៊ូរបស់ខ្លួន ប្រជាជនកម្ពុជាកំពុងតែប្រយុទ្ធដើម្បីទាមទារសេរីភាព ឯករាជ្យភាព និងកិត្តិយសរបស់ប្រជាជាតិរបស់គេ ។ ពួកគេមិនមានបំណងជ្រៀតជ្រែកចូលក្នុងឬប្រយុទ្ធប្រហារមកលើសហរដ្ឋអាមេរិក ឬប្រទេស ឬប្រជាជនណាមួយឡើយ”]

[អត្ថបទ] មហាសន្និបាតជាតិចំនួនពីរលើកបានគូសបញ្ជាក់សាជាថ្មីឡើងវិញ ដូចដែលបានបញ្ជាក់នៅក្នុងមហាសន្និបាតនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាផងដែរថា ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កំពុងតែធ្វើការតស៊ូបច្ចុប្បន្ននេះដោយមិនមានបំណងជ្រៀតជ្រែក ឬឈ្លានពានទៅលើសហរដ្ឋអាមេរិក ឬប្រជាជន ឬប្រទេសដទៃណាមួយឡើយ ។ យើងកំពុងធ្វើការតស៊ូដើម្បីសេរីភាព ឯករាជ្យភាព និងកិត្តិយសនៃជាតិយើង ។

មហាសន្និបាតជាតិលើកទី២ បានធ្វើឡើងនៅក្នុងពេលមួយដែលសភាពការណ៍បានអំណោយផលបំផុតចំពោះបដិវត្តកម្ពុជា និងនៅពេលដែលពួកជនក្បត់ជាតិទាំង៧រូប កំពុងតែជួបការលំបាកក្នុងដង្ហើមចុងក្រោយ ហើយឈានទៅរកការដួលរលំទាំងស្រុង បានបង្ហាញបន្ថែមនូវការបកស្រាយពិស្តារអំពីមាគ៌ានយោបាយជាតិ និងអន្តរជាតិរបស់យើង ។ លើសពីនេះទៀត នៅក្នុងកថាខណ្ឌទី២ នៃសេចក្តីប្រកាសចុងក្រោយរបស់ខ្លួន មហាសន្និបាតជាតិបានគូសបញ្ជាក់យ៉ាងច្បាស់លាស់នូវគោលជំហររបស់យើងពាក់ព័ន្ធនឹងចក្រពត្តិអាមេរិក ។ ប្រជាជនទូទាំងពិភពលោកដែលស្រឡាញ់សន្តិភាព បានដឹងយ៉ាងច្បាស់នូវមាគ៌ានយោបាយនេះ និងជំហររបស់ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ នៅផ្ទៃក្នុង យើងប្រកាន់ខ្ជាប់នូវសាមគ្គីភាពដ៏អស្ចារ្យរបស់ប្រជាជនទាំងមូល ដោយមិនរើសអើងវណ្ណៈ សង្គម និងមាគ៌ានយោបាយ ជំនឿសាសនា ហើយមិនគិតអំពីអតីតកាលរបស់ពួកគេ-- លើកលែងតែចំពោះជនក្បត់ជាតិទាំង៧រូប លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

បូរ៉េត និងសុស្តែន ហ្វេណង់ដេ ។ ទិសដៅយូរអង្វែងនាបច្ចុប្បន្ន និងអនាគតរបស់យើងគឺត្រូវកសាងកម្ពុជាឲ្យ*សម្បូរ*រុងរឿង ដែលក្នុងនោះប្រជាជនកម្ពុជាមានអាហារហូប និងសម្លៀកបំពាក់គ្រប់គ្រាន់ មានផ្ទះរស់នៅដោយខ្លួនឯង និងមានមន្ទីរពេទ្យ និងសាលារៀន ។

[00166808]

នៅក្រៅប្រទេស យើងប្រកាន់ខ្ជាប់នូវជំហរអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ហើយប្រកាន់នូវគោលការណ៍៥ចំណុចសន្តិសហវិជ្ជមាន បង្កើតនូវទំនាក់ទំនងជាមួយបណ្តាប្រទេសទាំងអស់ ទាំងជិតទាំងឆ្ងាយ ដោយមិនគិតពីប្រព័ន្ធសង្គម និងនយោបាយ ។ គោលការណ៍ចម្បងរបស់យើង គឺសមភាព ការគោរព ផលប្រយោជន៍ទៅវិញទៅមក មិនចូលបក្សសម្ព័ន្ធ និងមិនអន្តរាគមន៍ចូលកិច្ចការប្រទេសដទៃ ។

ទាំងនេះជាកត្តាដាច់ខាត និងមិនផ្លាស់ប្តូរ ។ ប្រជាជាតិ និងប្រជាជនកម្ពុជារបស់យើង រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នឹងមិនទទួលយកការសម្របសម្រួលណាមួយ ហើយនឹងមិនអត់ឱនចំពោះបរទេសណាដែលដាក់មូលដ្ឋានយោធាល្បានពានលើទឹកដីរបស់យើង ។

ជំហរនេះរបស់ប្រជាជាតិ ប្រជាជន រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជារបស់យើង គឺជាជំហរយុទ្ធសាស្ត្រមិនផ្លាស់ប្តូរយូរអង្វែង និងច្បាស់លាស់ ។ អាស្រ័យហេតុនេះ ប្រជាជន និងប្រជាជាតិកម្ពុជា ក្រោមការដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយមានទំនាក់ទំនងការទូតជាមួយនឹងប្រទេសជាង៦០ នឹងបង្កើតទំនាក់ទំនងជាមួយបណ្តាប្រទេសផ្សេងៗទៀត ទាំងជិត ទាំងឆ្ងាយ ដរាបណាគេគោរពយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ដូចបានរៀបរាប់ខាងលើ ។ ដូចដែលបានគូសបញ្ជាក់នៅក្នុងមហាសន្និបាតជាតិលើកទី២ រួចមកហើយ ប្រជាជាតិ និងប្រជាជនកម្ពុជារបស់យើងនឹងទទួលជំនួយពីប្រទេសណាក៏បាន ដរាបណាជំនួយនោះមិនមានភ្ជាប់ដោយលក្ខខណ្ឌ ។

ពាក់ព័ន្ធនឹងសហរដ្ឋអាមេរិក ប្រជាជនកម្ពុជាមានជំនឿទុកចិត្តចំពោះស្មារតីល្អរបស់ប្រជាជនអាមេរិក និងប្រជាជនទាំងអស់ដែលស្រឡាញ់សន្តិភាពនៅក្នុងប្រទេសនោះ ។ ឥឡូវនេះជាងពេលណាៗទាំងអស់ គឺជាពេលដែលប្រជាជនអាមេរិកត្រូវប្រើរាល់មធ្យោបាយទាំងអស់ដែលមាន ដើម្បីទប់ស្កាត់រាល់ទម្រង់នៃការជ្រៀតជ្រែក និងការផ្តល់ជំនួយរបស់ចក្រពត្តិអាមេរិក ហើយបង្ខំឱ្យរដ្ឋការហ្វូត-ឃីស៊ីងជ័រ បោះបង់ចោលនូវជនក្បត់ទាំង៧រូប លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ដែលបានត្រូវធ្លាក់ខ្លួនរួចទៅហើយ ក្លាយជាសពខាងវិស័យនយោបាយ យោធា និងសេដ្ឋកិច្ច ។

ថវិកាចំនួន២២២លានដុល្លារ ឬចំនួនសរុបប៉ុន្មានក៏ដោយ ក៏មិនអាចជប់ជនក្បត់ទាំង៧រូបឱ្យរស់ឡើងវិញបានដែរ ។ ប្រជាជនអាមេរិក និងប្រជាជនទាំងអស់ផ្សេងទៀត ទោះជិតទោះឆ្ងាយ នឹងទទួលបាននូវកិត្តិយសក្នុងការចូលរួមស្តារឡើងវិញឱ្យបានឆាប់រហ័សនូវសន្តិភាពនៅកម្ពុជា ប្រសិនបើគេបានសម្រេចដោយជោគជ័យក្នុងការបញ្ឈប់ភ្លាមៗនូវជំនួយរបស់សហរដ្ឋអាមេរិកទៅកាន់ពួកលន់ នល់ និងទៅកាន់គ្រប់ទម្រង់នៃការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក ។

[00166811]

របាយការណ៍របស់ AFP

ប៉ារីស AFP ជាភាសាអង់គ្លេស ម៉ោង១៣៤៨ ម៉ោងសកល GMT ថ្ងៃទី១២ មីនា ឆ្នាំ១៩៧៥ OW

[អត្ថបទ] ប៉ារីស ថ្ងៃទី១២ មីនា (AFP)--ព្រះអង្គម្ចាស់នរោត្តម សីហនុ នៃប្រទេសកម្ពុជា បានមានព្រះបន្ទូលថា ថ្ងៃនេះ កងកម្លាំងរបស់គាត់មិនមានបំណងវាយប្រហារផ្ទាល់ទៅលើទីក្រុងភ្នំពេញទេ ប៉ុន្តែព្រះអង្គប្រាកដព្រះហឫទ័យថា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ (RGNUC) និងខ្មែរក្រហម នឹងឡើងកាន់អំណាចនៅទីក្រុង នៅរដ្ឋធានីនៃកម្ពុជានៅចុងឆ្នាំនេះ ។

ព្រះអង្គ ដែលបានសម្តែងទស្សនៈស្តីអំពីអនាគតនយោបាយនៃកម្ពុជាក្នុងបទសម្ភាសន៍ជាមួយនឹងវិទ្យុ និងទូរទស្សន៍បារាំង បានមានបន្ទូលថា មិនមានផែនការវាយប្រហារភ្លាមៗទាំងស្រុងមកលើទីក្រុងភ្នំពេញទេ ក្នុងការរារាំងអាមេរិកមិនឲ្យជ្រៀតជ្រែកដោយផ្ទាល់នៅក្នុងសមរភូមិលើដី សមុទ្រ និងអាកាស ។ យុទ្ធសាស្ត្រប្រយុទ្ធនឹងលន់ នល់ គឺផ្អែកទៅលើការធ្វើសង្គ្រាមឲ្យខ្មាំងបាត់បង់នូវអានុភាព នេះជាប្រសាសន៍របស់ព្រះអង្គ ។

ព្រះអង្គមានបន្ទូលថា បន្ទាប់ពីការដួលរលំនៃរបបលន់ នល់ ខ្មែរក្រហម “នឹងក្លាយទៅជាម្ចាស់តែមួយគត់នៃវាសនាប្រជាជាតិ និងប្រទេសខ្មែរ ។” របបលន់ នល់ ឥឡូវនេះ “បានកំពុងស្ថិតនៅដំណាក់កាលចុងក្រោយរបស់ខ្លួនហើយ” ហើយជ័យជម្នះទាំងស្រុងរបស់កងកម្លាំងគាំទ្រសីហនុ នឹងទទួលបាននៅមុនចុងឆ្នាំ១៩៧៥ ព្រះអង្គបានមានព្រះបន្ទូលបន្ថែម ។

តបនឹងសំណួរស្តីអំពីទម្រង់នៃរបបបន្ទាប់ពីការដួលរលំនៃមហាសេនាលន់ នល់ ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ព្រះអង្គម្ចាស់សីហនុ បានមានបន្ទូលថា ៖ “បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបាន ខ្មែរក្រហមនឹងក្លាយទៅជាម្ចាស់តែមួយគត់នៃជោគវាសនាប្រជាជាតិ និងប្រទេសខ្មែរ ។ អាស្រ័យទៅលើការសម្រេចចិត្តរបស់ពួកគេ ថាតើសម្រេចហៅកម្ពុជាថា “ព្រះរាជាណាចក្រ” ឬ “សាធារណរដ្ឋ” មួយ ។”

Original EN: 00166779-00166887
និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងមានអានុភាពខ្លាំងក្លាក្រៃលែង ។ មិនមានអ្វីអាចទប់ទល់បានឡើយ ។ ពួកជនក្បត់ និងពួកលក់ជាតិទាំង៧នឹងត្រូវដួលរលំ ហើយកម្ទេចបានទាំងស្រុង ។

[00166838]

នៅពេលដែលអាយ៉ងរបស់វានៅទីក្រុងភ្នំពេញជិតដួលរលំហើយនោះ រដ្ឋការ ហ្វត-ឃីស៊ីងជ័រ បានកំពុងជួបនូវការបរាជ័យ និងការអាម៉ាស់ ។ ពួកវានាបច្ចុប្បន្ននេះកំពុងព្យាយាមទាំងត្រដរនៅក្នុងទីក្រុងវ៉ាស៊ីនតោននៅក្នុងផែនការជាលើកចុងក្រោយយកអស់លទ្ធភាពឲ្យសភាសហរដ្ឋអាមេរិកផ្តល់នូវជំនួយចំនួន ២២២លានដុល្លារ សម្រាប់ពួកលន់ នល់ ដែលកំពុងជួបការលំបាក ពីព្រោះពួកវាសង្ឃឹមថា ជំនួយនេះនឹងអាចជួយឲ្យពួកអាយ៉ងរបស់វាបន្តរស់រហូតទៅដល់រដូវវស្សាខាងមុខ ហើយថា នឹមអាណានិគមចាស់ថ្មីរបស់ពួកវា អាចបន្តរយៈពេលថែមទៀតនៅឈរជើងទីក្រុងភ្នំពេញ និងតំបន់មួយចំនួនតូចទៀតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្លាំង ។ នាបច្ចុប្បន្នប្រជាជនអាមេរិក សភាសហរដ្ឋអាមេរិក អ្នកនយោបាយអាមេរិក បណ្តាអ្នកស្រឡាញ់សន្តិភាព អ្នកសារព័ត៌មាន និងទស្សនៈអន្តរជាតិកំពុងតែប្រឆាំងទៅនឹងរដ្ឋការនេះ ដោយទាមទារឲ្យរដ្ឋការហ្វត-ឃីស៊ីងជ័រ ត្រូវតែបញ្ឈប់ផ្តល់ជំនួយទៅដល់ពួកលន់ នល់នៅភ្នំពេញ ។

នៅក្នុងឧបាយកលរបស់វា ដើម្បីបោកប្រាស់មតិសហរដ្ឋអាមេរិក អ្នកនយោបាយសហរដ្ឋអាមេរិកពិភពលោក និងប្រជាជនកម្ពុជា រដ្ឋការហ្វត-ឃីស៊ីងជ័រ បានផ្លាស់ប្តូរសេះអាយ៉ងរបស់ពួកវានៅភ្នំពេញ ហើយបណ្តេញចេញស៊ុស្តែន ហ្វេណង់ដេ ដែលបានទទួលបរាជ័យ ។ នាបច្ចុប្បន្នពួកវាបានព្យាយាមសើរើខុទ្ទកាល័យឡុង បូរ៉េត ហើយធ្វើឲ្យមើលទៅឃើញល្អ ។ តែទោះជាយ៉ាងណាក៏ដោយ ការពិតនៅតែជាការពិតថា ខុទ្ទកាល័យនេះនឹងនៅតែបម្រើតួនាទីដដែលក្នុងឋានៈជាឧបករណ៍របស់ការឈ្លានពានចក្រពត្តិអាមេរិក ។ ប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុ

ជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្តេជ្ញាចិត្តទាត់ចោលគ្រប់ឧបាយកលទាំងនេះ ។ យើងនឹងមិនសម្របសម្រួលឡើយ ។ យើងនឹងមិនចរចាជាមួយឧបករណ៍របស់ចក្រពត្តិអាមេរិកឈ្លានពាននោះឡើយ ។ ចក្រពត្តិអាមេរិកត្រូវតែបញ្ឈប់ការធ្វើអន្តរាគមន៍ ការជ្រៀតជ្រែក និងការឈ្លានពានមកក្នុងកម្ពុជា ។ ពួកវាត្រូវតែដកថយយកទៅវិញនូវទីប្រឹក្សាយោធា និងទីប្រឹក្សាផ្សេងៗទៀត រួមមានទាំងកម្មាភិបាលស្វែងរកសន្តិភាពចេញពីកម្ពុជា ។ ប្រជាជនកម្ពុជាត្រូវសម្រេចចិត្តដោយខ្លួនឯងនូវជោគវាសនានៃប្រជាជាតិរបស់ពួកគេ ដោយមិនមានការជ្រៀតជ្រែកមកពីសហរដ្ឋអាមេរិក និងបរទេសណាទាំងអស់ ។

បងប្អូនអ្នករដ្ឋការ នាយទាហាន ពលទាហាន អ្នកនយោបាយ និងមន្ត្រីជាន់ខ្ពស់នៅទីក្រុងភ្នំពេញ និងទីក្រុងមួយចំនួនតូច ដែលនៅតែស្ថិតនៅក្រោមការក្តោបក្តាប់របស់ខ្មាំងនៅឡើយ ត្រូវតែលះបង់ចោលពួកជនក្បត់ទាំង៧រូប ហើយមកចូលរួមក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជា ។ ប្រជាជនរបស់យើងត្រូវដាក់ទណ្ឌកម្មជនក្បត់ទាំង៧រូប ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងជាតិសាសន៍ឯងរបស់ពួកវា ។ បងប្អូនមិនត្រូវសហការជាមួយពួកជនក្បត់ទេ ។ សូមបោះបង់ចោលពួកវាភ្លាម ហើយប្រមូលផ្តុំការប្រឹងប្រែងរបស់បងប្អូនសហការជាមួយប្រជាជន និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ដើម្បីកម្ទេចពួកវា ។ នេះគឺជាលទ្ធភាពតែមួយគត់សម្រាប់ការបន្តរស់របស់បងប្អូន ។

## ការអំពាវនាវមួយបានស្នើឲ្យមានការច្របូកច្របល់ក្នុងមជ្ឈដ្ឋានស៊ីវិល

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៤០០ GMT ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[បទអត្ថាធិប្បាយ ៖ “បងប្អូនជនរួមជាតិនៅទីក្រុងភ្នំពេញ និងតំបន់ដែលស្ថិតនៅក្នុងការគ្រប់គ្រងបណ្តុះអាសន្នរបស់ខ្មាំង ត្រូវតែរួមសាមគ្គីក្រោកឈរឡើងដើម្បីផ្តួលរំលំពួកក្បត់ជាតិបញ្ចប់ទុក្ខវេទនារបស់ប្រជាជនយើង”]

[អត្ថបទ] សភាពការណ៍នៅភ្នំពេញ និងទីក្រុងមួយចំនួនតូចទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ពួកក្បត់ កាន់តែស្ថិតនៅក្នុងភាពធូន់ធ្ងរឡើងៗ ។ សភាពការណ៍ធ្ងន់ធ្ងរនេះ គឺដោយសារការពិតថា បងប្អូនជនរួមជាតិរបស់យើង--រួមមានទាំងអ្នករដ្ឋការ នាយទាហាន ពលទាហាន អ្នកនយោបាយ និងឥស្សរជនគ្រប់ប្រភេទ--បានរួមសាមគ្គីគ្នា ហើយបានធ្វើក្លូដកម្ម ដើម្បីផ្តួលរំលំជនក្បត់ទាំង៧រូប ។ បងប្អូនជនរួមជាតិមកពីគ្រប់ស្រទាប់វណ្ណៈនៅទីក្រុងភ្នំពេញ និងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង បានយល់ដឹងកាន់តែច្បាស់ថា នេះគឺជាមធ្យោបាយដើម្បីបញ្ចប់ទុក្ខវេទនារបស់ពួកគេ និងរាល់រូបភាពនៃការអន្តរាគមន៍របស់ចក្រពត្តិអាមេរិកមកក្នុងកម្ពុជា ។ កត្តាចម្បងដែលសូមអំពាវនាវបងប្អូនរបស់យើងឲ្យរួបរួម និងរៀបចំក្លូដកម្មដើម្បីផ្តួលរំលំជនក្បត់ទាំង៧ និងបញ្ចប់អត្ថិភាពរបស់ពួកវា រួមមាន៖

១. កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានឈានជើងចូលកាន់តែជិតមកកាន់ទីក្រុងភ្នំពេញ ហើយបានធ្វើការវាយប្រហារកាន់តែខ្លាំងមកពីគ្រប់ទិសទីមកលើទីរួមខេត្តមួយចំនួនតូច ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ។ កម្លាំងទឹកចិត្តនៃការបើកការវាយលុយរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង មានអានុភាពខ្លាំងក្លាមិនអាចមានអ្វីមកទប់ទល់បានឡើយ ។ កងកម្លាំងប្រដាប់អាវុធដែលកំពុងតែបាក់ស្រុតរបស់ពួកក្បត់ កំពុងតែខិតជិតទៅដួលរលំ ហើយនឹងដួលរលំទាំងស្រុងនៅពេលអនាគតដ៏ខ្លីខាងមុខ ។

[00166839]

២. ភ្នំពេញមូលដ្ឋានឈរជើងនៃការឈ្លានពានរបស់ចក្រពត្តិអាមេរិក និងអាយ៉ងពួកវា ហើយនិងទីរួមខេត្តដែលស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្ដោះអាសន្នរបស់ខ្មាំង ត្រូវបានដាក់ឲ្យស្ថិតនៅក្នុងភាពឯកោ ។ រាល់ទំនាក់ទំនងសេដ្ឋកិច្ចមកទីក្រុងទាំងអស់ ហើយនិងទីក្រុងភ្នំពេញ ត្រូវបានបំបាត់ទាំងស្រុង ។ ផ្លូវផ្គត់ផ្គង់ជើងទឹក និងជើងគោកត្រូវបានទប់ស្កាត់ ហើយមូលដ្ឋានព្រលានយន្តហោះពោធិ៍ចិនតុង បានទទួលរងការខូចខាតយ៉ាងខ្លាំង ។ កងកាំភ្លើងធ្លោងរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ជាប្រចាំថ្ងៃធ្លោងមកដាក់មូលដ្ឋានជើងអាកាសនេះ ហើយខ្មាំងស្ទើរតែមិនអាចប្រើព្រលាននេះបាន ។

ទោះបីជាមានយន្តហោះដឹកជញ្ជូន និងផ្គត់ផ្គង់របស់ចក្រពត្តិអាមេរិកក៏ដោយ បញ្ហាផ្គត់ផ្គង់ពួកជនក្បត់ទាំង៧រូបនៅក្នុងទីក្រុងភ្នំពេញ ដូចជាស្រូវ អាហារ គ្រាប់រំសេវ ប្រេងឥន្ធនៈ រថក្រោះ និងសព្វាវុធនឹងមិនត្រូវបានដោះស្រាយរួចបានឡើយ ។ មិនដូចជាទីតាំងនៅដោះកញ្ចនោះឡើយ ផ្ទុយមកវិញការបន្តរស់បានរបស់ទីក្រុងភ្នំពេញ មិនអាចពឹងផ្អែកទៅលើការទម្លាក់មកពីអាកាសបានឡើយ ។ ពួកចក្រពត្តិអាមេរិកមិនត្រឹមតែត្រូវផ្គត់ផ្គង់ដល់ភ្នំពេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកំពត តាកែវ កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង កំពង់ចាម កំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់ តាមរយៈការទម្លាក់ពីអាកាសមករបៀបនេះ ។ លើសពីនេះទៀតពួកវាត្រូវផ្គត់ផ្គង់ទីតាំងតូចៗផ្សេងៗទៀត ដូចជាអ្នកលឿង និងលង្វែក ។

នៅក្នុងឆ្នាំ១៩៧៤ ពួកក្បត់ជាតិបានរស់នៅទៅបានអាស្រ័យទាំងស្រុងទៅលើជំនួយសហរដ្ឋអាមេរិក ដែលនាំមកតាមរយៈទន្លេមេគង្គ ។ ឥឡូវនេះទន្លេមេគង្គលែងដំណើរការបានទៀត ហើយនឹងនៅតែត្រូវ

ទប់ស្កាត់បានជាអចិន្ត្រៃយ៍ ។ ទោះជារដ្ឋការ ហ្វត មានការចចេសរឹងរូសយ៉ាងណាក៏ដោយក្នុងការបន្តផ្តល់មកដល់ពួកក្បត់នូវជំនួយ ក៏ពួកវាមិនដែលបានសម្រេចដល់គោលដៅរបស់ពួកវាឡើយ ។

៣. ពួកក្បត់ទាំង៧រូបបានទទួលរងនូវការឯកោទាំងស្រុង ។ ប្រជាជននៅក្នុងប្រទេស និងនៅលើពិភពលោកបដិសេធ ស្អប់ខ្ពើម និងប្រឆាំងពួកវា មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដូចជាអាហ្វត-ឃីស៊ីងជ័រ និងស្តេសស៊ីងជ័រ ដែលនៅគាំទ្រពួកក្បត់លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុងបូរ៉េត និងសុស្តែន ហ្វេណង់ដេ មិនមាននរណាផ្សេងគាំទ្រពួកវាឡើយ ។ ស្ថានទូតបរទេសភាគច្រើនបានដកចេញពីភ្នំពេញ ។ សូម្បីតែស្ថានទូតអ៊ីស្រាអែល ដែលពួកជនក្បត់ទាំង៧រូបបានចាត់ទុកថាជាគ្រូអាចារ្យពួកវា ក៏បានដកខ្លួនចេញដែរ ។ មិនមាននរណាមួយហ៊ានស្នាក់នៅទីក្រុងភ្នំពេញ ហើយមិនមាននរណាគាំទ្រពួកជនក្បត់ឡើយឥឡូវនេះ ។ សូម្បីតែមជ្ឈដ្ឋានសហរដ្ឋអាមេរិកមួយចំនួនដែលធ្លាប់គាំទ្រពួកវា ក៏បច្ចុប្បន្ននេះបានប្រែប្រួលទស្សនៈរបស់ពួកគេ ហើយថ្លែងថា អ្វីតែម្យ៉ាងគត់ដែលពួកលន់ នល់ អាចធ្វើបានគឺត្រូវតែទម្លាក់អាវុធ ។

៤. លើសពីនេះទៀត ពួកជនក្បត់ទាំង៧រូប បានកំពុងប្រឈមនឹងការបែកបាក់មតិគ្នាយ៉ាងធ្ងន់ធ្ងរ ។ ពួកគេចោទ ហើយដាក់កំហុសគ្នាទៅវិញទៅមក ចំពោះការបរាជ័យនាពេលថ្មីៗកន្លងទៅនេះ ។ លន់ នល់ និងសុស្តែន ហ្វេណង់ដេ ឥឡូវកំពុងព្យាយាមរកមធ្យោបាយ និងវិធីសាស្ត្រដើម្បីកម្ទេចគ្នាទៅវិញទៅមក ។ សភាពការណ៍ផ្ទៃក្នុងរបស់ពួកវា កំពុងជួបប្រទះនឹងវិបត្តិធ្ងន់ធ្ងរ ហើយអគ្គបញ្ជាការរបស់ពួកគេកំពុងតែរង្គោះរង្គើ ។ ចក្រពត្តិអាមេរិកមិនអាចជំនួស ឬផ្លាស់ប្តូរបណ្តាជនក្បត់ទាំងនេះបានទេ ពីព្រោះពួកគេដូចៗគ្នាទាំងអស់ ។ ជនក្បត់ទាំង៧រូប ត្រូវបានប្រជាជនបដិសេធ ហើយប្រជាជនតាមរកមុខដើម្បីកម្ទេច ។

៥. កត្តាសំខាន់បំផុតនោះគឺថា ជាការពិតដែលថា៩៧ភាគរយនៃដែនដីកម្ពុជាទាំងមូល ឥឡូវត្រូវបានរំដោះ ។ តំបន់រំដោះដ៏រុងរឿងធំទូលាយនេះ ដែលមានប្រជាជនរស់នៅ៦លាននាក់ ដើរតួនាទីជាតំបន់សមរភូមិក្រោយយ៉ាងរឹងមាំ និងអស្ចារ្យ ដែលអាចធានាសន្តិសុខ និងជ័យជម្នះអស្ចារ្យសម្រាប់បងប្អូនជនរួមជាតិនៅភ្នំពេញ និងនៅកន្លែងទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ។

ព្រះសង្ឃពុទ្ធសាសនាជាទីសក្ការៈ បងប្អូនជនរួមជាតិជាទីស្នេហា ៖ ឥឡូវនេះគឺជាពេលដែលបងប្អូនត្រូវសាមគ្គីគ្នាប្រយុទ្ធ និងផ្តួលរំលំជនក្បត់ទាំង៧រូប ។ នេះគឺជាពេលវេលាអំណោយផលបំផុត ។ ពួកជនក្បត់បាននៅឯកោឡើងៗជាងពេលណាទាំងអស់ ។ ប្រសិនបើបងប្អូនបណ្តោយឲ្យពួកវានៅបន្តរស់មួយថ្ងៃ បានន័យថា បងប្អូននឹងរងទុក្ខវេទនាបន្ថែមកាន់តែយូ ។ បងប្អូនត្រូវតែប្រមូលការប្រឹងប្រែងរបស់បងប្អូនហើយផ្តួលរំលំពួកវា ។ កាលណាបងប្អូនកម្ទេចពួកវាបានកាន់តែឆាប់ នោះបងប្អូនឹងកាន់តែរួចផុតកាន់តែឆាប់ដែរចេញពីទុក្ខវេទនារបស់បងប្អូន ។

បងប្អូនជនរួមជាតិរួមទាំងកម្មករ ពលករ យុវជន សិស្ស និស្សិត គ្រូបង្រៀន អ្នករដ្ឋការនានាត្រូវតែងើបឡើងកាន់អាវុធ ។ បងប្អូនអ្នកនយោបាយ និងមន្ត្រីជាន់ខ្ពស់ទាំងអស់ត្រូវតែចូលរួមជាមួយប្រជាជន ។ បងប្អូននាយទាហាន ពលទាហាន នគរបាល អាវុធហត្ថ កងឈ្លប និងកងកម្លាំងផ្លូ ដែលកាន់អាវុធ រថក្រោះ និងយន្តហោះ ត្រូវតែវាយទៅលើជនក្បត់ទាំង៧រូប ។

[00166840]

បងប្អូនប្រាកដជានឹងឈ្នះ ប្រជាជនរបស់យើងប្រាកដជានឹងឈ្នះ ។ ប្រសិនបើបងប្អូនលែងមានមធ្យោបាយតស៊ូនៅក្នុងបណ្តាទីក្រុងនានាទៀតហើយ សូមអញ្ជើញបងប្អូនប្រញាប់ចូលមកក្នុងតំបន់រំដោះ ។ ប្រជាជនរបស់យើងនឹងស្វាគមន៍បងប្អូនយ៉ាងកក់ក្តៅ ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

កម្លាំកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងប្រាកដជានឹងឈ្នះ ។ រណសិរ្សរួបរួមជាតិ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្រាកដជានឹងដណ្តើមបានទីក្រុងភ្នំពេញ និងប្រទេសទាំងមូល! ជ័យោចលនាតស៊ូដើម្បីកម្ទេចជនក្បត់ជាតិទាំង៧រូប!

គ្មានការសម្របសម្រួល គ្មានការចរចា អាចទៅរួចបានឡើយ

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរ ផ្សាយទៅកម្ពុជា ម៉ោង ០៤០០ GMT ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

[បទអត្ថាធិប្បាយស្ថានីយ]

[អត្ថបទ] ពួកចក្រពត្តិអាមេរិកទាំងអស់គឺមានលក្ខណៈដូចៗគ្នា ។ ចន សុន ក៏ដូចជានិច សុន និច សុន ក៏មានពុម្ពតែមួយដូចហ្នឹង ដែរ ។ ក្នុងឋានៈជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក ពួកវាតែងតែរក្សានូវគោលដៅរួមក្នុងការឈ្លានពាន និងចូលអន្តរាគមន៍ទៅក្នុងកិច្ចការប្រទេសដទៃទៀត ។ ភស្តុតាងយ៉ាងច្បាស់លាស់បញ្ជាក់បញ្ហានេះ អាចឃើញបាននៅកម្ពុជា ។ មិនត្រឹមតែច្បាប់សហរដ្ឋអាមេរិកហាមឃាត់ប្រធានាធិបតី ឬរដ្ឋការនានាធ្វើរដ្ឋប្រហារទម្លាក់របបនយោបាយនៃប្រទេសដទៃប៉ុណ្ណោះទេ ប៉ុន្តែច្បាប់នោះថែមទាំងហាមឃាត់នូវការពាក់ព័ន្ធតាមរយៈការសន្យាផងដែរ ។

ទោះជាយ៉ាងណាក៏ដោយចក្រពត្តិអាមេរិក និងប្រធានាធិបតីនៃសហរដ្ឋអាមេរិក តាមរយៈការិយាល័យរបស់ ស៊ីអាយអេ បានធ្វើរដ្ឋប្រហារនៅកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយតាមរយៈក្រសួង

ការពារជាតិរបស់ពួកវា បានដាក់ពង្រាយទាហានសហរដ្ឋអាមេរិករាប់សែននាក់ ហើយបញ្ជាទាហានសៃហ្គនរាប់សែននាក់ រួមមានទាំងជើងគោក ជើងទឹក និងជើងអាកាស ឲ្យមកឈ្លានពានកម្ពុជា ។ ច្បាប់សាធារណៈរបស់សហរដ្ឋអាមេរិកស្ដីអំពីជំនួយបរទេសឆ្នាំ១៩៧១ ចែងយ៉ាងច្បាស់ថា នៅក្នុងករណីណាក៏ដោយជំនួយនេះមិនគួរផ្សារភ្ជាប់ទៅនឹងការសន្យានានា ក្នុងបំណងទៅលើការការពារប្រទេសកម្ពុជាឡើយ ហើយចំនួនសរុបនៃបុគ្គលិកសហរដ្ឋអាមេរិកទាំងនៅក្នុងស្ថានទូត ឬទាំងកំពុងផ្ដល់ឧបករណ៍ នឹងមិនត្រូវលើសពីចំនួន២០០នាក់ ។ ច្បាប់នេះចែងបន្ថែមថា សញ្ជាតិអាមេរិកទោះជាស៊ីវិល ឬយោធា មិនត្រូវអនុញ្ញាតឲ្យធ្វើជាទីប្រឹក្សាយោធាសម្រាប់កងទ័ពលន់ នល់បានឡើយ ។ យោងតាមច្បាប់របស់ពួកវាខ្លួនឯង សហរដ្ឋអាមេរិក ត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់យន្តហោះមកទម្លាក់លើកម្ពុជា ឬធ្វើប្រតិបត្តិការដើម្បីជួយដល់ពួកលន់ នល់ឡើយ ។ ដូច្នេះហើយគឺជាបញ្ញត្តិដែលច្បាប់នោះបានចែង ។

ទោះជាយ៉ាងណាក៏ដោយ ចក្រពត្តិអាមេរិក តាំងពីនិច សុន រហូតទៅដល់រដ្ឋការហ្វត បានធ្វើមិនដឹងមិនឮចំពោះច្បាប់នេះ ។ នៅក្នុងឆ្នាំ១៩៧៣ ពួកវាបានធ្វើយុទ្ធនាការជើងអាកាសយ៉ាងឃោរឃៅនៅក្នុងឧបាយកលចង់សម្លាប់បំផុតពូជប្រជាជាតិ និងប្រជាជនកម្ពុជា ក្រោយមកពួកវាបានបន្តធ្វើអាមេរិកាំងនីយកម្ម នូវការដឹកជញ្ជូនឲ្យពួកលន នល់ ហើយបានបង្កើនចំនួនទីប្រឹក្សារក្សាសន្តិភាព បុគ្គលិកស្ថានទូត និងជំនាញការនៅកម្ពុជារហូតដល់ចំនួនជាច្រើនពាន់នាក់ ។ នៅពេលណាក៏ដោយឲ្យតែសភាអាមេរិកសួរពួកវា ពួកវាឆ្លើយកុហក ដោយនិយាយថា បុគ្គលិករបស់ពួកវាមិនមែនជាទីប្រឹក្សាយោធាឡើយ មិនមានចំនួនលើសពី២០០នាក់ដែលបានកំណត់ ... ។ ល ។ ទាំងនេះបង្ហាញច្បាស់ថា ចក្រពត្តិអាមេរិកមិនមានការគោរពចំពោះច្បាប់ ឬទស្សនៈសាធារណជនសហរដ្ឋអាមេរិកឡើយ ។

នាបច្ចុប្បន្នទង្វើនេះកាន់តែមើលឃើញច្បាស់ថែមទៀត ។ ជាការច្បាស់ណាស់ថា រដ្ឋការហ្វត-ឃីស៊ីងជ័រ គ្រប់គ្រងជាចំហ និងការពាររបបមហាក្បត់ជាតិនិងមហាពុករលួយរបស់ពួកលន់ នល់ ទីក្រុង

ភ្នំពេញ ។ នៅពេលណាដែលពួកអាយ៉ងរបស់វា កំពុងរងទុក្ខនៅដំណាក់កាលធ្ងន់ធ្ងរនៅភ្នំពេញ ពួកក្រុមហ្វូត-ឃីស៊ីងជ័រ-ស្ពេសស៊ីងជ័រ នៅទីក្រុងវ៉ាស៊ីនតោន តែងតែមានការច្រឡំវិលវល់ ហើយរងទុក្ខអន្ទះសារក្នុងលក្ខណៈត្រដររកខ្យល់ដូចគ្នា ។ ឥឡូវនេះពួកវាបានងាកទៅរកគ្រប់មធ្យោបាយ និងកិច្ចកល ដើម្បីបន្តជួយដល់អាយ៉ងរបស់ពួកវា ហើយក្នុងពេលជាមួយគ្នានោះ បានតុបតែងនិងលាបពណ៌លម្អរបបនៃជនក្បត់ទាំង៧រូប តាមរយៈការផ្លាស់ប្តូរជនក្បត់ម្នាក់ ហើយដាក់ជំនួសម្នាក់ទៀតនៅក្នុងឧបាយកលដើម្បីបំភាន់ភ្នែកនិងទស្សនៈរបស់សាធារណជន ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានទទួលបរាជ័យ ។ ពួកក្បត់នៅភ្នំពេញ នៅតែជាអាយ៉ងដដែលរបស់ចក្រពត្តិអាមេរិក ដែលគ្រប់គ្រង និងចាត់ចែងដោយពួកចក្រពត្តិអាមេរិក ។

ប្រជាជនកម្ពុជា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានប្តេជ្ញាចិត្តបន្តការវាយលុកទៅលើសត្រូវដោយគ្មានការសម្របសម្រួលឬចរចាឡើយ ។ យើងបានរំដោះរួចហើយ៩៧ភាគរយនៃផ្ទៃប្រទេសទាំងមូលរបស់យើង ។ ប្រជាជនរបស់យើង៦លាននាក់បានរំដោះរួចហើយ ហើយបានកាន់យ៉ាងរឹងមាំនូវជោគវាសនារបស់ប្រជាជាតិនៅក្នុងដៃរបស់ខ្លួនគេផ្ទាល់ ។

[00166841]

ជាមួយនឹងជ័យជម្នះទាំងនេះ ព្រមទាំងសភាពការណ៍បច្ចុប្បន្នអំណោយផលលើគ្រប់វិស័យ ប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ឥឡូវនេះកំពុងឈរជើងនៅច្រកទ្វារចូលភ្នំពេញ និងទីក្រុងផ្សេងៗទៀត ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ខ្មាំង-- និងឈានទៅមុខដោយឥតសំចៃរហូតទាល់តែពួកមហាក្បត់ជាតិលន់ នល់ សេរីមៈតៈ ស៊ឺន ង៉ុកថាញ់ ចេង

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ហេង អ៊ិន តាំ ឡុង បូរ៉េត សុស្តែន ហ្វេណង់ដេ បានវាយកម្ទេចទាំងស្រុង ហើយពួកឈ្លានពានចក្រពត្តិអាមេរិកត្រូវបោសសម្អាតបានទាំងស្រុងចេញពីប្រទេសកម្ពុជា ។ ប្រជាជន និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ប្រាកដណាស់នឹងរំដោះបានទាំងស្រុងទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀតដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង--សរុបមាន៣ភាគរយនៃដែនដីទាំងមូល--នៅក្នុងអនាគតឆាប់ៗនេះ ។

សេចក្តីអំពាវនាវចំពោះប្រជាពលរដ្ឋទីក្រុងភ្នំពេញ

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៤០០ GMT ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

[អត្ថបទ] ស្រូវ និងគ្រឿងសព្វាវុធកំពុងតែមានការខ្វះខាត ពោធិ៍ចិនតុងត្រូវបានឆាបឆេះ ហើយអាក្បត់ជាតិឡុង បូរ៉េត កំពុងតែទាល់ច្រក ។ សភាពការណ៍នៅក្នុងចំណោមពួកក្បត់នៅទីក្រុងភ្នំពេញមានលក្ខណៈច្របូកច្របល់ ។ ព្រះសង្ឃព្រះពុទ្ធសាសនា បងប្អូនជនរួមជាតិត្រូវតែងើបឈរឡើង ។

នៅថ្ងៃទី១៣ ខែមីនា កាំភ្លើងគ្រប់ប្រភេទរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាបានបាញ់ផ្លោងយ៉ាងសន្ធឹកសន្ធាប់ទៅលើមូលដ្ឋានពោធិ៍ចិនតុង ។ រថនាសម្ព័ន្ធយោធាមួយចំនួនបានត្រូវកម្ទេច ហើយឃ្លាំងដែលផ្ទុកទៅដោយសព្វាវុធ ដែលទើបតែដាក់ចូលថ្មីៗ ត្រូវបានឆាបឆេះ និងផ្ទុះ ។ យន្តហោះ មួយចំនួនបានឆាបឆេះ ឬរងការខូចខាតធ្ងន់ធ្ងរ ធ្វើឲ្យបញ្ឈប់បាននូវការដឹកជញ្ជូនសដឹកនិងផ្គត់ផ្គង់តាមយន្តហោះចក្រពត្តិអាមេរិកឈប់ដំណើរការពីព្រោះ យន្តហោះ DC-8s និង C-130s ដែលធ្លាប់ចុះចតលែងហ៊ានប្រថុយប្រថានទៀតហើយ ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

សភាពការណ៍នេះបានច្រានឱ្យសត្រូវរួមមានចក្រពត្តិអាមេរិក និងជនក្បត់ទាំង៧រូប ធ្លាក់ទៅក្នុងសភាពស្ពន់ស្ពោទាំងស្រុង ។ ឃ្លាំងស្រូវជិតអស់ស្រូវ ហើយគ្រឿងសព្វាវុធដែលកំពុងមានការខ្វះខាតរួចទៅហើយ កាន់តែខ្វះខាតឡើងថែមទៀតនាពេលបច្ចុប្បន្ន ។ ឃ្លាំងស្តុកប្រេងឥន្ធនៈក៏កាន់តែជិតអស់ ។ ផ្លូវផ្គត់ផ្គង់តាមជើងទឹក និងជើងគោកត្រូវបានកាត់ផ្តាច់ ផ្លូវអាកាសឥឡូវក៏ត្រូវបានកាត់ផ្តាច់ បុគ្គលិកនៃស្ថានទូតបរទេស អ្នកសារព័ត៌មានបរទេសបានចាកចេញយ៉ាងប្រញាប់ប្រញាល់ពីទីក្រុងភ្នំពេញ ។

សភាពការណ៍ប្រឈមចំពោះពួកក្បត់នៅទីក្រុងភ្នំពេញមានលក្ខណៈធ្ងន់ធ្ងរបំផុត ។ អាសុស្តែន ហ្វេណង់ដេ បានធ្លាក់ពីបុណ្យស័ក្តិ ហើយអ្នកមកជំនួសគាត់អាយ៉ងសាក់ ស៊ុតសាខន គ្មានអ្វីក្រៅពីជនកំសាក ។ កងទ័ពទាំងមូលរបស់ពួកក្បត់កំពុងស្ថិតនៅក្នុងភាពស្ពន់ស្ពោយ៉ាងខ្លាំង ហើយកំពុងតែត្រូវបានរុញច្រាន ។ ខណៈដែលជនក្បត់ឡុង បូរ៉េត ដែលត្រូវបានបញ្ជាដោយចក្រពត្តិអាមេរិក ឱ្យបង្កើតខុទ្ទការល័យក្បត់ជាតិថ្មីមួយ កំពុងតែទាល់ច្រក នាយទាហាន អ្នកនយោបាយ កំពុងតែប្រមូលផ្តុំការប្រឹងប្រែងរបស់ពួកគេ ដើម្បីប្រឆាំងនឹងជនជាតិក្បត់ទាំង៧រូប ។

ព្រះសង្ឃជាទីសក្ការៈ បងប្អូនជនរួមជាតិជាទីស្នេហា កម្មករជាទីស្រឡាញ់ ពលករ យុវជន សិស្សនិស្សិត គ្រូបង្រៀន និងបងប្អូននាយទាហានជាទីស្នេហា កងទ័ព អ្នករដ្ឋការ អ្នកនយោបាយ និងមន្ត្រីជាន់ខ្ពស់នៅទីក្រុងភ្នំពេញ និងនៅទីរួមខេត្តមួយចំនួនតូច ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ខ្មាំងនៅឡើយ ។

ពេលវេលាបានមកដល់ហើយ សភាពការណ៍មានសភាពអំណោយផលយ៉ាងច្រើនបំផុត ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានខិតមកជិតបងប្អូនមែនទែនហើយ បងប្អូនត្រូវតែសាមគ្គី

គ្នា បំពាក់អាវុធឲ្យខ្លួនឯងវាយប្រហារទៅលើឃ្លាំងរបស់ពួកជនក្បត់ កម្ទេចរចនាសម្ព័ន្ធយោធារបស់ពួកវា ជំរំយោធា សាលាក្រុង ទីស្នាក់ការរបស់ចៅហ្វាយខេត្ត និងកម្ទេចស្ថាប័នយោធា នយោបាយ សេដ្ឋកិច្ចទាំងអស់របស់ពួកវា ព្រមទាំងផ្តួលរំលំពួកក្បត់ជាតិទាំងនោះ ។ ធ្វើដូច្នេះ ទុក្ខលំបាករបស់បងប្អូននឹងត្រូវបានបញ្ចប់ភ្លាមៗ ហើយសន្តិភាពនឹងត្រូវបានស្តារឡើងវិញយ៉ាងឆាប់រហ័ស ។
[00166842]

## អ្នកដែលបាញ់ផ្លោងដាក់ពោធិ៍ចិនតុងបានទទួលនូវការកោតសរសើរ

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៤០០ GMT ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទ] ភាពម្ចាស់ការដ៏អស្ចារ្យថ្មីមួយនៃអង្គភាពរបស់យុទ្ធជនខ្មាន់កាំភ្លើង របស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ដែលឈរជើងនៅខ្សែត្រៀមខាងលិចទីក្រុងភ្នំពេញ ហើយដែលបានធ្វើការវាយប្រហារយ៉ាងខ្លាំងមកលើពោធិ៍ចិនតុង បានធ្វើឲ្យស្ពានចម្លងជើងអាកាសរបស់ចក្រពត្តិអាមេរិកបានកាត់ផ្តាច់ទាំងស្រុងតាំងពីថ្ងៃទី១៣ ខែមីនា!

នៅថ្ងៃទី១៣ ខែមីនា កងកម្លាំងប្រដាប់អាវុធរបស់យើងបានផ្លោងសម្រុកដាក់មូលដ្ឋានជើងអាកាសរបស់ខ្មាំងនៅឯពោធិ៍ចិនតុង ដោយប្រើគ្រាប់ផ្លោង និងរ៉ុក្កែតយ៉ាងសន្ធឹកសន្ធាប់ កម្ទេចបាននូវយន្តហោះបួនគ្រឿង រួមមានទាំងយន្តហោះ DC-8 មួយគ្រឿង និង C-130 មួយគ្រឿងរបស់ចក្រពត្តិអាមេរិក ។ គំនរគ្រឿងសព្វាវុធចំនួន៥ ផ្ទុកទៅដោយគ្រាប់រំសេវរាប់ម៉ឺនបង់បានផ្ទុះតៗគ្នា លាន់រំពងខ្លាំងអស់រយៈពេលពីម៉ោង០៩០០ ដល់ម៉ោង១៧០០ ។ ឃ្លាំងស្រូវចំនួនពីរបានត្រូវដុតបំផ្លាញ ហើយឃ្លាំងសាំងមួយបានឆាបឆេះ

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ធ្វើឲ្យអណ្តាតភ្លើងនិងផ្សែងខ្មៅហោះទៅលើមេឃអស់រយៈពេលជាង២៤ម៉ោង ។ យន្តហោះផ្សេងៗជាច្រើនទៀតបានរងការខូចខាត ហើយអ្នកបើកយន្តហោះយោធារបស់ខ្មាំងជាង១៥០នាក់ ជាងម៉ាស៊ីន និងកម្មករ ដែលបានដាក់សម្រាប់ជញ្ជូនទុកនូវគ្រឿងសព្វាវុធ ដែលយន្តហោះយកមកទម្លាក់នោះ ត្រូវបានសម្លាប់ ឬត្រូវបានរងរបួស ។ ពោធិ៍ចិនតុងដូច្នេះត្រូវបានបិទទ្វារ ។ មិនមានយន្តហោះសត្រូវណាអាចហោះឡើងបានឡើយ ហើយមិនមានយន្តហោះសហរដ្ឋអាមេរិកណាហ៊ានចុះចតឡើយ ។

នេះគឺជាជោគជ័យដ៏ភ្លឺស្វាងមួយទៀតនៃអង្គភាពយុទ្ធជនខ្នាន់កាំភ្លើងនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏អង់អាចក្លាហាន នៅលើខ្សែត្រៀមភាគខាងលិចនៃទីក្រុងភ្នំពេញ ប្រជាជនរបស់យើងទូទាំងប្រទេស ស្វាគមន៍យ៉ាងកក់ក្តៅចំពោះជ័យជម្នះរបស់ពួកគេ ហើយបានអបអរសាទរដោយអស់ពីចិត្តចំពោះពួកគេ ។ ជ័យោកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏អង់អាចក្លាហាន និងជ័យជម្នះជារៀងរហូតនៅលើសមរភូមិភាគខាងលិចនៃទីក្រុងភ្នំពេញ ។

"ការអំពាវនាវជាបន្ទាន់" ថ្ងៃ១៧ មីនា

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៤០០ GMT ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

[អត្ថបទ] ព្រះសង្ឃជាទីសក្ការៈ ជនរួមជាតិជាបងប្អូន និងជាទីស្រឡាញ់ ប្រជាជនជាបងប្អូន កម្មករ យុវជន និស្សិត គ្រូបង្រៀន នាយទាហាន ពលទាហាន នគរបាល កងអាវុធហត្ថ កងកម្មង់ដូ កងឈ្លបអ្នកនយោបាយ និងឥស្សរជនគ្រប់ប្រភេទ សមាជិកទាំងអស់ទាំងខ្ពស់ទាំងទាប នៃអង្គការចាត់តាំងទាំងអស់របស់របបពួកជនក្បត់នៅក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងជា

បណ្តោះអាសន្ននៅឡើយរបស់ខ្មាំង ៖ រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា សូមអំពាវនាវជាបន្ទាន់ដល់បងប្អូនដូចខាងក្រោម ៖

១. ពេលវេលាបានមកដល់ហើយ ដែលបងប្អូនត្រូវសាមគ្គី និងងើបឡើងផ្តួលរំលំរបបនេះ ព្រមទាំងពួកក្បត់ទាំង៧រូបតែម្តង ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាឥឡូវនេះបានឡោមព័ទ្ធ និងវាយប្រហារមកលើជនក្បត់ទាំង៧រូបមកពីគ្រប់ទិសទី ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារង់ចាំតែពេលវេលា ដើម្បីកម្ទេចពួកវាទាំងស្រុងតែប៉ុណ្ណោះ ។ ផ្លូវគោក និងផ្លូវទឹកទាំងអស់ត្រូវបានកាត់ ផ្តាច់ ។ តាំងពីថ្ងៃទី១៣ ខែមីនា ព្រលានយន្តហោះពោធិ៍ចិនតុងក៏ត្រូវបានបិទទ្វារផងដែរ ។ បណ្តាជនក្បត់មិនមានអ្វីផ្គត់ផ្គង់ សាំង ឬក៏គ្រឿងសព្វាវុធ ។
[00166843]

ប្រជាជននិងសភាសហរដ្ឋអាមេរិកបានកំពុងកាត់ផ្តាច់ជំនួយមកកាន់បណ្តាជនក្បត់ជាតិ ។ ទោះបីជាពួកចក្រពត្តិសហរដ្ឋអាមេរិកមានការចចេសរឹងរូសយ៉ាងណាក៏ដោយ ពួកគេមិនអាចជួយពួកក្បត់ លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ឲ្យផុតពីការដួលរលំបានឡើយ ។ យើងនឹងបញ្ចប់អត្ថិភាពនៃជនក្បត់ជាតិទាំង៧រូប ដើម្បីបញ្ចប់នូវទុក្ខលំបាកដែលមិនអាចរៀបរាប់បានរបស់ព្រះសង្ឃ និងប្អូនរបស់យើង ប្រជាជាតិ និងប្រជាជនរបស់យើង នឹងសម្រេចឲ្យបានសន្តិភាពភ្លាមៗនៅកម្ពុជា ។

២. ដើម្បីសម្រេចបានគោលដៅនេះ បងប្អូនត្រូវប្រើគ្រប់ទម្រង់នៃការតស៊ូដើម្បីវាយប្រហារទៅលើពួកក្បត់ជាតិចេញពីក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងៗទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំងនៅឡើយ ដូចជាធ្វើការជួបប្រជុំ ចេញសេចក្តីថ្លែងការណ៍ថ្កោលទោស និងបដិសេធពួកវា

ធ្វើកូដកម្ម ធ្វើពហិការមិនទៅសាលា ធ្វើបាតុកម្មតូចធំ ដើម្បីតវ៉ានឹងការកំណែនកងទ័ព ការអត់ឃ្លាន និងការឡើងថ្លៃទំនិញ ចលនាប្រមូលកម្លាំងដើម្បីវាយឆ្មក់ឃ្លាំងស្រូវ ឃ្លាំងសហករណ៍ ឃ្លាំងសូណិចស៊ីម [ក្រុមហ៊ុនជាតិនីហរណ អាហរណ] ឃ្លាំងសារ៉ាប៉ា [ក្រុមហ៊ុនប្រមូលស្រូវ] និងឃ្លាំងសាលាក្រុង និងសាលាខេត្ត ហើយសូម្បីតែការដណ្តើមយកនូវអាវុធរបស់ខ្មាំងដើម្បីវាយប្រហារទៅលើខ្មាំងក៏ត្រូវតែធ្វើដែរ ។ បងប្អូនដែលកាន់កាប់ប្រើកាំភ្លើង យានយន្តបំពាក់អាវុធ យន្តហោះ កាំភ្លើងតូច ឬកាំភ្លើងធំ សូមអញ្ជើញវាយប្រហារ និងកម្ទេចទីតាំងទាំងអស់ ជំរំ បន្ទាយ សាលាក្រុង សាលារដ្ឋបាលខេត្ត ទីស្នាក់ការ ការិយាល័យស្នងការ បរមរាជវាំង វីឡា ស្ថានីយវិទ្យុ ព្រមទាំងទីតាំងយោធា នយោបាយ សេដ្ឋកិច្ចទាំងអស់របស់ខ្មាំង ។ នៅពេលណាដែលបងប្អូនបានឃើញពួកជនក្បត់លន់ នល់ សេរីមៈតៈ ស៊ឹន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្ដែន ហ្វេណាង់ដេ បងប្អូនត្រូវកម្ទេចពួកវាភ្លាម ធ្វើដូច្នេះនឹងបានរួមវិភាគទានយ៉ាងធំធេងដល់ការរំដោះជាតិ និងប្រជាជនយើង ។

៣. បងប្អូនអាចនឹងធ្វើការចូលរួមសមស្របភ្លាមៗ ដោយបដិសេធមិនសហការជាមួយជនក្បត់ជាតិទាំង៧រូប ។ ក្នុងការធ្វើដូច្នេះ បងប្អូនប្រាកដជាត្រូវបានរាប់ចូលក្នុងចំណោមប្រជាជន និងរណសិរ្សរួបរួមជាតិកម្ពុជា ។ ក្នុងករណីចាំបាច់ បងប្អូនត្រូវតែឆ្លងកាត់ភ្លាមៗមកកាន់តំបន់រំដោះ ។ ប្រជាជន យុទ្ធជន និងយុទ្ធនារី ព្រមទាំងកម្មាភិបាលរបស់យើងនឹងទទួលបងប្អូនយ៉ាងកក់ក្ដៅ ។ ក្នុងពេលជាមួយគ្នានេះ យើងសូមអំពាវនាវដល់បណ្ដាមិត្តបរទេសទាំងអស់ និងស្ថានទូតបរទេស ដែលស្ថិតនៅភ្នំពេញនៅឡើយ និងនៅក្រោមការគ្រប់គ្រងរបស់ខ្មាំងជាបណ្ដោះអាសន្ននៅឡើយ ឲ្យប្រញាប់ជម្លៀសចេញដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗ ។

[00166845]

AFP រាយការណ៍ពីសកម្មភាពប្រយុទ្ធនៅសមរភូមិជិតភ្នំពេញ អ្នកលឿង

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ហុងកុង AFP ជាភាសាអង់គ្លេស ម៉ោង០៩៣០ ម៉ោងសកល GMT ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទដកស្រង់] ភ្នំពេញថ្ងៃទី១៨ មីនា (AFP) -- កងកម្លាំងខ្មែរក្រហមបានបង្កើនការដាក់សម្ពាធរបស់ពួកគេមកលើទីក្រុងភ្នំពេញ ដោយបើកមុខសមរភូមិពីរថែមទៀតមកជិតរដ្ឋធានី ដែលបានរងការវាយប្រហារយ៉ាងច្រើនហើយនោះ ។ ខ្សែប្រយុទ្ធមួយចម្ងាយតែ៧គីឡូម៉ែត្រ (៤ម៉ៃល៍) ភាគខាងកើតនៃចំណុចកណ្ដាលនៃទីក្រុងភ្នំពេញ និងមួយទៀត២៥គីឡូម៉ែត្រ (១៥ម៉ៃល៍) ភាគពាយ័ព្យ ។ នៅក្នុងខណៈជាមួយគ្នាដែរ ការប្រយុទ្ធកំពុងតែធ្វើឡើងដដែលនៅថ្ងៃនេះ នៅជិតអ្នកលឿងដែលជាមូលដ្ឋានសាឡាងទន្លេមេគង្គដ៏សំខាន់ស្ដាប់រស់មានចម្ងាយ៦០ គីឡូម៉ែត្រ (៤០ម៉ៃល៍) ភាគខាងត្បូងទីក្រុងភ្នំពេញ ហើយនៅឯភូមិជាគន្លឹះ ភូមិទួលលាប ដែលស្ថិតនៅក្នុងរយៈចម្ងាយនៃគ្រាប់ផ្លោង និងរ៉ុក្កែតនៃព្រលានយន្តហោះពោធិ៍ចិនតុង ។

ទាហានរដ្ឋាភិបាលប្រហែលបីពាន់នាក់ត្រូវបានឡោមព័ទ្ធនៅឯអ្នកលឿង ហើយរបាយការណ៍យោធាដែលបានមកដល់ទីនេះនិយាយថា ពួកគេបានក្លាយជាគោលដៅនៃការផ្លោងគ្រាប់ដាក់យ៉ាងធ្ងន់ធ្ងរដែលបណ្ដាលឲ្យ២៣នាក់ស្លាប់ ៥៦នាក់រងរបួសនៅក្នុងបរវេណទីក្រុងផ្ទាល់ ហើយនិងគ្រោះថ្នាក់ដល់ជីវិត ១៥នាក់ ផ្សេងទៀត ហើយប្រហែល១២នាក់បានរងរបួសក្នុងចំណោមកងនាវាដែលបានបោះទីតាំងនៅកោះមួយក្បែរនោះ ។

ទោះជាមានការវាយបកមកពីកងទ័ពរដ្ឋាភិបាលកាលពីម្សិលមិញក៏ដោយ ខ្មែរក្រហមបានបន្តវាយប្រហារដោយរ៉ុក្កែត១០៧មីលីម៉ែត្រទៅលើព្រលានយន្តហោះពោធិ៍ចិនតុង ចេញមកពីជំរំបាញ់កាំភ្លើងដែល

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ស្ថិតនៅជិតភូមិទួលលាប ។ កាលពីម្សិលមិញគ្រាប់រ៉ុក្កែតប្រហែលកន្លះឡូបានធ្លាក់ចំព្រលានយន្តហោះ ដែលជាខ្សែទំនាក់ទំនងតែមួយគត់របស់ទីក្រុងភ្នំពេញភ្ជាប់ទៅនឹងពិភពខាងក្រៅ ។

នៅក្នុងកំឡុងពេលយប់ និងពេលព្រឹកក្នុងថ្ងៃនេះ គ្រាប់រ៉ុក្កែតប្រហែល៣០បានហោះទម្លាក់មកខាងមូលដ្ឋាននាវាជ្រោយចង្វានៅខាងចុងជ្រោយ ដែលជាចំណុចប្រសព្វរវាងទន្លេមេគង្គ និងទន្លេសាបបែរមុខមកខាងរដ្ឋធានី ។ គ្រាប់រ៉ុក្កែតពីរផ្សេងទៀតបានធ្លាក់ចំតំបន់នៃស្ថានទូតបារាំង ។

វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាបរិយាយពិស្តារស្តីអំពីសកម្មភាពសមរភូមិប្រយុទ្ធកាលពីថ្ងៃ១២-១៦ ខែមីនា

សំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជានៃទីក្រុងភ្នំពេញ [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៧00 GMT ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

[អត្ថបទដកស្រង់] ស្តីអំពីសមរភូមិមុខទន្លេមេគង្គភាគខាងក្រោមនៃទីក្រុងភ្នំពេញ ៖

១. អ្នកលឿង ស្ថិតនៅច្រាំងខាងកើតនៃទន្លេមេគង្គ ៖ កាលពីយប់ថ្ងៃទី១៥-១៦ ខែមីនា យើងបានបើកការវាយប្រហារដោយគ្រាប់ផ្លោង និងកងថ្មើរជើងយ៉ាងច្រើនទៅលើខ្មាំង ។ យោងទៅតាមរបាយការណ៍ជាបឋម យើងបានកម្ទេចទីតាំងខ្មាំងចំនួនពីរ នៅភាគអាគ្នេយ៍នៃអ្នកលឿង ។ បន្ទាប់ពីវាយទម្លុះនូវខ្សែការពាររបស់ខ្មាំងមកពីត្រើយខាងនេះ យើងបានចូលដល់បរិវេណជិតៗជំរំកងពលតូចលេខ៤ ។ នៅត្រើយម្ខាងទៀត យើងបានចូលមកកៀកជំរំរបស់ខ្មាំង ដែលជាឃ្លាំងផ្ទុកសម្ភារៈផ្គត់ផ្គង់ ។

[00166846]

នៅក្នុងពេលជាមួយគ្នានោះ យើងបានដាក់ឲ្យមូលដ្ឋានកងនាវារបស់ខ្មាំងទទួលនូវគ្រាប់ផ្លោងយ៉ាងធ្ងន់ធ្ងរកម្ទេចបាននូវបន្ទាយយោធាជាច្រើន ។ នៅក្នុងការវាយប្រហារដោយគ្រាប់ផ្លោង និងកងថ្មើរជើងទាំងនេះ យើងបានសម្លាប់ ឬបានធ្វើឲ្យរងរបួសទាហានខ្មាំងជាង១២០នាក់ ។ យោងទៅតាមរបាយការណ៍មកពីសមរភូមិកាលពីពេលថ្មីៗនេះ ក្រោយពីបានទទួលរងការបរាជ័យយ៉ាងធ្ងន់ធ្ងរនៅឯសមរភូមិអ្នកលឿងឧត្តមសេនីយ ណុប ប៉ាវ៉ាម៉ូន ដែលជាចៅហ្វាយខេត្តស្វាយរៀង និងជាមេបញ្ជាការចម្រុះនៃអ្នកលឿង បានគេចខ្លួនទៅភ្នំពេញ ដែលជាកន្លែងគាត់កំពុងទទួលការព្យាបាលនៅឯមន្ទីរពេទ្យចំពោះជំងឺដាក់ស្មារតីចេះតែគិតថា ចាញ់របស់គាត់ ។ គាត់បានធូរស្រាលដោយសារឧត្តមសេនីយលីម ស៊ីសាអាត ។

ទោះជាយ៉ាងណាក៏ដោយឧត្តមសេនីយដ៏កំសាកនេះមិនហ៊ានត្រឡប់ទៅអ្នកលឿងវិញឡើយ ។ ទីស្នាក់ការរបស់គាត់គឺស្ថិតនៅក្នុងទីក្រុងភ្នំពេញ ។ អ្នកលឿង ដូច្នេះត្រូវបានដាក់ឲ្យនៅក្នុងភាពឯកោ ហើយត្រូវបានឡោមព័ទ្ធទាំងស្រុង ដាក់ក្រោមការវាយប្រហារយ៉ាងសន្ធឹកសន្ធាប់មកពីគ្រប់ទិសទី ។ ឥឡូវនេះមិនមានឧទ្ធម្ភាគចក្រណាអាចចុះនៅអ្នកលឿងបានទេ ហើយក៏មិនមានក្បួនកប៉ាល់ណាអាចធ្វើដំណើរពីភ្នំពេញទៅអ្នកលឿងបានដែរ ដោយសារមានគ្រាប់ផ្លោងយ៉ាងសុក្រឹត និងដាច់ខាតរបស់យើងដែលមាននៅតាមបណ្តោយផ្លូវនោះ ។

២. កំពង់ផែអ្នកលឿងត្រើយខាងលិចនៃទន្លេមេគង្គ ៖ កាលពីថ្ងៃទី១៥ ខែមីនានេះផងដែរ យើងបានដុតបំផ្លាញឲ្យធ្លាក់ដល់ដី និងរំដោះបានទាំងស្រុងនូវទីតាំងមួយជួរនៅឯចំណុចកំពង់ផែអ្នកលឿងត្រើយខាងលិច ជាលើកទី២ ។ យើងបានរំដោះប្រព័ន្ធទីតាំងនេះបានម្តងហើយកាលពីថ្ងៃទី២ មីនា និង (មិនអាចអានបាន) កងវរៈសេនាតូចលេខ២៩ និង២៥៨ នៃកងពលតូចលេខ៦៩ ដែលបានបោះទីតាំងនៅឯកំពង់ផែនោះ ។ នៅម៉ោង១៦០០ នៅថ្ងៃទី១៥ មីនា យើងកម្ទេចបានទាំងស្រុងនូវវរៈសេនាតូចទាំងពីរនេះ ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ទាហានខ្មាំងជាង៧០នាក់បានត្រូវសម្លាប់នៅនឹងកន្លែង ។ អ្នកដែលនៅរស់បានលោតទៅក្នុងទន្លេហើយលង់ទឹក ។ យើងដណ្តើមបានកាំភ្លើង១៤៧ដើម រំសេវជាង៣តោន វិទ្យុទាក់ទង៦គ្រឿង និងយានជំនិះពីរគ្រឿង ។

៣. បាណាំ ៖ យោងទៅតាមរបាយការណ៍បន្ថែមមកទៀតកាលពីយប់នៃថ្ងៃទី១២ មីនា យើងបានវាយបង្រ្កាប និងរំដោះបានទីតាំងខ្មាំងចំនួន៣ នៅខ្សែក្រវាត់ការពារភាគខាងត្បូងនៃបាណាំ ។ យើងសម្លាប់បានទាហានខ្មាំងចំនួន៣០នាក់ ដុតបំផ្លាញយានយន្តបំពាក់អាវុធមួយគ្រឿង ដណ្តើមបានកាំភ្លើង២១ដើម និងរំសេវជាង១តោន ។

៤. ស្តីអំពីទន្លេមេគង្គផ្នែកខាងលើតំបន់អ្នកលឿង ៖ យោងតាមរបាយការណ៍បន្ថែមការវាយឆ្មក់ទៅលើក្បួននាវាខ្មាំងកាលពីយប់ថ្ងៃទី១៤-១៥ ខែមីនា បានទទួលលទ្ធផលចាប់បាននាវាបីគ្រឿង ពន្លិចកប៉ាល់មួយគ្រឿង និងធ្វើឱ្យខូចខាតកប៉ាល់ពីរផ្សេងទៀត ។ ជាមួយនឹងកប៉ាល់ដែលចាប់បាន យើងក៏ចាប់យកបានផងដែរនូវកាំភ្លើងធំ១០៥មីលីម៉ែត្រមួយគ្រឿង ។ យើងក៏ចាប់យកបានផងដែរនូវគ្រាប់រំសេវជាង២០តោន និងស្រូវរាប់រយបាវ ។ យើងចាប់បានទាហានខ្មាំងចំនួន១២នាក់ និងមានទាហានខ្មាំងសរុប៣០នាក់បានស្លាប់ ឬរងរបួស ។

នៅជុំវិញទីក្រុងភ្នំពេញ ៖

១. នៅឯសមរភូមិភាគពាយ័ព្យនៃទីក្រុងភ្នំពេញ ៖ នៅឯពុទ្រា និងទួលក្រសាំង ៖ នៅថ្ងៃទី១៦ ខែមីនា យើងបានបង្រ្កាប និងរំដោះបានទាំងស្រុងទីតាំងភូមិពុទ្រា ។ វរៈសេនាតូចលេខ២០៥ ត្រូវបានវាយប្រហារ និងរុញច្រាន ។ ខ្មាំងបានទុកចោលសពទាហាន១៥នាក់ កាំភ្លើង៩ដើម និងសម្ភារៈ ព្រមទាំងគ្រាប់

រំសេវមួយចំនួន ។ ភូមិពុទ្រាមានចម្ងាយត្រឹមតែ៧គីឡូម៉ែត្រភាគខាងជើងនៃពោធិ៍ចិនតុង ។ នៅថ្ងៃទី១៦ ខែមីនា ផងដែរ នៅម៉ោង១000 យើងបានបាញ់ទម្លាក់ T-28 មួយគ្រឿងនៅម្តុំទួលក្រសាំង ដែលមានចម្ងាយ ៨គីឡូម៉ែត្រភាគខាងជើងពោធិ៍ចិនតុង ។ អ្នកបើកបរយន្តហោះត្រូវបានសម្លាប់ ។

នៅឯព្រែកព្នៅ ៖ កាលពីថ្ងៃទី១៥ ខែមីនា យើងបានសម្លាប់ទាហានខ្មាំង២៥នាក់ ធ្វើឲ្យរងរបួសជាច្រើនទៀតនៅភាគខាងលិចព្រែកព្នៅ ។ អ្នកដែលរត់ពីស្លាប់ បានរត់គេចទៅកាន់ព្រែកព្នៅ ។

២. នៅសមរភូមិភាគខាងលិចនៃភ្នំពេញ ៖ កាលពីថ្ងៃទី១៥ ខែមីនា យើងបានស្កាត់វាយឆ្មក់ និងបំបែកនូវពីរអង្គភាពរបស់កងពលតូចលេខ៨០ ដែលស្ថិតនៅភាគខាងលិចនិងនិរតីនៃស្ថានីយអាយស្មយយានសំរោង បណ្តាលឲ្យពួកវារត់ត្រឡប់ទៅស្ថានីយវិញ ។ យើងសម្លាប់បានទាហានខ្មាំង១៥នាក់ ដណ្តើមបានកាំភ្លើង៥ដើម ។ យើងបន្តឡោមព័ទ្ធស្ថានីយជុំវិញគ្រប់ទិសទី ។ នៅថ្ងៃទី១៦ ខែមីនា កងកាំភ្លើងធំរបស់យើងបានបន្តបាញ់រ៉ុក្កែត និងផ្លោងគ្រាប់ផ្លោងទៅក្នុងព្រលានយន្តហោះពោធិ៍ចិនតុង ។

[00166847]

៣. នៅសមរភូមិភាគនិរតីនៃទីក្រុងភ្នំពេញ ៖ យើងបន្តរក្សានូវការគ្រប់គ្រងយ៉ាងរឹងមាំលើផ្នែកនៃផ្លូវលេខ៤ ពីអង្គស្នួលដល់កំពង់ស្ពឺ ។ យើងក៏បានបន្តផងដែរក្នុងការធ្វើឲ្យកងពលតូចលេខ១៣ និង២៧ នៅឯកោដាច់ចេញពីមូលដ្ឋានរបស់គេនៅក្រុងកំពង់ស្ពឺ ។ ទាហានខ្មាំងចំណុះឲ្យកងពលតូចទាំងពីរនេះ បានព្យាយាមបើកការប្រតិបត្តិការ [ពាក្យមិនអាចអានបាន] ប៉ុន្តែពួកគេត្រូវបានវាយបំបាក់នៅក្នុងតំបន់នោះ ។

៤. នៅឯសមរភូមិភាគអាគ្នេយ៍នៃទីក្រុងភ្នំពេញ ៖ កាលពីយប់ថ្ងៃទី១៥-១៦ ខែមីនា យើងបានបើកការវាយប្រហារមួយខ្សែទៅលើខ្មាំងនៅលើច្រាំងទាំងពីរនៃទន្លេបាសាក់ ។ នៅច្រាំងខាងកើតយើងបានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើឫស្សីស្រុក ។ នៅត្រើយម្ខាងទៀត យើងបានបើកការវាយប្រហារទៅលើខ្មាំងចេញមកពីចំណុចកណ្តាលកោះអន្លុងចិន ។ សមរភូមិនេះស្ថិតនៅក្នុងរវាងពី៧ទៅ៨គីឡូម៉ែត្រភាគខាងអាគ្នេយ៍នៃក្រុងតាខ្មៅ ។

[00166849]

AFP ៖ កងកម្លាំងខ្មែរក្រហមកាន់ក្តាប់បានពាក់កណ្តាលនៃអ្នកលឿង

ហុងកុង AFP ជាភាសាអង់គ្លេស ម៉ោង០៤០៨ ម៉ោងសកល GMT ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទដកស្រង់] ភ្នំពេញថ្ងៃទី២០ ខែមីនា (AFP)-- កងកម្លាំងខ្មែរក្រហមបានចូលនិងកាន់ក្តាប់បានពាក់កណ្តាលនៃកំពង់ផែទន្លេមេគង្គតូចមួយនៃក្រុងអ្នកលឿង ដែលជាមូលដ្ឋានរឹងមាំជាចុងក្រោយរបស់រដ្ឋាភិបាលនៅខាងត្បូងនៃទន្លេមេគង្គ នេះបើយោងតាមរបាយការណ៍ពីប្រភពយោធាបានបញ្ជាក់កាលពីព្រឹកមិញនេះ ។ របាយការណ៍នោះ បាននិយាយថា ទាហានរដ្ឋាភិបាល២៥០០នាក់នៅអ្នកលឿងបានប្រមូលផ្តុំគ្នាឡើងវិញនៅម្តុំផ្សារ ដែលនៅជុំវិញនោះមានការប្រយុទ្ធយ៉ាងសាហាវបានធ្វើឡើងតាំងពីល្ងាចម្សិលមិញ ។ អ្នកការពារខាងរដ្ឋាភិបាលត្រូវបានគេរាយការណ៍ថា បានទទួលរងនូវការខូចខាតដ៏ធ្ងន់ធ្ងរ ។

អ្នកលឿងត្រូវឡោមព័ទ្ធបានអស់រយៈពេលជាងមួយខែមកហើយ ហើយក្នុងអំឡុងពេលពីរបីថ្ងៃចុងក្រោយនេះ ការបាញ់គ្រាប់ផ្លោង និងការវាយប្រហារយ៉ាងច្រើនទៅលើក្រុងនោះ ធ្វើឲ្យទ័ពការពារទីនោះ

ស្មើរតែស្លាប់ខ្លួនចល័តលែងកើត ។ ការវាយប្រហារទាំងនោះបានបង្កធ្វើឲ្យកាន់តែលំបាកដល់ការផ្គត់ផ្គង់តាមរយៈឆ័ត្រយោងទៅដល់ទីក្រុងនេះ ។

[00166850]

លន់ នល់ ប្រកាសខុទ្ទកាល័យថ្មី ថ្ងៃទី២១ មីនា

ភ្នំពេញ សេវាផ្សាយក្នុងស្រុងជាភាសាខ្មែរ ម៉ោង១០៣៨ ជាម៉ោងសកល GMT ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទនៃបទបញ្ជាប្រធានាធិបតីចុះថ្ងៃទី២១ មីនា--អានដោយអ្នកផ្សាយព័ត៌មាន]

[អត្ថបទ] យោងតាមអនុក្រឹតលេខ ១៣៩-៧៥ PRK ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៥ ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ--ដោយបានឃើញនូវរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ និងអនុក្រឹតលេខ ៤៧៤-៧៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៤ ធ្វើវិសោធនកម្មតាមមាត្រាបន្តបន្ទាប់ខាងក្រោមនេះ ស្តីអំពីការតែងតាំងខុទ្ទការល័យរដ្ឋមន្ត្រី--ចេញបញ្ជាដូចតទៅ៖

១. ខុទ្ទការល័យរដ្ឋមន្ត្រីដែលត្រូវបានតែងតាំងអនុលោមតាមអនុក្រឹតលេខ ៤៧៤-៧៤ PRK ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៤ និងបានធ្វើវិសោធនកម្មដោយមាត្រាបន្តបន្ទាប់ដូចខាងក្រោម ត្រូវតែផ្លាស់ប្តូរសមាសភាពដូចខាងក្រោម ៖

នាយករដ្ឋមន្ត្រី ៖ ឡុង បូរ៉េត

ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការនយោបាយ និងបេសកម្មពិសេស៖ ហាង់ ធុនហាក់

ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការពារជាតិ ៖ ឧត្តមសេនីយត្រី សាក់ ស៊ុតសាខន

ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកអប់រំ និងទំនាក់ទំនងសភា ៖ ប៉ាន់ សុធី

ទេសរដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យនាយករដ្ឋមន្ត្រី មហាផ្ទៃ ចលនាទូទៅ និងកិច្ចការសាសនា ៖ គូ គង់

ទេសរដ្ឋមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ផែនការ និងផលិតផល ៖ ឃី តាំងលឹម

ទេសរដ្ឋមន្ត្រីទទួលបន្ទុកសាធារណការ និងពាណិជ្ជកម្ម ៖ ហែម កេតសាណា

រដ្ឋមន្ត្រីការបរទេស ៖ គីគី លឹម

រដ្ឋមន្ត្រីឯកភាពជាតិ ៖ គៀម រ៉េត

រដ្ឋមន្ត្រីទទួលបន្ទុកជនភៀសខ្លួន សំណង់ និងអភិវឌ្ឍសហគមន៍៖ គង់ អន

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៖ លី ខ្វាន់ប៉ាន

រដ្ឋមន្ត្រីសុខាភិបាលសាធារណៈ ៖ លឿង ណាល់

រដ្ឋមន្ត្រីទទួលបន្ទុកដឹកជញ្ជូននិងផ្គត់ផ្គង់ ៖ អ៊ាវ យ៉ាង

រដ្ឋមន្ត្រីឧស្សាហកម្ម និងទេសចរណ៍ ៖ ជីវ ស៊ាងលៀន

រដ្ឋមន្ត្រីព័ត៌មាន ប្រៃសនីយ និងទូរគមនាគម ៖ ថោង លឹមហ្វុង

រដ្ឋមន្ត្រីសន្តិសុខជាតិ ៖ វ៉ាន់ ស

រដ្ឋលេខាធិការទទួលបន្ទុកសង្គមកិច្ច និងការងារ ៖ ងួន ជាន

រដ្ឋលេខាធិការទទួលបន្ទុកពាណិជ្ជកម្ម ៖ តាំង សារ៉េត

រដ្ឋលេខាធិការទទួលបន្ទុកកសិកម្ម ៖ អ៊ុំង ស៊ីយុន

២. សកម្មភាពនានារបស់ខុទ្ទការល័យរដ្ឋមន្ត្រីនេះ ត្រូវចាត់ផ្ដាក់ទៅក្នុង៥ក្រុម ទៅតាមគោលបំណងដែលត្រូវសម្រេចឲ្យបានដោយរដ្ឋាភិបាល ៖

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ក្រុមទី១ ៖ ចលនាទូទៅ និងគោលនយោបាយ ។ ក្រុមនេះធ្វើគោលនយោបាយសម្រាប់បណ្ដាក្រសួងមហាផ្ទៃ កិច្ចការសាសនា ការបរទេស ឯកភាពជាតិ ព័ត៌មាន ប្រៃសនីយ និងទូរគមនាគមន៍ ព្រមទាំងសន្តិសុខជាតិ ។

ក្រុមទី២ ៖ ការពារជាតិ និងយុត្តិធម៌ ។ ក្រុមនេះរួមមានក្រសួងការពារជាតិ យុត្តិធម៌ និងសន្តិសុខជាតិ ។

ក្រុមទី៣ ៖ សង្គមកិច្ច វប្បធម៌ និងយុវជន ។ ក្រុមនេះរួមមានក្រសួងអប់រំ វប្បធម៌ ជនភៀសខ្លួន សំណង់ អភិវឌ្ឍសហគមន៍ សុខាភិបាល ការងារ និងសង្គមកិច្ច ។

[00166851]

ក្រុមទី៤ ៖ ហិរញ្ញវត្ថុ ផែនការ និងផលិតកម្ម ។ ក្រុមនេះរួមមានក្រសួងហិរញ្ញវត្ថុ ផែនការ ឧស្សាហកម្ម កសិកម្ម និងទេសចរណ៍ ។

ក្រុមទី៥ ៖ ផ្គត់ផ្គង់ ដឹកជញ្ជូន និងសាធារណការ ។ ក្រុមនេះរួមមានក្រសួងសាធារណការ ផ្គត់ផ្គង់ ដឹកជញ្ជូន និងពាណិជ្ជកម្ម ។

៣. ឧត្តមសេនីយត្រី សាក់ ស៊ុតសាខន កាន់មុខនាទីជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិបន្ថែមទៅលើតួនាទីជាប្រធាននៃអគ្គសេនាធិការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា ។

៤. ប្រធានខុទ្ទការល័យនៃប្រធានាធិបតី និងអគ្គលេខាធិការនៃរដ្ឋាភិបាល ត្រូវទទួលខុសត្រូវអនុវត្ត ជាបន្ទាន់នូវអនុក្រឹតនេះ ។

ភ្នំពេញថ្ងៃទី២១ មីនា ឆ្នាំ១៩៧៥

[បានចុះហត្ថលេខា] លន់ នល់

AFP ទាហានរដ្ឋាភិបាលដកចេញពីទួលលាប

ហុងកុង AFP ជាភាសាអង់គ្លេស ម៉ោង ១៤៥៦ GMT ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

[អត្ថបទដកស្រង់] ភ្នំពេញថ្ងៃទី២០ ខែមីនា (AFP)--ទាហានរដ្ឋាភិបាលកម្ពុជាថ្ងៃនេះបានបោះបង់ចោលនូវទីតាំងឈរជើងជាគន្លឹះ ទួលលាប ដែលស្ថិតនៅជិតព្រលានយន្តហោះភ្នំពេញ ដែលបានប្រើដោយខ្មែរក្រហមគាំទ្រដោយកុម្មុយនីស្ត ធ្វើជាមូលដ្ឋានសម្រាប់បាញ់ផ្លោងដាក់ព្រលានយន្តហោះ រហូតដល់ពេលថ្ងៃសៅរ៍មុន ដែលបានដណ្តើមយកមកវិញ នេះបើយោងតាមប្រភពយោធាបានរាយការណ៍ ។

[00166864]

អបអរសាទរដល់យុទ្ធជនគ្រប់រូបនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៤០០ ម៉ោងសកល GMT ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ បាងកង (BK)

["សារអបអរសាទរ" ចុះថ្ងៃទី២៣ មីនា របស់ខៀវ សំផន ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គបញ្ជាការកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា--អានដោយអ្នកអានសារព័ត៌មាន]

[អត្ថបទ] មិត្តភក្តិទាំងអស់ជាទីគោរពដែលនៅគ្រប់ជាន់ថ្នាក់នៃការដឹកនាំបញ្ជា កម្មាភិបាលជាទីស្នេហា យុទ្ធជន យុទ្ធនារីទាំងបីផ្នែកនៃកងកម្លាំងរំដោះជាតិប្រជាជនកម្ពុជា ដែលនៅគ្រប់សមរភូមិទូទាំងប្រទេស ៖ មហាចលនាវាយសម្រុកអស្ចារ្យរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនរបស់យើង នៅក្នុងរដូវប្រាំងឆ្នាំ១៩៧៥ មកដល់ពេលនេះមានអាយុ២ខែ២៣ថ្ងៃហើយ ។ នៅក្នុងអំឡុងពេលនេះ បងប្អូនទាំងអស់ មិត្តភក្តិជាទីស្រឡាញ់ រួមទាំងអ្នកដែលកាន់នាទីជាមេដឹកនាំ ជាបញ្ជាការគ្រប់លំដាប់ថ្នាក់ កម្មាភិបាល យុទ្ធជន យុទ្ធនារីទាំងបីផ្នែកនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានវាយប្រហារយ៉ាងខ្លាំងបំផុតទៅលើខ្មាំងនៅលើសមរភូមិជាយុទ្ធសាស្ត្រទាំងបី ពោលគឺទន្លេមេគង្គ ផ្លូវគមនាគមន៍ផ្សេងៗទៀត ភ្នំពេញ និងជាយក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងៗ ។

នៅក្នុងរយៈពេលដ៏ខ្លីនេះ បងប្អូនបានកម្ទេចនូវទីតាំង និងទាហានរបស់ខ្មាំងបានយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ពីខែមករាមកដល់ពាក់កណ្ដាលខែមីនា ទាហានខ្មាំងជាង៤៦,៥០០នាក់ បានត្រូវសម្លាប់ រងរបួស ចាប់បាន ឬចុះចូល ។ ទីតាំងឈរជើងរបស់ខ្មាំងជាង៨០០ទីតាំងទាំងតូចទាំងធំ ត្រូវបានបង្ក្រាប និងរំដោះបាន ។ ទន្លេមេគង្គផ្នែកខាងក្រោមទីក្រុងភ្នំពេញត្រូវរំដោះបាន ហើយកំណាត់ផ្នែកចាប់ពីទីក្រុងភ្នំពេញដល់ព្រំប្រទល់វៀតណាមខាងត្បូង ត្រូវបានកាន់ក្ដាប់យ៉ាងណែននៅក្នុងដៃរបស់កងកម្លាំងប្រដាប់

អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ។ ផ្ទៃដីប្រវែងជាង៣០គីឡូម៉ែត្រនៃផ្លូវលេខ១ និងទីតាំងខ្មាំងចំនួន២៥៣ទីតាំងជុំវិញទីក្រុងភ្នំពេញក៏ត្រូវរំដោះបានផងដែរ ។

យើងកំពុងបន្តបើកការវាយប្រហារយ៉ាងខ្លាំងក្លាទៅលើខ្មាំង ដើម្បីដណ្តើមយកតំបន់ទល់មុខភ្នំពេញនៅត្រើយខាងកើតទន្លេមេគង្គបន្ទាប់ពីបានកម្ទេច និងរំដោះរួចហើយនូវទីតាំងខ្មាំងជាច្រើនចាប់ពីព្រែកឆ្លៅដល់ព្រែកតាម៉ាក់ ។ យើងកំពុងធ្វើការវាយប្រហារទៅលើខ្មាំងមកពីភាគពិ្លសាន និងភាគឧត្តរនៅជិតព្រែកលាប ជ្រោយចង្វា និងគីឡូម៉ែត្រលេខ៦ ។ មកពីទិសខាងលិច យើងបានខិតចូលជិតពោធិ៍ចិនតុង ។ មកពីទិសនិរតីយើងបន្តធ្វើការវាយប្រហារនិងបោសសម្អាតខ្មាំងលើផ្លូវលេខ៤ និង៣៨ ។ នៅផ្ទៃអាគ្នេយ៍យើងបានចូលជិតដល់ក្រុងតាខ្មៅ និងកំពុងបន្តបោសសម្អាតខ្មាំងនៅម្តុំជុំវិញដីឥដ្ឋ និងតំបន់ចន្លោះពីដីឥដ្ឋដល់កៀនស្វាយ ។

នៅគ្រប់សមរភូមិទីរួមខេត្តផ្សេងៗ បងប្អូនក៏បានវាយប្រហារយ៉ាងខ្លាំងក្លាទៅលើខ្មាំង រំដោះបានទីតាំងរាប់រយ រួមមានទាំងទីរួមខេត្តឧដុង្គ និងទីរួមស្រុកមួយចំនួន ដូចជាមោង គាស់ក្រឡ កំពង់លែង រលាប្អៀរ អនុខេត្តបន្ទាយស្លារ អនុខេត្តថ្មពួក ។ ល ។

[00166865]

ផ្ទៃដីនៃតំបន់រំដោះរបស់យើងបានរីកកាន់តែធំឡើងៗ ។ គិតមកត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៥ តំបន់រំដោះរបស់យើងមានផ្ទៃដីស្មើនឹង៩៧ភាគរយ នៃដែនដីកម្ពុជាទាំងមូល ហើយប្រជាជនយើងចំនួន៦លាននាក់ត្រូវបានរំដោះទាំងស្រុង ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ចំពោះខ្មាំងវាកំពុងបរាជ័យ ហើយកំពុងតែស្ថិតនៅឯកោជាងពីមុនថែមទៀត ។ គ្រប់កងពលរបស់ពួកវាទាំងអស់ត្រូវបានរុញច្រាន ឬកម្ទេចម្តងមួយៗដោយសារស្នាដៃរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ។ ស្មារតី ចំនួន យុទ្ធសាស្ត្រ វិធីសាស្ត្រប្រយុទ្ធ ការចាត់តាំង និងបញ្ជាការកម្លាំងប្រដាប់អាវុធខ្មាំងកំពុងតែដួលរលំ ។ សុស្តែន ហ្វេណង់ដេ អគ្គបញ្ជាការក្បត់ជាតិ និងជាប្រធានអគ្គសេនាធិការ កំពុងតែធ្លាក់ពីតំណែងយ៉ាងអាម៉ាស់ធ្ងន់ធ្ងរ ខណៈដែលរដ្ឋាភិបាលឡុង បូរ៉េត បានត្រូវបែកបាក់ ។ ខ្មាំងកំពុងជួបប្រទះនូវការខ្វះខាតកម្លាំងមនុស្ស និងស្បៀងអាហារ ហើយក៏កំពុងខ្វះខាតគ្រឿងសព្វាវុធ ។ យើងបានបិទស្ទើរតែគ្រប់ផ្លូវដឹកជញ្ជូនរបស់ខ្មាំង ។ ទន្លេមេគង្គត្រូវបានបិទ ។ ផ្លូវគោកទាំងអស់ត្រូវបានកាត់ផ្តាច់ ហើយពោធិ៍ចិនតុងបានទទួលរងនូវការវាយប្រហារដោយគ្រាប់ផ្លោងរបស់យើងជាប់ជានិច្ច ។ នៅភ្នំពេញ និងតំបន់ដែលគ្រប់គ្រងដោយខ្មាំងជាបណ្តោះអាសន្ន ប្រជាជន កម្មករ យុវជននិស្សិត គ្រូបង្រៀន អ្នករដ្ឋការ និងទាហាន កំពុងក្រោកឈរឡើងធ្វើកុបកម្ម និងក្រោកតស៊ូយ៉ាងក្តៀវក្លាប្រឆាំងនឹងជនក្បត់ទាំង៧រូប លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ។

សមមិត្ត មេបញ្ជាការ កម្មាភិបាល យុទ្ធជនទាំងបីផ្នែកនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជានៅគ្រប់សមរភូមិទូទាំងប្រទេសជាទីស្នេហា ៖

ប្រជាជនយើងទូទាំងប្រទេស បណ្តាប្រជាជនជាមិត្តទាំងជិតទាំងឆ្ងាយ ពាសពេញពិភពលោកមានសេចក្តីរំភើបរីករាយក្រៃលែងចំពោះជ័យជម្នះដ៏អស្ចារ្យនេះ ដែលទទួលបានដោយកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនយើង ។ ជ័យជម្នះនេះមានខ្លឹមសារសំខាន់បំផុត ហើយមានទស្សនៈវិស័យល្អឥតខ្ចោះ ។ កងកម្លាំងបដិវត្តរបស់យើងគ្រប់អង្គភាព បានកើនឡើងទាំងចំនួន ទាំងគុណភាពបង្កើតបានជាលក្ខខណ្ឌអំណោយផល សម្រាប់យើងបន្តឈានជើងទៅមុខកាន់តែខ្លាំងឡើង និងសម្រេចបាន

ជ័យជម្នះកាន់តែច្រើនឡើងៗឈានទៅសម្រេចគោលដៅចុងក្រោយ នៃការរំដោះបានទាំងស្រុងនៃប្រជាជាតិ និងប្រជាជនយើង ។

សមមិត្តទាំងអស់ជាទីស្នេហា ៖ បទពិសោធន៍ទាំងឡាយដែលរៀនសូត្របាននៅក្នុងដំណាក់កាលដំបូងនៃការវាយលុករដូវប្រាំងឆ្នាំ១៩៧៥នេះ បានបង្ហាញយ៉ាងច្បាស់លាស់ និងយ៉ាងភ្លឺស្វាងនូវភាពត្រឹមត្រូវនៃមាគ៌ាដឹកនាំដ៏ត្រឹមត្រូវរបស់យើងទាំងអស់ រួមមានទាំងជំហរនៃការតស៊ូដាច់ខាត បូរណភាពដែនដី និងការច្នៃប្រឌិតនៅក្នុងការប្រយុទ្ធ និងសាមគ្គីភាពយ៉ាងរឹងមាំ និងសាមគ្គីភាពក្នុងចំណោមអង្គភាពទាំងអស់ បណ្តាសមរភូមិ និងគ្រប់លំដាប់ថ្នាក់នៃការបញ្ជា កម្មាភិបាល យុទ្ធជន យុទ្ធនារី និងរវាងសមរភូមិមុខ និងសមរភូមិក្រោយ ដែលបានប្តេជ្ញាចិត្តអនុវត្តគ្រប់ពាក្យស្លោករបស់យើង ហើយគាំទ្រដោយគ្មានលក្ខខណ្ឌទៅដល់សមរភូមិមុខ ។ ចំណេះដឹងបន្ថែមជាពិសេសដែលយើងបានរៀនសូត្រចេញមកពីដំណាក់កាលនៃការវាយលុករដូវប្រាំងនេះ គឺថា ឃើញមាននូវការដឹកនាំដ៏ជិតដិត និងមានប្រសិទ្ធភាពនៃបញ្ជាការ និងសមរភូមិ ។

មិត្តភក្តិទាំងអស់ជាទីស្នេហា ៖ ចក្រពត្តិអាមេរិក ចចេស និងឃោរឃៅជាទីបំផុត ។ ទោះជាជនក្បត់ទាំង៧រូប--ដែលជាអាយ៉ងពួកវា--កំពុងតែជិតដួលរលំ ហើយពួកវាដឹងថា មិនមានវិធីណាអាចសង្គ្រោះពួកអាយ៉ងនោះបានក៏ដោយ ក៏ចក្រពត្តិអាមេរិកនៅតែចចេសបន្តអនុវត្តគ្រប់ឧបាយកលដ៏អាក្រក់ ។

ជាប្រពៃណី ប្រជាជន យុទ្ធជន យុទ្ធនារី កម្មាភិបាល បានប្រកាន់ខ្ជាប់នូវជំហរប្រុងប្រយ័ត្នបដិវត្តខ្ពស់ប្រឆាំងនឹងឧបាយកលខ្មាំងទាំងអស់ ហើយក្នុងពេលជាមួយគ្នានោះបានប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវពាក្យស្លោកបដិវត្តរបស់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងនោះគឺ "កាលណាយើងកាន់តែឈ្នះច្រើន យើងកាន់តែមានការគួរសមខិនលំទោន" ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

មិត្តភក្តិរបស់យើងទាំងអស់នៅសមរភូមិទាំងបីជាយុទ្ធសាស្ត្រ ទន្លេមេគង្គ ភ្នំពេញ និងជាយភ្នំពេញ និងទីរួមខេត្តផ្សេងៗ--ប្រាកដណាស់នឹងបន្តប្រកាន់ខ្ជាប់នូវជំហរទាំងនេះ ហើយដូច្នេះនឹងក្លាយទៅជាកម្លាំងប្រយុទ្ធយ៉ាងខ្លាំងបំផុតទៅលើខ្មាំងរហូតដល់កម្ពុជាបានត្រូវរំដោះ១០០ភាគរយ ។

[00166866]

ជាមួយនឹងស្មារតីនេះ និងមនោសញ្ចេតនាភាវតភាពបដិវត្តយ៉ាងជ្រាលជ្រៅទាំងនេះ តាងនាមឲ្យប្រជាជាតិ និងប្រជាជនកម្ពុជា កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ខ្ញុំសូមផ្ញើជូនដល់បងប្អូនទាំងអស់នូវការអបអរសាទរយ៉ាងកក់ក្តៅ និងការជូនពរដ៏វិសេសវិសាលពីខ្ញុំ ។ ខ្ញុំសូមជូនពរឲ្យមានសុខភាពល្អ កម្លាំងមាំមួន និងជ័យជម្នះថ្មីៗកាន់តែច្រើនថែមទៀត ។ ក្នុងពេលជាមួយគ្នានេះ ខ្ញុំសូមលំឱនកាយឧទ្ទិសគោរពដល់វិញ្ញាណក្ខន្ធរបស់មិត្តភក្តិយើងដែលបានពលីជីវិតដ៏មានតម្លៃសម្រាប់បុព្វហេតុរំដោះជាតិប្រជាជនយើង ។ ខ្ញុំសូមជូនពរឲ្យមិត្តភក្តិទាំងអស់ដែលរងរបួសឆាប់ជាសះស្បើយ ដើម្បីបន្តបំពេញឲ្យបានជោគជ័យនូវភារកិច្ចបដិវត្តរបស់ពួកគាត់ទាំងអស់ ។

យើងប្រាកដជានឹងរំដោះបានទីក្រុងភ្នំពេញ១០០ភាគរយ!

តំបន់រំដោះកម្ពុជា ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ [បានចុះហត្ថលេខា] ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងអគ្គបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166867]

ឡុង បូរ៉េត ៖ ត្រៀមខ្លួនជាស្រេចសម្រាប់ "ធ្វើការលះបង់ណាមួយ" ដើម្បីសន្តិភាពតាមរយៈការចរចា

ហុងកុង AFP ជាភាសាអង់គ្លេស ម៉ោង១៥០៣ ម៉ោងសកល GMT ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទដកស្រង់] ភ្នំពេញថ្ងៃទី២៤ ខែមីនា (AFP)--នាយករដ្ឋមន្ត្រីកម្ពុជា ឡុង បូរ៉េត ថ្ងៃនេះបានប្រកាសថា រដ្ឋាភិបាលដែលកំពុងជួបបញ្ហារបស់លោកបាន "ត្រៀមខ្លួនជាស្រេចដើម្បីធ្វើពលីកម្មណាមួយដែលតម្រូវឲ្យយើងធ្វើ ដើម្បីផលប្រយោជន៍នៃសន្តិភាពមួយតាមរយៈការចរចា" ខណៈពេលដែលលោកបានធ្វើបទបង្ហាញពីខុទ្ទកាល័យថ្មីរបស់គាត់ទៅចំពោះមុខរដ្ឋសភាកម្ពុជា ។

លោកបានបន្ថែមទៀតថា រដ្ឋាភិបាលជឿជាក់ថា "រវាងខ្មែរនិងខ្មែរ" យើងអាចឈានដល់ការយោគយល់មួយ (ជាមួយនឹងទ័ពព្រៃខ្មែរក្រហម ដែលគាំទ្រដោយកុម្មុយនីស្ត) ដើម្បីឲ្យកងទ័ពយើងធ្វើការទម្លាក់អាវុធ និងដោះស្រាយនូវចំណុចខ្វែងគ្នា ដែលបំបែកពួកយើង តាមរយៈមធ្យោបាយនយោបាយដោយសន្តិវិធី ។

បណ្ដាអ្នកសង្កេតការណ៍នៅទីនេះកត់សម្គាល់ថា ខ្លឹមសារគោលនៃការធ្វើពលីកម្ម គឺជាខ្លឹមសារមួយដែលតែងតែលើកឡើងជាញឹកញាប់នៅក្នុងពេលពិភាក្សា អំពីការលាលែងតំណែងនាពេលណាមួយខាងមុខរបស់សេនាប្រមុខលន់ នល់ ដែលជាប្រធានាធិបតីកម្ពុជា ឈរនៅលំដាប់កំពូលនៃបញ្ជីមេដឹកនាំកម្ពុ

ជា ដែលខ្មែរក្រហមឥឡូវនេះកំពុងជាប់ដៃវាយលុកមកលើទីក្រុងបានប្តេជ្ញាចិត្តរួចទៅហើយថា នឹងសម្លាប់ ។

ពួកកុម្មុយនីស្តបានខិតជិតមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង

ហុងកុង (AFP) ជាភាសាអង់គ្លេសម៉ោង ១៣០៨ ម៉ោងសកល GMT ថ្ងៃទី២៤ មីនា ១៩៧៥ បាងកង (BK)

[អត្ថបទដកស្រង់] ភ្នំពេញ ថ្ងៃទី២៤ មីនា ១៩៧៥ (AFP)--ខ្មែរក្រហមគាំទ្រដោយកុម្មុយនីស្តថ្ងៃនេះបានវាយទម្លុះខ្សែការពាររបស់រដ្ឋាភិបាល ធ្វើឲ្យមានសម្ពាធខិតកាន់តែជិតមកព្រលានយន្តហោះពោធិ៍ចិនតុង រដ្ឋធានីកម្ពុជា ដែលរងការវាយប្រហារ របស់កម្ពុជា ដែលជាខ្សែតភ្ជាប់ចុងក្រោយជាមួយនឹងពិភពលោកខាងក្រៅ នេះបើយោងតាមប្រភពនានារបស់ខាងយោធានៅឯសមរភូមិបានរាយការណ៍ ។

កម្លាំងខ្មែរបានដាក់វានៅចម្ងាយពីរគីឡូម៉ែត្រ (ជាងមួយម៉ៃល៍) ជិតទៅខាងព្រលានយន្តហោះ ដែលបានស្ថិតនៅក្នុងរយៈចម្ងាយនៃការបាញ់រ៉ុក្កែត និងគ្រាប់ផ្លោងរបស់ខ្មែរក្រហម ។

ប្រភពនោះបាននិយាយថា មេដឹកនាំកម្លាំងរដ្ឋាភិបាលដែលនៅមូលដ្ឋាន ឧត្តមសេនីយ ចន្ទរង្សី ត្រូវបានដកភ្លាមៗចេញពីតំណែងបញ្ជាការ ។ ឧត្តមសេនីយរូបនេះ គឺជាពូរបស់មេដឹកនាំខ្មែរក្រហម នរោត្តម សីហនុ ដែលជាអតីតអ្នកដឹកនាំប្រទេសកម្ពុជា ។

ខ្មែរក្រហមបានបំបែកយកបាននៅម្តុំទួលលាប ដែលពីមុនជាទីតាំងគន្លឹះនៃខ្សែការពារព្រលានយន្តហោះដែលមានចម្ងាយ១០គីឡូម៉ែត្រ (៦ម៉ៃល៍) ភាគពាយ័ព្យនៃផ្លូវយន្តហោះរត់ ដែលឧត្តមសនីយចន្ទរង្សី និងទាហានរបស់គាត់បានប្រយុទ្ធកន្លងមកដើម្បីដណ្តើមយកទៅវិញ ។

ប្រភពនានាមកពីខាងយោធាបាននិយាយថា មូលដ្ឋានបាញ់គ្រាប់រ៉ុក្កែតនៅឯទួលលាបបានត្រូវការពារបានយ៉ាងរឹងមាំ ហើយបរិវេណនោះត្រូវបានវាយគ្រាប់មីនយ៉ាងក្រាស់ ដែលធ្វើឲ្យមានការលំបាកក្នុងការដណ្តើមយកទីនោះ ។ ទាហានរដ្ឋាភិបាល ដែលប្រតិបត្តិការនៅភាគខាងជើងផ្លូវជាតិលេខ៤បានដកថយថ្ងៃនេះចេញពីទីតាំងដែលគេដណ្តើមបានក្នុងការប្រយុទ្ធកាលពីម្សិលមិញ ។

[00166868]

ពិធីនេះត្រូវបានឧបនាយករដ្ឋមន្ត្រីខៀវ សំផន ធ្វើជាអធិបតី និងចូលរួមដោយរដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រីជាច្រើនរូប ។ ពិធីនេះចាប់ផ្តើមនៅម៉ោង០៨០០ ។ ជាមួយនឹងការទះដៃអបអរសាទរយ៉ាងលាន់រំពង ខៀវ សំផន បានធ្វើសុន្ទរកថា ដោយមានខ្លឹមសារសរុបឡើងវិញនូវជ័យជម្នះដ៏មានខ្លឹមសារប្រវត្តិសាស្ត្រនិងមហាអស្ចារ្យ ដែលទទួលបានដោយរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិ កម្ពុជា នៅក្នុងកំឡុងពេល៥ឆ្នាំកន្លងទៅ ទាំងនៅលើសមរភូមិមុខ ទាំងនៅលើសមរភូមិក្រោយ ព្រមទាំងខាងក្នុង និងខាងក្រៅប្រទេស ។ នៅពេលជាមួយគ្នានោះ លោកបានធ្វើសេចក្តីរាយការណ៍អំពីចលនាវាយលុកដ៏អស្ចារ្យប្រឆាំងនឹងខ្មាំងនៅក្នុងកំឡុងពេលរដូវប្រាំងនេះ ដែលនៅក្នុងនោះកងកម្លាំងប្រដាប់អាវុធ និងប្រជាជនយើងបានប្រយុទ្ធ និងកម្ទេចខ្មាំងដោយប្តេជ្ញាចិត្តត្រូវប្រយុទ្ធ និងយកឈ្នះដោយមិនសម្រុះសម្រួល ឬដកថយ ។ ស្របទៅតាមសេចក្តីប្រកាសនៃមហាសន្និបាតជាតិលើកទី២ ឧបនាយករដ្ឋមន្ត្រីខៀវ សំផន ក៏បានអំពាវនាវផងដែរដល់កងកម្លាំងប្រដាប់អាវុធ និងប្រជាជនយើងទាំងអស់គ្នា ឲ្យបន្តធ្វើការវាយ

លុកឲ្យបានខ្លាំងក្លាទៅលើខ្មាំង ដោយប្រកាន់ខ្ជាប់នូវស្មារតីទទួលខុសត្រូវនិងប្រុងប្រយ័ត្នបដិវត្តប្រឆាំងគ្រប់ឧបាយកលខ្មាំងទាំងអស់ ។

សរុបមកឧបនាយករដ្ឋមន្ត្រីបានសម្តែងនូវការជូនពរសព្វសាធុការដល់សម្តេចនរោត្តម សីហនុ ប្រមុខរដ្ឋ និងជាប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា សម្តេចប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រះសង្ឃគ្រប់អង្គ កម្មាភិបាល និងយុទ្ធជននៃផ្នែកទាំងបីនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ព្រមទាំងជនរួមជាតិរបស់យើងទាំងអស់ ដែលនៅក្នុងតំបន់រំដោះ ក៏ដូចជាតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មាំងនៅឡើយជាបណ្តោះអាសន្ន និងនៅក្នុងប្រទេស និងក្រៅប្រទេស ។ គាត់ជូនពរឲ្យពួកគេមានសុខភាពល្អ កម្លាំងមាំមួន និងជ័យជម្នះកាន់តែច្រើនថែមទៀតនៅក្នុងភារកិច្ចបដិវត្តរំដោះប្រជាជាតិ និងប្រជាជនរបស់យើង ។ គាត់ក៏បានសម្តែងផងដែរនូវការអំណរគុណ ដល់បណ្តាប្រជាជនទាំងអស់ រដ្ឋាភិបាល និងបណ្តាប្រទេសជាមិត្តទាំងជិតទាំងឆ្ងាយ និងជូនចំពោះប្រជាជនដែលស្រឡាញ់សន្តិភាពនៅលើពិភពលោក រួមមានទាំងប្រជាជនអាមេរិកខាងចម្រើននិយមផង ដែលបានផ្តល់ការគាំទ្រ និងជំនួយឥតឈប់ឈររបស់ពួកគេដល់ប្រជាជនកម្ពុជា នៅក្នុងមូលហេតុដ៏ត្រឹមត្រូវរបស់ពួកគេប្រឆាំងនឹងចក្រពត្តិអាមេរិក និងអាយ៉ងរបស់ពួកវា--លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ។

ក្រោយមកតំណាងនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ក្រសួង និងមន្ទីរបដិវត្តនិងអង្គការចាត់តាំងមហាជនស្នេហាជាតិផ្សេងៗ បានឡើងថ្លែងនូវទស្សនៈរបស់ពួកគេ ។ នៅចុងក្រោយនៃកម្មវិធីនយោបាយ អង្គប្រជុំបានអនុម័តនូវសេចក្តីសម្រេចដូចខាងក្រោម ៖

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

១. យើងប្តេជ្ញាតស៊ូ និងសម្រេចឲ្យបានភារកិច្ចបដិវត្តទាំងអស់ប្រកបដោយស្មារតីពលីកម្មខ្ពស់បំផុតក្នុងបុព្វហេតុពង្រឹងនូវចលនាវាយលុកមហាអស្ចារ្យទៅលើខ្មាំងនៅឯសមរភូមិមុខ និងពង្រឹងចលនាមហាអស្ចារ្យ ដើម្បីដោះស្រាយបញ្ហាទឹក និងការបង្កបង្កើនផលនៅមូលដ្ឋាន ។

២. យើងប្តេជ្ញាចិត្តអនុម័ត្តយកនូវជំហរឯករាជ្យ និងបូរណភាពដែនដី ជម្នះរាល់ការលំបាក និងឧបសគ្គទាំងអស់ ហើយប្រកាន់ខ្ជាប់នូវជំហរប្តេជ្ញាចិត្ត ដើម្បីប្រយុទ្ធដោយមិនសម្របសម្រួល ឬដកថយរហូតទាល់តែបានទទួលបានជ័យជម្នះទាំងស្រុង និងជាអចិន្ត្រៃយ៍ ។

៣. យើងប្តេជ្ញាចិត្តប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នបដិវត្ត និងកម្ទេចរាល់ឧបាយកលខ្មាំង ។

៤. យើងប្តេជ្ញាចិត្តពង្រឹងឯកភាព និងសាមគ្គីភាពនៅក្នុងចំណោមជួរកងកម្លាំងប្រដាប់អាវុធ និងក្នុងចំណោមប្រជាជនទាំងមូល ហើយប្រកាន់ជាប់ជានិច្ចនូវជំហររមទម្យបដិវត្ត ។

ជាចុងក្រោយកម្មវិធីមានការសម្តែងសិល្បៈដោយយុទ្ធជន និងយុទ្ធនារី នៃក្រសួងឃោសនាការ និងព័ត៌មានរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាកិច្ចបញ្ចប់នៃពិធីក្នុងបរិយាកាសសោមនស្សរីករាយនៃសាមគ្គីភាពយោធា និងការអបអរសាទរ ៖ “ជ័យោខួបលើកទី៥ នៃរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏រុងរឿង និងកាន់តែមានជ័យជម្នះ!” ។

[00166869]

ហ៊ូ នឹម នៃរាជរដ្ឋាភិបាលរំដោះជាតិប្រជាជនកម្ពុជា ចេញសេចក្តីអំពាវនាវចំពោះព្រះសង្ឃ ស្តីអំពីសភាពការណ៍បច្ចុប្បន្ន

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជានៃភ្នំពេញ [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០១០០ ម៉ោងសកល GMT ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[អត្ថបទនៃ "សេចក្តីអំពាវនាវដល់ព្រះសង្ឃពុទ្ធសាសនានៅទីភ្នំពេញ និងទីរួមខេត្ត ដែលស្ថិតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ដោយហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការព័ត៌មាននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា" នាថ្ងៃទី២២ មីនា--ផ្សាយផ្ទាល់ ឬបានថតទុក]

[អត្ថបទ] ខ្ញុំសូមសម្តែងការគោរពពីចម្ងាយទៅដល់ព្រះសង្ឃជាទីសក្ការៈ ដែលគង់នៅទីក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងៗ ក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ព្រះសង្ឃជាទីសក្ការៈ ៖ ដូចតេជគុណបានដឹងហើយថា សភាពការណ៍ដែលកំពុងធ្លាក់ដុនដាបខ្លាំងនាពេលបច្ចុប្បន្ន នៅទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗទៀត ក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង កាន់តែបន្តធ្លាក់ដុនដាបទៀតពីមួយថ្ងៃទៅមួយថ្ងៃ ។ ស្រូវ និងស្បៀងអាហារផ្សេងៗកំពុងកាន់តែខ្សត់ទៅៗ ហើយនៅពេលអនាគតនឹងកាន់តែមានការលំបាកក្នុងការរកម្ហូបអាហារ ។ ពួកក្បត់ទាំង៧រូបនៅទីក្រុងភ្នំពេញ មិនត្រឹមតែពុករលួយយ៉ាងខ្លាំង ហើយមិនមានលទ្ធភាពដោះស្រាយបញ្ហាជីវភាព ព្រមទាំងការខ្វះខាតស្រូវអង្ករសម្រាប់ផ្គត់ផ្គង់ព្រះសង្ឃ និងជនរួមជាតិរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងបង្កើននូវអំពើគាបសង្កត់ជិះជាន់ហ្វាស៊ីសមកលើពួកគេថែមទៀត ។ នៅថ្ងៃទី១១ ខែមីនា ជនក្បត់លន់ នល់ បានប្រកាសថា គាត់បានបញ្ជាឲ្យជនរួមជាតិរបស់យើងទាំងអស់ដែលបានតវ៉ា និងទាមទារស្រូវ ឬដែលបានប្រឆាំងជាមួយគាត់ឲ្យយកទៅបាញ់សម្លាប់ចោល ។ លើសពីនេះទៀត ពួកក្បត់ជាតិបង្កើនថែមទៀតនូវសកម្មភាពកែនទ័ពរបស់ពួកគេ ។ ពួកគេបានធ្វើការកែនទ័ពដោយបង្ខំដល់មនុស្សគ្រប់គ្នា រួមទាំងក្មេងអាយុ១២ឆ្នាំ និស្សិត ស្ត្រី ព្រះសង្ឃ ឲ្យមកប្រយុទ្ធនៅសមរភូមិមុខ និងទីតាំងផ្សេងៗទៀត ដើម្បីឲ្យការពារបក្ខពួកវានៅសមរភូមិក្រោយ ។ ពួកគេ

បានបែងចែកភ្នំពេញនិងទីក្រុងផ្សេងៗទៀតដែលគេគ្រប់គ្រងជាបណ្តោះអាសន្នចេញទៅជាផ្នែកការពារតូចៗហើយបង្ខំឲ្យប្រជាជនដឹកត្រង់សេជាច្រើននៅក្នុងទីក្រុង ដើម្បីប្រយុទ្ធ និងស្លាប់ជំនួសពួកគេ ។ ព្រះសង្ឃជាទីសក្ការៈ ៖ នេះគឺជាសភាពការណ៍ធ្ងន់ធ្ងរ និងគ្រោះថ្នាក់បំផុត ប៉ះពាល់ដល់សន្តិសុខ និងជីវិតរបស់តេជគុណ ព្រមទាំងសន្តិសុខនិងជីវិតរបស់ជនរួមជាតិយើងនៅទីក្រុងភ្នំពេញ និងនៅទីក្រុងផ្សេងៗដែលខ្មាំងកាន់កាប់ជាបណ្តោះអាសន្ន ។ ពេលអត់អាហារ តេជគុណនឹងត្រូវស្លាប់ ពេលកែនចូលទាហានតេជគុណក៏នឹងត្រូវស្លាប់ ។ នាបច្ចុប្បន្នគ្មាននរណាម្នាក់អាចនៅអព្យាក្រឹត ឬមិនពាក់ព័ន្ធនោះបានឡើយ ។ ពួកខ្មាំងមិនអនុញ្ញាតឲ្យព្រះសង្ឃ និងប្រជាជនរបស់យើងរស់នៅដោយមិនមានការពាក់ព័ន្ធនោះបានឡើយ ។ អាស្រ័យហេតុនេះ នាបច្ចុប្បន្នគឺជាពេលដែលត្រូវបន្ទាន់ជាងពេលណាៗទាំងអស់ ដែលខ្ញុំសូមស្នើដល់តេជគុណឲ្យពិចារណានូវសភាពការណ៍បច្ចុប្បន្ន ហើយធ្វើការសម្រេចព្រះទ័យដើម្បីរួមសាមគ្គីជាមួយប្រជាជន យុវជន សិស្សសាលា និស្សិត គ្រូបង្រៀន អ្នករដ្ឋការ និងទាហាន ដែលបានក្រោកឈរ ក្នុងការធ្វើកុបកម្មយ៉ាងធំធេងជាបន្តបន្ទាប់ ។

១. ៩៧ភាគរយនៃប្រទេសកម្ពុជារបស់យើងត្រូវបានរំដោះរួចហើយ ប្រជាជនយើង៦លាននាក់បានរំដោះឲ្យមានសេរីភាព ។ ប្រជាជនយើងនៅក្នុងតំបន់រំដោះដ៏ធំធេង ដោយមានការចូលរួមដោយសោមនស្សរីករាយ ពីសំណាក់ព្រះអង្គទាំងអស់កំពុងនឹងកសាងកម្ពុជាក្នុងរូបភាពថ្មីមួយ ដែលមានលក្ខណៈពិតជាឯករាជ្យ សន្តិភាព អព្យាក្រឹត បូរណភាពដែនដី ប្រជាធិបតេយ្យ និងរុងរឿង ។ កម្ពុជាថ្មីនេះបានកើតឡើងហើយ ។ នៅលើវិស័យនយោបាយ យោធា សេដ្ឋកិច្ច សង្គម និងវប្បធម៌ រដ្ឋអំណាចប្រជាធិបតេយ្យរបស់ប្រជាជនយើង បានចាក់ឫសយ៉ាងរឹងមាំរួចហើយ និងដោយបានអភិវឌ្ឍដោយជំហានលោតផ្លោះដែលមិនធ្លាប់មានពីមុនមក ។ ប្រជាជនយើងជាបន្តបន្ទាប់ បានក្តោបក្តាប់និងអភិវឌ្ឍធនធានធម្មជាតិទាំងអស់របស់យើង រួមមានទាំងចម្ការកៅស៊ូ ។ ធារាសាស្ត្រ និងដំណាំ ព្រមទាំង ស្រែចម្ការដែលបានកាប់ឆ្ការផ្សេងៗបានដុះលូតលាស់ស្រស់បំព្រង និងទទួលបាននូវផលយ៉ាងល្អ ។

ប្រជាជននៃតំបន់រំដោះរបស់យើងមិនត្រឹមតែអាចបំពេញបាននូវសេចក្តីត្រូវការរបស់គេប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានគាំទ្រដល់ការធ្វើសង្គ្រាម និងបង្កើននូវជីវភាពរស់នៅរបស់ពួកគេ ។ នាបច្ចុប្បន្ននេះ ក្នុងឋានៈជារដ្ឋ និងប្រទេសឯករាជ្យ និងបូរណភាពដែនដីទាំងស្រុង តំបន់រំដោះរបស់យើងបានធ្វើការសម្រេចបាននូវសមិទ្ធផលជាច្រើនអស្ចារ្យ ហើយមានស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធ ។ ការបង្កើតក្រុមសាមគ្គីសម្រាប់បង្កបង្កើនផល និងយុទ្ធនាការដោយជោគជ័យដើម្បីដោះស្រាយបញ្ហាទឹកទូទាំងតំបន់រំដោះបានធានានូវអនាគតមួយដែលប្រទេសកម្ពុជាយើង នឹងត្រូវរំដោះបាន១០០ភាគរយ ។ ទាំងនេះគឺអាស្រ័យទៅលើកម្លាំងនៃប្រជាជន និងព្រះសង្ឃរបស់យើងនៅក្នុងតំបន់រំដោះ ដែលបានចូលរួមនៅក្នុងការប្រឹងប្រែងកសាងប្រកបដោយការប្តេជ្ញាចិត្តយ៉ាងខ្ពស់ និងយ៉ាងបរិសុទ្ធ ។

[00166870]

២. ដូចតេជគុណបានដឹងហើយ សំឡេងកាំភ្លើងបានរោទិ៍រំពងញាប់ញ័រដល់ទីស្នាក់នៅរបស់តេជគុណនាបច្ចុប្បន្ន ។ នេះគឺជាសម្រែកជ័យជម្នះនៃកងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ដែលបានកំពុងធ្វើការវាយប្រហារយ៉ាងសន្ធោរសន្ធៅនៅគ្រប់ទីកន្លែង ។ យើងកំពុងវាយប្រយុទ្ធលើទន្លេមេគង្គនៅក្នុងនិងនៅជុំវិញភ្នំពេញ ព្រមទាំងនៅបណ្តាទីរួមខេត្តដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មាំងជាបណ្តោះអាសន្ននៅឡើយ ។ យើងកំពុងវាយប្រហារដោយអានុភាពយ៉ាងខ្លាំងក្លា ហើយដោយខ្លួនឯងផ្ទាល់ ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងមានអានុភាពលើសលុប ។ ប្រជាជន និងព្រះសង្ឃរបស់យើងទូទាំងប្រទេសមានសេចក្តីរំភើបរីករាយឥតឧបមា មានមោទនភាពចំពោះកម្លាំងដ៏ខ្លាំងក្លានេះ ដែលបានទទួលការកោតសរសើរពីសំណាក់បណ្តាប្រជាជនជាមិត្តទាំងអស់ ទាំងជិតទាំងឆ្ងាយនៅលើពិភពលោក ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

តេជគុណព្រះសង្ឃជាទីសក្ការៈ ដឹងហើយថាយើងបានរំដោះ និងកាន់ក្តាប់ទាំងស្រុងនូវទន្លេមេគង្គ ។ ខ្មាំងមិនអាចដណ្តើមយកវាទៅវិញបានទេ ដោយសារខ្មាំងមិនមានកម្លាំងឬមធ្យោបាយធ្វើដូច្នោះឡើយ ។ ប្រកបទៅដោយស្មារតីទទួលខុសត្រូវនិងប្រុងប្រយ័ត្នបដិវត្តខ្ពស់បំផុត កម្មាភិបាល និងយុទ្ធជនរបស់យើង--ដែលជាបុត្រាបុត្រីដ៏ល្អនៃប្រជាជនកម្ពុជាយើង--តែងតែត្រៀមខ្លួនរួចជាស្រេចដើម្បីកម្ទេចខ្មាំងនៅតាមបណ្តោយចម្ងាយជិត១០០គីឡូម៉ែត្រនៃទន្លេមេគង្គ ដែលតភ្ជាប់ពីភ្នំពេញទៅព្រំប្រទល់វៀតណាមខាងត្បូង ។ អស់រយៈពេលជាងពីរបីខែកន្លងទៅ មិនមានក្បួនកប៉ាល់ណាអាចគេចផុតពីកណ្តាប់ដៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងឡើយ ចាប់តាំងពីដើមខែនេះមកទន្លេមេគង្គផ្នែកខាងក្រោមអ្នកលឿងមានភាពស្ងាត់ជ្រងំ ហើយកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងបានពន្លិច ឬបានដុតឲ្យឆេះនូវក្បួនកប៉ាល់របស់ខ្មាំងទាំងអស់ ដែលយូរៗម្តងបានលេចមុខមកខាងលើអ្នកលឿង ។ ខ្មាំងកាលពីមុនបានដាក់ការសង្ឃឹមទៅលើពោធិ៍ចិនតុង ប៉ុន្តែឥឡូវពោធិ៍ចិនតុងក៏បានដណ្តើមយកអស់ហើយដែរ ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងនាបច្ចុប្បន្ន កំពុងបង្កើនការប្រយុទ្ធលើពោធិ៍ចិនតុង ភ្នំពេញ និងទីរួមខេត្តទាំងអស់ដែលខ្មាំងកំពុងកាន់កាប់ជាបណ្តោះអាសន្ន ។ ដូចតេជគុណបានដឹងហើយ នៅក្នុងទីក្រុងមួយចំនួនកងកម្លាំងប្រដាប់អាវុធរបស់យើងបានចូលរហូតទៅដល់ទីផ្សារ ឬខិតចូលដល់ក្បែរទីស្នាក់ការខេត្តក៏មាន នៅរង់ចាំតែពេលវេលាតែប៉ុណ្ណោះដែលប្រជាជនកម្ពុជារបស់យើងនឹងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាត្រូវរំដោះបានជាអចិន្ត្រៃយ៍នូវបណ្តាក្រុងទាំងនេះ ។

៣. ដោយសារតេជគុណបានស្តាប់ឮវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជារបស់យើង តេជគុណដឹងហើយថា មហាសន្និបាតជាតិលើកទី២ បានធ្វើឡើងក្រោមបរិយាកាសអំណោយផលក្រៃលែងចំពោះតំបន់រំដោះរបស់យើងកាលពីថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ។ សេចក្តីសម្រេចសំខាន់ៗនៃមហាសន្និបាតនេះ ដែលតំណាងឲ្យប្រជាជន និងប្រជាជាតិកម្ពុជា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រ

ណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទាំងមូល បានស្តែងឲ្យឃើញថា បដិវត្តកម្ពុជារបស់យើងបានឈានមកដល់ដំណាក់កាលថ្មីមួយ ។ នៅក្នុងដំណាក់កាលថ្មីនេះ ប្រជាជន និងប្រជាជាតិកម្ពុជា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជារបស់យើង បានបង្កើនការវាយប្រហារទៅលើខ្មាំងក្នុងកម្រិតដែលមិនធ្លាប់មានពីមុនមក ដើម្បីរំដោះឲ្យបាននូវទឹកដី៣ភាគរយ និងប្រជាជនដែលនៅសល់ រួមមានទាំងតេជគុណ ព្រះសង្ឃជាទីសក្ការៈ ដែលបានរងទុក្ខ និងឧបសគ្គមិនអាចរៀបរាប់អស់នៅក្នុងទីក្រុងភ្នំពេញ និងតំបន់ដែលកាន់កាប់បណ្តោះអាសន្នដោយខ្មាំង ។ ប្រជាជន និងប្រជាជាតិកម្ពុជា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រាកដជានឹងដណ្តើមបានជ័យជម្នះទាំងស្រុងជាដាច់ខាត ។

ព្រះសង្ឃជាទីសក្ការៈ ៖ មានជនក្បត់តែ៧រូបទេ មានដូចជាលន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណង់ដេ ។ ពួកវាបានបង្កឲ្យមាននូវការខូចខាត និងវិនាសកម្មដែលមិនអាចរៀបរាប់អស់ និងដែលមិនធ្លាប់មានពីមុនមក មកលើប្រជាជាតិ ប្រជាជន ព្រះសង្ឃ និងព្រះពុទ្ធសាសនារបស់យើង ។ ឧក្រិដ្ឋកម្មដ៏សែនឃោរឃៅដែលបានប្រព្រឹត្តដោយពួកក្បត់ជាតិទាំងនេះ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ--ចាប់តាំងពីការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលបានផ្តួលរំលំកម្ពុជាដែលមានឯករាជ្យ សន្តិភាព និងអព្យាក្រឹត--មានវិសាលភាពធំធេងជាងមហាសមុទ្រ និងខ្លឹមសារចងចាំជាដរាបធំដូចភ្នំ ។ អាស្រ័យហេតុនេះ តំណាងឲ្យប្រជាជន និងប្រជាជាតិកម្ពុជាទាំងមូល មហាសន្និបាតជាតិលើកទី២ បានសម្រេចយ៉ាងត្រឹមត្រូវថា អត្ថិភាពនៃជនក្បត់ទាំង៧រូបនេះគួរតែត្រូវបញ្ចប់ ។

នាបច្ចុប្បន្នបណ្តាជនក្បត់ជាតិទាំងនេះបានឈានដល់ដំណាក់កាលចុងក្រោយនៃអត្ថិភាពរបស់ពួកគេហើយ ។ ឥឡូវនេះតេជគុណ ព្រះសង្ឃជាទីសក្ការៈ ក៏ដូចជាពិភពលោកទាំងមូលបានដឹងហើយថា ពួក

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ជនក្បត់ត្រូវបានឡោមព័ទ្ធទាំងស្រុងដោយកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនរបស់យើង ។ នៅចាំតែពេលវេលាតែប៉ុណ្ណោះដែលកងកម្លាំង និងប្រជាជនរបស់យើងនឹងកម្ទេចពួកវា ដាក់ទណ្ឌកម្មពួកវាស្របទៅតាមទំហំនៃឧក្រិដ្ឋកម្មដែលពួកវាបានប្រព្រឹត្ត ។ ដូចតេជគុណបានដឹងហើយ ភ្នំពេញ និងបណ្តាតំបន់ទីក្រុងទាំងអស់ដែលខ្មាំងកំពុងកាន់កាប់បណ្តោះអាសន្ន ត្រូវបានដាក់ឲ្យក្នុងភាពឯកោទាំងស្រុង ។ ទន្លេមេគង្គត្រូវបានបិទ រាល់ផ្លូវគមនាគមន៍ផ្លូវគោកទាំងអស់ត្រូវបានឈប់ដំណើរការ ព្រលានយន្តហោះពោធិ៍ចិនតុងត្រូវបានបិទ ហើយប្រជាជន និងអ្នកនយោបាយអាមេរិកកំពុងតែបដិសេធនូវសំណើរបស់រដ្ឋការអាមេរិក ដែលស្នើសុំជំនួយផ្តល់មកដល់បណ្តាជនក្បត់ជាតិទាំងនេះ ។ ថ្ងៃអវសានរបស់ពួកវាបានមកដល់ហើយ ។ ឥឡូវនេះយើងត្រូវតែបញ្ចប់អត្ថិភាពនៃពួកជនក្បត់ជាតិទាំង៧រូបនេះ ។

[00166871]

ព្រះសង្ឃជាទីគោរព ដូចដែលបានថ្លែងយ៉ាងច្បាស់ដោយសេចក្តីសម្រេចនៃមហាសន្និបាតជាតិលើកទី២ អ្នករដ្ឋការទាំងថ្នាក់ក្រោម និងទាំងថ្នាក់លើទាំងអស់ អ្នកនយោបាយ ឥស្សរជន នាយទាហាន ពលទាហាន និងកងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែកដទៃទៀត ដែលបម្រើរបបពួកក្បត់ជាតិនេះ លើកលែងតែជនក្បត់ទាំង៧រូបនេះ អាចនឹងមកចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ដរាបណាពួកគេបោះបង់ចោល និងឈប់សហការជាមួយជនក្បត់ជាតិទាំង៧រូបនោះ ។ ពេលនេះគឺជាពេលល្អបំផុត ។ ព្រះសង្ឃជាទីគោរពទាំងអស់ដែលមានប្រពៃណីតស៊ូស្នេហាជាតិ គួរតែរួមចំណែកក្នុងការបញ្ចប់ទុក្ខវេទនា និងមហាវិនាសកម្មដ៏ធំធេង ដែលចក្រពត្តិអាមេរិក និងអាយ៉ងពួកវាបានបង្កឲ្យកើតមានឡើងក្នុងរយៈពេល៥ឆ្នាំកន្លងទៅ មកលើប្រជាជាតិ និងប្រជាជនរបស់យើង ព្រះសង្ឃ និងពុទ្ធសាសនា ។ តេជគុណគួរតែរួមចំណែកក្នុងការបញ្ចប់សង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងអាយ៉ងពួកវានៅកម្ពុជា រួមចំណែក

រំដោះជាតិប្រជាជន និងពុទ្ធសាសនា ព្រមទាំងរួមចំណែកក្នុងការសម្រេចឲ្យបានយ៉ាងឆាប់រហ័សនូវសន្តិភាពជូនចំពោះប្រទេសកម្ពុជាយើង ។

ជាមួយគ្នានេះ ខ្ញុំសូមធ្វើការអំពាវនាវជាបន្ទាន់ដូចខាងក្រោមដល់ព្រះសង្ឃជាទីសក្ការៈទាំងអស់ ដែលស្នាក់នៅតាមវត្តអារ៉ាម និងទីរួមខេត្តផ្សេងៗ ដែលនៅក្រោមការគ្រប់គ្រងរបស់ខ្មាំងនៅឡើយ ។

១. ព្រះសង្ឃ ដែលជានិស្សិតនៃវិទ្យាល័យពុទ្ធសាសនបណ្ឌិត្យ និងសកលវិទ្យាល័យពុទ្ធសាសនបណ្ឌិត្យទាំងអស់ គ្រូខាងព្រះសង្ឃ និងព្រះសង្ឃទាំងឋានៈទាបនិងខ្ពស់ទាំងអស់ ៖ តេជគុណសូមអញ្ជើញបន្តប្រវត្តិនៃការតស៊ូដ៏អង់អាចក្លាហាននៃព្រះសង្ឃស្នេហាជាតិ ដែលបានចូលរួមកន្លងមកនៅក្នុងគ្រប់ចលនាតស៊ូនៃ ប្រជាជន កម្មករ យុវជន និស្សិត គ្រូបង្រៀន អ្នករដ្ឋការ និងទាហាន ដូចជាត្រូវចេញសេចក្តីថ្លែងការណ៍ ធ្វើសិក្ខាសាលា សន្និបាត និងជួបប្រជុំ ឈប់ទៅសាលា ធ្វើបាតុកម្ម ប្រឆាំងនឹងកំណែនទ័ព អំពើពុករលួយ អំពើអយុត្តិធម៌ និងហ្វាស៊ីសនិយម វាយឆ្មក់ឃ្លាំងអង្ករ និងសហករណ៍របស់ពួកក្បត់ ហើយសូម្បីតែវាយប្រហារទៅលើខ្មាំងដណ្តើមយកអាវុធពីខ្មាំងដើម្បីប្រហារទៅលើខ្មាំងវិញ ក៏ត្រូវតែចូលរួមដែរ ព្រមទាំងត្រូវធ្វើកុបកម្មផ្តួលរំលំជនក្បត់ជាតិទាំង៧រូប និងរបបរបស់ពួកវា ។

២. ព្រះសង្ឃក្នុងឋានៈខ្ពង់ខ្ពស់ ព្រះសង្ឃពុទ្ធសាសនាគ្រប់លំដាប់ថ្នាក់ ប្រធានព្រះសង្ឃតាមខេត្ត ស្រុក វត្តអារ៉ាម និងទីស្នាក់អាស្រ័យពុទ្ធសាសនាទាំងអស់ទូទាំងតំបន់ដែលនៅក្រោមការកាន់កាប់របស់ខ្មាំង ។ តេជគុណសូមអញ្ជើញជួយព្រះសង្ឃដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់តេជគុណ ក៏ដូចជាប្រជាជនកម្មករ យុវជន និស្សិត ដែលរស់នៅជិតវត្តរបស់តេជគុណ ឬនៅតាមកុដិរបស់តេជគុណ ដែលបានចូលរួមក្នុងកុបកម្ម និងតស៊ូរបស់ប្រជាជនយើង ។ ជាងនេះទៅទៀត តេជគុណសូមអញ្ជើញចូលរួម

ក្នុងការតស៊ូនេះ ឬក៏ជួយលើកស្ទួយនូវការតស៊ូតាមគ្រប់រូបភាពរបស់ព្រះសង្ឃ និងជនរួមជាតិរបស់យើង ។

៣. ព្រះសង្ឃជាទីសក្ការៈទាំងអស់ តេជគុណសូមអញ្ជើញផ្តល់នូវការទំនុកបម្រុងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ទៅដល់យុទ្ធជន និងកម្មាភិបាលជាបងប្អូនរបស់យើង នៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង ដែលបានធ្វើការវាយលុកទៅលើខ្មាំងគ្រប់ទីកន្លែង ហើយសូមចូលរួមក្នុងការកម្ទេចខ្មាំងទាំង៧រូប ដើម្បីរំដោះទីក្រុងភ្នំពេញ និងទីរួមខេត្តទាំងអស់ ដែលខ្មាំងកាន់កាប់ជាបណ្តោះអាសន្ន ។

៤. ដើម្បីចៀសឲ្យផុតពីគ្រោះថ្នាក់ណាមួយដែលអាចកើតមានឡើងចំពោះតេជគុណ សូមតេជគុណគេចឲ្យឆ្ងាយពីទីតាំង យោធា នយោបាយ និងសេដ្ឋកិច្ចរបស់ខ្មាំងទាំងអស់ ។ តំបន់រំដោះនៅជិតតេជគុណ ហើយប្រសិនបើមានការចាំបាច់តេជគុណសូមអញ្ជើញចូលមកតំបន់រំដោះទាំងនោះ ។ ប្រជាជន យុទ្ធជន យុទ្ធនារី កម្មាភិបាល និងអង្គការចាត់តាំងរណសិរ្សរួបរួមជាតិកម្ពុជារបស់យើងនៅគ្រប់ទីកន្លែងនឹងស្វាគមន៍ នឹងផ្តល់ដល់តេជគុណនូវម្ហូបអាហារ ទីស្នាក់អាស្រ័យ និងសន្តិសុខ ។ តេជគុណ ព្រះសង្ឃជាទីសក្ការៈ សូមអញ្ជើញចូលទៅតំបន់រំដោះដែលតេជគុណអាចចូលរួមបានជាមួយនឹងព្រះសង្ឃ និងប្រជាជនចំនួន៦លាននាក់ដែលនៅក្នុងតំបន់រំដោះ ដើម្បីកសាងកម្ពុជាថ្មីមួយ ដែលពិតជាឯករាជ្យ សន្តិភាព អព្យាក្រឹត ប្រជាធិបតេយ្យ និងសម្បូររុងរឿង ហើយដែលគោរពព្រះពុទ្ធសាសនា--ដែលរណសិរ្សរួបរួមជាតិកម្ពុជារបស់យើងបានលើកតម្កល់ជាសាសនារបស់រដ្ឋ ដែលត្រូវរក្សាជារៀងរហូត ។

ពេលវេលានៅសល់ខ្លីណាស់ ។ តេជគុណ ព្រះសង្ឃជាទីសក្ការៈ ត្រូវតែសម្រេចចិត្តឲ្យបានឆាប់រហ័ស ជាមួយនឹងសេចក្តីរាប់អានដ៏ជ្រាលជ្រៅ និងសេចក្តីស្មោះត្រង់យ៉ាងស្មោះស្ម័គ្រ ខ្ញុំសូមគោរពចំពោះ

តេជគុណ និងជូនពរតេជគុណអាយុវែង សុខភាពល្អ សុភមង្គល កម្លាំងមាំមួន បំពេញបានគ្រប់ភារកិច្ច និងជ័យជម្នះនៅក្នុងភារកិច្ចរំដោះជាតិប្រជាជនរបស់យើង ។

ជ័យោប្រជាជនកម្ពុជាដ៏អស្ចារ្យ! ជ័យោពុទ្ធសាសនា! ជ័យោកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាដ៏អង់អាចក្លាហាន និងដែលទទួលបានជ័យជម្នះជាប់រហូត! ជ័យោរណសិរ្សរួបរួមជាតិកម្ពុជាដ៏រឹងមាំនិងខ្លាំងក្លា!

[00166872]

ជ័យោមហាសាមគ្គីភាពរវាងព្រះសង្ឃស្នេហាជាតិ និងប្រជាជននៅក្នុងតំបន់ដែលកាន់កាប់ជាបណ្តោះអាសន្នដោយខ្មាំង ដែលកំពុងលុបបំបាត់ចក្រពត្តិអាមេរិក និងអាយ៉ងទាំង៧រូបរបស់ពួកវា ។ ប្រជាជនប្រាកដជានឹងរំដោះបានកម្ពុជាទាំងស្រុងក្នុងពេលអនាគតឆាប់ៗខាងមុខ ។

តំបន់រំដោះកម្ពុជា ថ្ងៃទី២២ មីនា ឆ្នាំ១៩៧៥ ។ ដោយគោរពពីខ្ញុំ ។

បទអត្ថាធិប្បាយវិទ្យុរណសិរ្សរួបរួមជាតិ អបអរសាទរខួបកំណើតរណសិរ្សរួបរួមជាតិកម្ពុជា-កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា [សម្ងាត់] ជាភាសាខ្មែរផ្សាយទៅកម្ពុជា ម៉ោង ០៤០០ ម៉ោងសកល GMT ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[អត្ថបទអត្ថាធិប្បាយ ៖ "ជ័យជម្នះទាំងឡាយជាប្រវត្តិសាស្ត្រដ៏អស្ចារ្យដែលទទួលបានក្នុងរយៈពេល៥ឆ្នាំកន្លងទៅ ដោយប្រជាជន និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា"]

[អត្ថបទ] ថ្ងៃនេះទី២៣ ខែមីនា ឆ្នាំ១៩៧៥ គឺគម្រប់៥ឆ្នាំគត់ចាប់តាំងពីការចាប់បដិសន្ធិនៃរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ៥ឆ្នាំដែលបានកត់សម្គាល់នាំមកនូវជ័យជម្នះអស្ចារ្យដែលមានចរិតជាប្រវត្តិសាស្ត្រ ។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅសង្គ្រាមបដិវត្តដ៏អស្ចារ្យក្នុងការរំដោះជាតិ យើងបានប្រមូលបាននូវបទពិសោធន៍នៃការតស៊ូបដិវត្តរបស់ប្រជាជាតិ និងប្រជាជនកម្ពុជា--ដែលជាការតស៊ូមួយ ក្នុងនោះកូនចៅប្រជាជនបានបង្ហូរឈាមនៅលើមាតុភូមិជាទីស្រឡាញ់របស់ពួកគេ ។ ពួកចក្រពត្តិចាស់ថ្មី ពោលគឺបារាំង ជប៉ុន និងសហរដ្ឋអាមេរិកបានក្តោបក្តាប់ និងវាយប្រហារមកលើកម្ពុជា ។ ជាពិសេសក្នុងរយៈពេល២០ឆ្នាំចុងក្រោយនៅពេលដែលចក្រពត្តិអាមេរិក និងអាយ៉ងរបស់វាពួកលន់ នល់ បានសាបព្រោះនូវវិនាសកម្មដ៏ធំធេង និងលំបាកវេទនាមកលើប្រជាជាតិ និងប្រជាជនកម្ពុជា កុលបុត្ត កុលធិតាច្រើនរាប់មិនអស់បានធ្វើពលីកម្មជីវិត ដើម្បីរំដោះប្រជាជាតិ និងមាតុភូមិជាទីស្រឡាញ់បំផុតរបស់ពួកគេ ។

ជាមួយនឹងជំហរនៃការតស៊ូដាច់ខាតស្វ័យម្ចាស់ការលើខ្លួនឯង ប្រឈមមុខនឹងគ្រោះថ្នាក់ និងការលំបាកបន្តបន្ទាប់ បែងចែកយ៉ាងច្បាស់លាស់រវាងមិត្តនិងសត្រូវ ប្រជាជនយើង យុទ្ធជន យុទ្ធនារី និងកម្មាភិបាលរបស់យើង បានឆ្លងកាត់នូវការតស៊ូបដិវត្តអស់រយៈពេលជាច្រើនឆ្នាំ ងើបឡើងដោយទឹកចិត្តដាច់ខាតប្រយុទ្ធប្រឆាំងខ្លាំង នៅពេលដែលចក្រពត្តិអាមេរិក និងពួកក្បត់ជាតិ លន់ នល់ សេរីមៈតៈ ស៊ីន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងសុស្តែន ហ្វេណាង់ដេ បានធ្វើរដ្ឋប្រហារប្រតិកិរិយាហ្វាស៊ីស នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ផ្តួលរំលំនូវកម្ពុជាដែលឯករាជ្យ សន្តិភាព និងអព្យាក្រឹត ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ថ្ងៃទី២៣ មីនា ១៩៧០ គឺជាថ្ងៃប្រវត្តិសាស្ត្រ នៅពេលដែលសម្តេចនរោត្តម សីហនុ ប្រធានរដ្ឋ និងជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍៥ចំណុចយ៉ាងឱឡារិក អំពាវនាវដល់ប្រជាជាតិ និងប្រជាជនកម្ពុជាឲ្យងើបឡើងរួបរួមគ្នា ហើយពង្រឹងសាមគ្គីភាពដើម្បីកម្ទេចខ្មាំង ហើយនៅពេលដែលប្រជាជនកម្ពុជា រួមទាំងព្រះសង្ឃពុទ្ធសាសនា កម្មករ ពលករ យុវជន សិស្ស និស្សិត បញ្ញវន្ត និងប្រជាជនដទៃទៀតមកពីស្រទាប់វណ្ណៈបានងើបឡើង ហើយធ្វើបាតុកម្មដ៏ធំៗនៅក្នុងការតស៊ូកម្ទេចឧបាយកលពួកក្បត់ជាតិ ដែលនៅពីក្រោយខ្នងរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ។ គឺជាពេលនោះហើយ ដែលជាពេលចាប់បដិសន្ធិនៃរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជាបានប្រកាសបង្កើតឡើងប្រកបដោយជោគជ័យ ។

នៅក្រោមទង់ដ៏ខ្លាំងសន្ធោសន្ធៅនិងមហាអស្ចារ្យនៃរណសិរ្សរួបរួមជាតិកម្ពុជា ប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានធ្វើការវាយប្រហារទៅលើចក្រពត្តិអាមេរិក និងពួកអាយ៉ងរបស់វាយ៉ាងធ្ងន់ធ្ងរ និងយ៉ាងក្លៀវក្លា រក្សាបាននូវជំហរតស៊ូដាច់ខាត ដោយមិនមានការសម្របសម្រួល ឬការដកថយ រហូតដល់ទទួលបានជ័យជម្នះដ៏រុងរឿង និងជាប្រវត្តិសាស្ត្រនាពេលបច្ចុប្បន្ន ។

ប្រជាជន៦លាននាក់បានត្រូវរំដោះទាំងស្រុង ។ តំបន់រំដោះដ៏ធំទូលាយបានក្លាយទៅជាតំបន់សាមគ្គីភាពជាធ្លុងមួយ ហើយបានក្លាយជាប្រទេសមួយពិតប្រាកដដែលមានជ័យជម្នះ ស្ថាប័នជាច្រើន និងរចនាសម្ព័ន្ធគ្រប់ជាន់ថ្នាក់ខាងវិស័យនយោបាយ យោធា សេដ្ឋកិច្ច សង្គម វប្បធម៌ និងហិរញ្ញវត្ថុ ប្រកបដោយលក្ខណៈពេញលេញទាំងស្រុង ។ បច្ចុប្បន្នវាគឺជារដ្ឋមួយឯករាជ្យ បូរណភាពដែនដី និងម្ចាស់ការខ្ពស់ ។ ជាលើកទី១នៅក្នុងប្រវត្តិសាស្ត្រ យើងកំពុងកសាងបាននូវកម្ពុជាមួយ ដែលឯករាជ្យ សន្តិភាព អព្យាក្រឹត និងប្រជាធិបតេយ្យ លើទឹកដីដ៏រុងរឿងនៃអង្គរ ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166873]

នៅក្នុងរយៈពេល៥ឆ្នាំកន្លងទៅ តំបន់រំដោះដ៏ធំធេង និងដ៏រឹងមាំ មានការរីកចម្រើនឈានទៅមុខយ៉ាងឆាប់រហ័ស ជាពិសេសក្នុងវិស័យកសាងទំនប់ប្រឡាយ និងអាងទឹក ដើម្បីដោះស្រាយបញ្ហាទឹក ក៏ដូចជាក្នុងការបង្កើតនូវក្រុមសាមគ្គីបង្កបង្កើនផល ។ ទាំងអស់នេះសម្រេចបានយ៉ាងឆាប់រហ័សនៅទូទាំងតំបន់រំដោះកម្ពុជាទាំងមូល ។ ដូច្នេះបាននាំមកនូវការផ្លាស់ប្តូរដែលមិនធ្លាប់មានពីមុនមក មកដល់តំបន់ជនបទនៃប្រទេស ។

សមិទ្ធផលទាំងនេះកាន់តែបានពង្រឹងឡើងថែមទៀតនូវអំណាចគ្រប់គ្រងរបស់ប្រជាជនយើង ដែលជាមូលដ្ឋានគ្រឹះនៃកម្ពុជាថ្មីមួយ ដែលមានឯករាជ្យ សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ មានអានុភាពខ្លាំងក្លា សម្បូររុងរឿង បម្រើឲ្យសុភមង្គលនៃប្រជាជនគ្រប់ជនជាតិ ជាពិសេសប្រជាជនក្រីក្រ កសិករដែលជាម្ចាស់ប្រទេស និងជាម្ចាស់ទឹកដី ។ សមិទ្ធផលនេះក្នុងពេលតែមួយ គឺជាការធានាបានយ៉ាងច្រើនសម្រាប់ធ្វើឲ្យចលនាវាយលុកមហាអស្ចារ្យនាពេលបច្ចុប្បន្នទៅលើខ្មាំងនៅឯសមរភូមិ នៃសង្គ្រាមប្រជាជនដ៏អស្ចារ្យ និងប្រកបដោយជ័យជម្នះនេះ កំពុងតែជាដំបងវាយយ៉ាងទម្ងន់ទៅលើពួកជនក្បត់ជាតិទាំង៧រូប ។

ខួបកំណើតលើកទី៥ នៃការចាប់បដិសន្ធិរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានធ្វើឡើងក្នុងឱកាសមួយដែលអំណោយផលបំផុត ខណៈដែលកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង រំដោះបានទាំងស្រុងនូវទន្លេមេគង្គ គ្រប់គ្រងសភាពការណ៍នៅមូលដ្ឋានអ្នកលឿង និងតាមបណ្តោយទន្លេចម្ងាយជិត១០០គីឡូម៉ែត្រចន្លោះពីភ្នំពេញ និងព្រំប្រទល់វៀតណាម បានឡោមព័ទ្ធ និងវាយប្រហារទៅលើភ្នំពេញ និងពោធិ៍ចិនតុងមកពីគ្រប់ទិសទី ហើយបន្តបន្ទាប់បានបោសសម្អាតខ្មាំងចេញពីតំបន់ជាយក្រុងភ្នំពេញ ដូច្នេះបានធ្វើឲ្យភ្នំពេញនៅឯកោ កាត់ផ្តាច់

រាល់ផ្លូវគមនាគមន៍ជើងគោក និងជើងទឹកទាំងអស់ ហើយបានធ្វើឲ្យទីក្រុងនេះក្លាយទៅជារងតូចមួយទទួលនូវការបាញ់ផ្លោងយ៉ាងធ្ងន់ធ្ងរកាន់តែច្រើនឡើងមកពីសំណាក់យុទ្ធជនខ្មាន់កាំភ្លើងរបស់យើង ហើយដែលជាទីកន្លែងដែលប្រជាជន យុវជន និស្សិត គ្រូបង្រៀន អ្នករដ្ឋការ និងទាហាន កំពុងតែក្រោកឈរឡើង និងធ្វើកុបកម្មផ្ទុះឡើងដូចភ្នំភ្លើង ។ ដោយបានកាត់ផ្តាច់ស្រូវ គ្រឿងសព្វាវុធ ប្រេងឥន្ធនៈ និងដោយទទួលរងនូវការវាយលុកដ៏អស្ចារ្យ ពីសំណាក់កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងនៅឯភ្នំពេញ និងនៅទីរួមខេត្តដែលកាន់កាប់ដោយខ្មាំងជាបណ្តោះអាសន្ន ជនក្បត់ជាតិទាំង៧រូប នឹងត្រូវបានកម្ទេចទាំងស្រុងដោយស្នាដៃប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើងក្នុងពេលឆាប់ៗនេះ ។

ជាមួយនឹងមហាជ័យជម្នះដែលទទួលបាននៅសមរភូមិផ្ទៃក្នុង ប្រជាជាតិ និងប្រជាជនកម្ពុជា កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក៏ទទួលបានផងដែរ នូវជ័យជម្នះដ៏រុងរឿងនៅលើឆាកអន្តរជាតិ ។ អត្តសញ្ញាណបដិវត្តន៍នៃប្រជាជន និងប្រជាជាតិកម្ពុជា បានផុសឡើងខ្ពស់ត្រដែតនៅលើពិភពលោក ។ បណ្តាប្រជាជនជាមិត្តទាំងអស់ ទាំងជិតទាំងឆ្ងាយ និងបណ្តាប្រជាជនដែលស្រឡាញ់សន្តិភាពទាំងអស់នៅក្នុងពិភពលោក មានសេចក្តីសោមនស្សរីករាយសាទរជ័យជម្នះរប់សយើង ហើយបានសម្តែងនូវការគាំទ្រដោយសោមនស្សរីករាយ និងជាបន្តចំពោះយើងទាំងអស់គ្នា ។ ជ័យជម្នះដ៏មានខ្លឹមសារប្រវត្តិសាស្ត្រនៃប្រជាជនយើង សម្រេចបានដោយសារមានមាគ៌ានយោបាយបដិវត្តត្រឹមត្រូវ និងវ៉ៃយឆ្លាត ភាពអង់អាចក្លាហាននៃប្រជាជនកម្ពុជាយើង អានុភាពនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់យើង និងវីរភាពបដិវត្តដ៏ខ្ពង់ខ្ពស់ នៃយុទ្ធជន និងកម្មាភិបាលរបស់យើង បុរស និងនារី កម្មករ និងកសិករក្រីក្រ កម្លាំងដ៏រឹងមាំនិងធំធេងនៃសាមគ្គីភាពក្នុងចំណោមរណសិរ្សរួបរួមជាតិកម្ពុជា ហើយដោយសារមានការចាត់តាំង និងរីកចម្រើនយ៉ាងឆាប់រហ័សនៃកងកម្លាំងបដិវត្ត ដែលសម្រេចបានដោយរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

នៅលើគ្រប់វិស័យជាពិសេសជំហរ និងមាគ៌ាប្ដេជ្ញាចិត្តប្រយុទ្ធយកឈ្នះ ដណ្ដើមយកឯករាជ្យ និងបូរណភាពដែនដី ព្រមទាំងជម្នះគ្រប់ការលំបាក និងគ្រប់ឧបសគ្គ ។

ការតស៊ូដ៏រុំារ៉ៃនៃប្រជាជនកម្ពុជាយើងបានជួយឲ្យយើងមើលឃើញកាន់តែច្បាស់នូវចរិតចចេសរឹងរូសរបស់ខ្មាំងចក្រពត្តិអាមេរិក និងអាយ៉ងពួកវាទាំងអស់ ។ អាស្រ័យហេតុនេះ ប្រជាជាតិ និងប្រជាជនកម្ពុជារបស់យើងទាំងមូល កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រមទាំងយុទ្ធជន យុទ្ធនារី កម្មាភិបាលទាំងអស់របស់យើង បានប្ដេជ្ញាចិត្តរក្សានូវការប្រុងប្រយ័ត្នបដិវត្តកាន់តែខ្ពស់ និងបន្តប្រយុទ្ធដាច់ខាតរហូតទាល់តែខ្មាំងត្រូវបានបោសសម្អាតអស់ទាំងស្រុង ហើយរហូតទាល់តែពិតជាទទួលបាននូវកម្ពុជាថ្មីមួយ ដែលឯករាជ្យ សន្តិភាព អព្យាក្រឹត បូរណភាពដែនដី ប្រជាធិបតេយ្យ និងសម្បូររុងរឿង ដែលមានបូរណភាពដែនដីត្រូវបានបង្កើតឡើងជាអចិន្ត្រៃយ៍ ។

នៅក្នុងឱកាសនេះ ប្រជាជាតិ និងប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមសម្ដែងនូវការថ្លែងអំណរគុណដល់បណ្ដាប្រជាជន និងប្រទេសជាមិត្តទាំងអស់ ទោះជិត ទោះឆ្ងាយ ព្រមទាំងប្រជាជនដែលស្រឡាញ់សន្តិភាព រួមទាំងប្រជាជនចម្រើនរបស់អាមេរិកផង ដែលបានគាំទ្រ និងជួយដល់បុព្វហេតុដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា ។ នៅក្នុងពេលឆាប់ៗនេះ ដោយមានការគាំទ្ររបស់ប្រជាជននៅលើពិភពលោក ប្រជាជនកម្ពុជារបស់យើង និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ប្រាកដជានឹងរំដោះបានទាំងស្រុងទីក្រុងភ្នំពេញ និងប្រទេសកម្ពុជាទាំងមូល ។ ជ័យោខួបកំណើតលើកទី៥ ដ៏ជោគជ័យនៃរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166874]

សេចក្តីប្រកាសចុះថ្ងៃទី២២ ខែមីនា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ស្តីអំពីខួបកំណើតនៃរណសិរ្សរួបរួមជាតិកម្ពុជា-និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា

ទីភ្នាក់ងារព័ត៌មានកម្ពុជា [សម្ងាត់] ជាភាសាបារាំងផ្សាយទៅអាស៊ីបូព៌ា ម៉ោង១១១៦ ម៉ោងសកល GMT ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៥ បាងកក (BK)

[សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចុះថ្ងៃទី២២ ខែមីនា ស្តីអំពីខួបកំណើតនៃរណសិរ្សរួបរួមជាតិកម្ពុជា-កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា]

[អត្ថបទ] កម្ពុជាថ្ងៃទី២៥ ខែមីនា AKI--ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ គឺជាខួបកំណើតលើកទី៥នៃការចាប់បដិសន្ធិរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ។ នៅក្នុងរយៈពេល៥ឆ្នាំនៃការតស៊ូយ៉ាងដាច់ខាត និងរឹងមាំប្រឆាំងនឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិក និងពួកជនក្បត់នៅទីក្រុងភ្នំពេញ រណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា
ជាបន្តបន្ទាប់បានទប់ស្កាត់បាននូវការប្រតិបត្តិការ និងឧបាយកលយោធារបស់ខ្មាំងទាំងអស់ ។

[00166875]

ថ្ងៃនេះពួកគេរំដោះបាន៩៧ភាគរយនៃដែនដីជាតិ និងប្រជាជន៦លាននាក់ ។ រណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា តំណាងឲ្យសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅរបស់

ប្រជាជនកម្ពុជាទាំងមូល លើកលែងតែជនក្បត់ជាតិមួយក្ដាប់តូច--ដែលជាឧបករណ៍អាណានិគមចាស់ថ្មី របស់ចក្រពត្តិអាមេរិកនៅកម្ពុជា ។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង កាន់ក្ដាប់នូវការទទួលខុសត្រូវរដ្ឋកម្ពុជាមួយដែលឯករាជ្យ បូរណភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ និង ប្រជាធិបតេយ្យ ដែលបានបង្កើតកន្លងមកនៅលើតំបន់រំដោះដ៏ធំទូលាយ ហើយមានទំនាក់ទំនងការទូត ជាមួយនឹងបណ្ដារដ្ឋបូរណភាពដែនដីចំនួនជាង៦០ ។

នាពេលបច្ចុប្បន្នក្រោមការវាយប្រហារឥតឈប់ឈរ និងខ្លាំងក្លាពីសំណាក់ប្រជាជន និងកងកម្លាំង ប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់ពួកគេ ជនក្បត់នៅទីក្រុងភ្នំពេញមួយក្ដាប់តូចនោះ កំពុងស្ថិត នៅក្នុងភាពទល់ច្រក ។ មនុស្សគ្រប់គ្នាយល់ស្របថា ការដួលរលំដែលមិនអាចចៀសផុតបានកាន់តែខិតជិត មកដល់ពួកវាហើយ ។

ប៉ុន្តែទោះបីជាមានការជំទាស់ពីប្រជាជនសហរដ្ឋអាមេរិក ឥស្សរជន និងបណ្ដាប្រជាជនដែល ស្រឡាញ់យុត្តិធម៌ និងសន្តិភាពជុំវិញពិភពលោកក៏ដោយ ក៏រដ្ឋការហ្វត និងឃីស៊ីងជ័រ នៅតែចចេស ជ្រៀត ជ្រែកចូលកិច្ចការកម្ពុជា បង្កើននូវយន្តហោះដឹកជម្លៀសនិងទម្លាក់ ព្រមទាំងប្រើប្រាស់ការភូតកុហក និងឆ បោក ដើម្បីបន្តជួយដល់ពួកក្បត់ជាតិនៅទីក្រុងភ្នំពេញ ។ លើសពីនេះទៀត ពួកវាបានបញ្ជូននាវាទី៧ រួម មានទាំងកប៉ាល់ដឹកឧទ្ធម្ភាគចក្រអូឃីនណាវ៉ា រួមជាមួយនឹងទាហានជើងទឹកជាច្រើនពាក់នាក់ទៅកាន់ឈូង សមុទ្រថៃ ដើម្បីត្រៀមក្នុងការអន្តរាគមន៍ចូលក្នុងកម្ពុជានៅពេលណាមួយ ។

ដូច្នេះផ្ទុយស្រឡះពីការបញ្ចប់ការឈ្លានពាននៃចក្រពត្តិអាមេរិក រដ្ឋការហ្វត-ឃីស៊ីងជ័រ កំពុងតែ បន្តនូវការធ្វើកម្ពុជានីយកម្មនៃសង្គ្រាម ហើយសាបព្រោះនូវការបំផ្លិចបំផ្លាញ និងទុក្ខវេទនាក្នុងគោល បំណងរក្សានូវអាណានិគមនិយមអាមេរិកនៅកម្ពុជា ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

នៅក្នុងឱកាសដ៏ឱឡារិកនៃខួបលើកទី៥ នៃការចាប់បដិសន្ធិរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមធ្វើការគូសបញ្ជាក់ជាថ្មីឡើងវិញថា គោលបំណងនៃការតស៊ូរបស់ប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជា គឺជាការបង្កើតឡើងវិញនូវកម្ពុជាដែលឯករាជ្យ បូរណភាព សន្តិភាព អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ។ តាមពិតប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា បានប្ដេជ្ញាចិត្តបន្តការតស៊ូយ៉ាងត្រឹមត្រូវរបស់ពួកគេ រហូតទាល់តែបញ្ចប់បាននូវរាល់ការជ្រៀតជ្រែកដោយផ្ទាល់ ឬដោយប្រយោលរបស់ចក្រពត្តិអាមេរិក ។ ការជ្រៀតជ្រែកទាំងងងើលដោយរដ្ឋការហ្វូត-ឃីស៊ីងជ័រ និងជំនួយពួកវា ព្រមទាំងការបន្តគាំទ្រយ៉ាងចចេស ជួយដល់ពួកជនក្បត់ជាតិនៅភ្នំពេញ មិនអាចរារាំងប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់ពួកគេ រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មិនឲ្យផ្ដួលរំលំដ៏ជោគជ័យទោះជាក្នុងតម្លៃណាក៏ដោយ នូវអត្ថិភាពនៃបណ្ដាជនក្បត់ទាំងនោះបានឡើយ ហើយទាំងអស់នេះ បានកាន់តែពង្រឹងឡើងថែមទៀត នូវការប្ដេជ្ញាចិត្តរបស់ពួកគេ ដើម្បីធ្វើការតស៊ូយ៉ាងត្រឹមត្រូវ ដោយគ្មានការសម្របសម្រួល ឬដកថយ រហូតដល់សម្រេចបានទាំងស្រុងនូវគោលការណ៍៥ចំណុច នៃសេចក្ដីប្រកាសថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ របស់សម្ដេចសីហនុ ប្រមុខរដ្ឋ និងជាប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា ។ កិច្ចការកម្ពុជាត្រូវតែបានដោះស្រាយដោយគ្មានការអន្តរាគមន៍របស់បរទេស ត្រូវដោះស្រាយដោយប្រជាជនដោយខ្លួនឯង--ដែលជាតំណាងតែមួយគត់ និងស្របច្បាប់ពួកគេ គឺរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានសម្ដេចប៉ែន នុត ជានាយករដ្ឋមន្ត្រី និងលោកខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី ។ ដោយមានកងកម្លាំងស្នេហាជាតិទាំងអស់នៃប្រជាជាតិ ដែលមានតំណាងរបស់ពួកគេនៅក្នុងជួររាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក្នុងរយៈពេល៥ឆ្នាំនៃការតស៊ូកន្លងមក បានបង្ហាញនូវភាពចាស់ទុំ និងលក្ខណៈសម្បត្តិពេញលេញ សម្រាប់គ្រប់គ្រងដោយជោគជ័យនូវកិច្ចការរដ្ឋទាំងអស់ ។

សង្គ្រាមនៅក្នុងប្រទេសកម្ពុជានឹងត្រូវបញ្ចប់ ហើយសន្តិភាពពិតប្រាកដនឹងបានស្តារឡើងវិញ បន្ទាប់ពីគ្រប់ការជ្រៀតជ្រែកដោយរដ្ឋការហ្វេត-ឃីស៊ីងជ័របានបញ្ចប់ ។ កិច្ចការរបស់កម្ពុជានឹងត្រូវដោះស្រាយដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ស្របតាមសេចក្តីសម្រេចនៃមហាសន្និបាតជាតិលើកទី២ ។ រាល់សមាជិកទាំងអស់នៃអង្គការចាត់តាំងយោធា និងកងស្ម័គ្រចិត្តទាំងអស់ដែលបម្រើឲ្យរបបពួកក្បត់ជាតិទីក្រុងភ្នំពេញ ត្រូវតែទម្លាក់អាវុធរបស់ពួកគេ ហើយចុះចូលជាមួយនឹងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជា ។ លើកលែងតែពួកក្បត់ជាតិនៅទីក្រុងភ្នំពេញមួយចំនួនតូច ប្រជាពលរដ្ឋម្នាក់ៗមានចំណែករបស់ខ្លួននៅក្នុងសហគមន៍ជាតិ ដើម្បីកសាងកម្ពុជាមួយដែលឯករាជ្យ បូរណភាព សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ ប្រជាធិបតេយ្យ និងសម្បូររុងរឿង ។

រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាសូមអះអាងសាជាថ្មីថា នឹងប្រកាន់ខ្ជាប់ជានិច្ចទៅនឹងគោលនយោបាយក្នុងប្រទេសនៃការសាមគ្គីភាពជាតិដ៏ទូលាយ ដោយគ្មានការបែងចែកវណ្ណៈសង្គម និន្នាការនយោបាយ ឬជំនឿសាសនា ហើយដោយមិនគិតពីអតីតភាពនៃប្រជាពលរដ្ឋម្នាក់ៗ លើកលែងតែពួកក្បត់ជាតិនៅទីក្រុងភ្នំពេញមួយក្តាប់តូចប៉ុណ្ណោះ ។

[00166876]

ស្តីអំពីគោលនយោបាយការបរទេសរបស់ខ្លួន រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមបញ្ជាក់សាជាថ្មីឡើងវិញនូវការអនុវត្តគោលនយោបាយអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធរបស់ខ្លួន ហើយនិងប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍៥ចំណុចនៃសន្តិសហវិជ្ជមាន នៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងបណ្តាប្រទេសដទៃទៀតទាំងជិតទាំងឆ្ងាយ ដោយគ្មានការបែងចែកប្រព័ន្ធនយោបាយ និងសង្គម ហើយឈរលើគោល

ការណ៍សមភាព គោរពគ្នាទៅវិញទៅមក បម្រើផលប្រយោជន៍គ្នាទៅវិញទៅមក មិនឈ្លានពាន និងមិនជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ។

ប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជារបស់ពួកគេ ជាថ្មីម្តងទៀត សូមថ្លែងអំណរគុណយ៉ាងកក់ក្តៅដល់បណ្តារដ្ឋាភិបាល និងប្រទេសជាមិត្ត បណ្តាប្រជាជនដែលស្រឡាញ់សន្តិភាព និងយុត្តិធម៌ នៅក្នុងសហរដ្ឋអាមេរិក និងនៅទូទាំងពិភពលោក ព្រមទាំងអង្គការប្រជាធិបតេយ្យជាតិ និងអន្តរជាតិទាំងអស់ ដែលបានផ្តល់ជំនួយ និងការគាំទ្រដល់ការតស៊ូយ៉ាងត្រឹមត្រូវ ដើម្បីការរំដោះជាតិ និងជឿជាក់ថា ជំនួយ និងការគាំទ្រនេះ នឹងបន្តកើនឡើងជាបន្តបន្ទាប់ រហូតដល់សម្រេចបានជោគជ័យទាំងស្រុង ។

ដើម្បីបន្ថយនូវទុក្ខវេទនា និងគ្រោះអាសន្ននៃប្រជាជាតិ និងប្រជាជនកម្ពុជា និងដើម្បីស្តារឡើងវិញនូវសន្តិភាពពិតប្រាកដ និងយូរអង្វែងនៅកម្ពុជាឲ្យបានកាន់តែឆាប់ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមអំពាវនាវដល់សមាជិកអង្គការឃោធា និងស្វ័យត្រាណរបស់របបផ្តាច់ការនៅភ្នំពេញ ឲ្យបោះបង់ចោលជួររបស់ពួកគេ ហើយបែរចុងកាំភ្លើងរបស់គេតម្រង់ទៅពួកក្បត់ជាតិទាំងនោះវិញ ។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមអំពាវនាវដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ គ្រប់ឋានៈ នៅក្នុងកន្លែងដែលកាន់កាប់បណ្តោះអាសន្នដោយខ្មាំង ងើបឡើងសាមគ្គីគ្នា ហើយធ្វើការប្រយុទ្ធគ្រប់រូបភាពទៅលើក្រុមពួកក្បត់ជាតិដើម្បីកម្ទេចវា ។ សូមឲ្យប្រជាជនកម្ពុជាទាំងមូល សហការគ្នាជិតស្និទ្ធជាមួយនឹងកងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនកម្ពុជានៅឯសមរភូមិមុខ ក៏ដូចជានៅសមរភូមិក្រោយ នៅក្នុងតំបន់រំដោះ ក៏ដូចជានៅក្នុងកន្លែងដែលខ្មាំងកាន់កាប់បណ្តោះអាសន្ន បង្កើននូវការសកម្មប្រយុទ្ធទ្វេឡើង និងបង្កើនការតស៊ូទ្វេឡើងប្រឆាំងនឹងពួកឈ្លានពានចក្រពត្តិអាមេរិក និងអាយ៉ងពួកវា--ពួកក្បត់ជាតិនៅទីក្រុងភ្នំពេញ--ដើម្បីរំដោះឲ្យបានទាំងស្រុងនូវប្រជាជាតិ និងប្រជាជនកម្ពុជាជារៀងរហូត!

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166878]

សីហនុប្រកាសថា “ជនមហាក្បត” ២១នាក់ទៀត ត្រូវយកមកកាត់ទោស

ប៉ារីស AFP ជាភាសាអង់គ្លេស ម៉ោង១១៥១ ម៉ោងសកល GMT ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៥ OW

[អត្ថបទ] ប៉េកាំងថ្ងៃទី២៦ ខែមីនា (AFP)--សម្តេចនរោត្តម សីហនុ ប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជាថ្ងៃនេះបានប្រកាសឈ្មោះ “ជនមហាក្បត់” កម្ពុជាចំនួន២១រូប ដែលនឹងត្រូវធ្វើការកាត់ទោសជា “ឧក្រិដ្ឋជនសង្គ្រាម” ។ ព្រះអង្គបន្ថែមពួកជននេះទៅក្នុងបញ្ជីនៃ “ជនមហាក្បត់ជាតិ” ទាំង៧រូបដែលត្រូវបានផ្តន្ទាទោសដល់ជីវិតពីសំណាក់ខ្មែរក្រហម ។


នៅថ្ងៃទី១៣ ខែមីនា កាំភ្លើងគ្រប់ប្រភេទទាំងអស់របស់ ក.រ.ជ.ប.ក. បានបាញ់ផ្ទោងយ៉ាងខ្លាំងក្លា ទៅលើមូលដ្ឋានពោធិ៍ចិនតុង។ ទីតាំងយោធាជាច្រើន ត្រូវបានបំផ្លាញ ហើយឃ្លាំងដែលស្តុកពេញទៅដោយគ្រាប់រំសេវដែលទើបតែត្រូវបានផ្គត់ផ្គង់ថ្មីៗត្រូវបានឆាបឆេះ និងផ្ទុះ។ យន្តហោះជាច្រើនគ្រឿង បានឆេះ ឬត្រូវ

បានធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរ ដោយបានបញ្ឈប់ការដឹកជញ្ជូនតាមយន្តហោះដោយចក្រពត្តិអាមេរិក ពីព្រោះយន្តហោះ DC-8 និង C-130 ដែលធ្លាប់ចុះចត លែងហ៊ានប្រថុយគ្រោះថ្នាក់ទៀតហើយ។

ស្ថានភាពនេះបានធ្វើឲ្យខ្មាំង ដោយរួមទាំងចក្រពត្តិអាមេរិក និងជនក្បត់ទាំង៧នាក់ ភ័យស្លន់ស្លោ។ ស្តុកស្រូវអង្ករស្ទើរតែអស់រលីង ហើយគ្រាប់រំសេវ ដែលមានការខ្វះខាតរួចទៅហើយ គឺកាន់តែខ្សត់ នាពេលឥឡូវនេះ។ ស្តុកប្រេងឥន្ធនៈក៏អស់ផងដែរ។ ផ្លូវផ្គត់ផ្គង់ទាំងផ្លូវគោកនិងផ្លូវទឹកទាំងអស់ ត្រូវបានកាត់ផ្តាច់ ហើយផ្លូវអាកាសក៏ត្រូវបានកាត់ផ្តាច់ផងដែរនាពេលឥឡូវនេះ។ បុគ្គលិកស្ថានទូតបរទេស និងអ្នកសារព័ត៌មានបរទេស កំពុងចាកចេញពីទីក្រុងភ្នំពេញយ៉ាងប្រញ៉ាប់ប្រញ៉ាល់។

ស្ថានភាពដែលបនក្បត់ភ្នំពេញកំពុងប្រឈម គឺពិតជាធ្ងន់ធ្ងរបំផុត។ អា សូស្តែន ហ្វែរណង់ដែស (Sostene Fernandez) បានធ្លាក់ពីមុខតំណែង ហើយអ្នកជំនួសវា គឺអាយ៉ង សាក់ ស៊ុតសាខន ដែលគ្រាន់តែជាមនុស្សកំសាកតែប៉ុណ្ណោះ។ កងទ័ពរបស់ជនក្បត់ទាំងមូល កំពុងភ័យស្លន់ស្លោ និងកំពុងត្រូវបានហ៊ុមព័ទ្ធ។ ចំណែកងឯ ឡុង បូរ៉េត ដែលត្រូវបានចក្រពត្តិអាមេរិកបញ្ជាឲ្យបង្កើតគណៈរដ្ឋមន្ត្រីក្បត់ថ្មីមួយ កំពុងប្រឈមនឹងភាពទាល់ច្រក មន្ត្រីយោធា និងអ្នកនយោបាយ កំពុងប្រមូលផ្តុំកម្លាំងរបស់ពួកគេប្រឆាំងនឹងជនក្បត់ទាំង៧នាក់។

ព្រះតេជគុណ និងបងប្អូនជនរួមជាតិជាទីស្រឡាញ់ បងប្អូនកម្មករ ពលករ យុវជនយុវនារី សិស្ស និស្សិត លោកគ្រូអ្នកគ្រូជាទីស្រឡាញ់ និងបងប្អូនមន្ត្រីយោធា កងទ័ព មន្ត្រីរដ្ឋការ អ្នកនយោបាយ និងមន្ត្រីជាន់ខ្ពស់នៅក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួនតូចផ្សេងទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ជាទីស្រឡាញ់៖

ពេលវេលាបានមកដល់ហើយ ហើយស្ថានភាពគឺពិតជាអំណោយផល។ ក.រ.ជ.ប.ក. របស់យើងបានខិតចូលមកជិតបងប្អូនហើយ។ បងប្អូនត្រូវរួបរួមគ្នា កាន់អាវុធ វាយប្រហារហាងទំនិញរបស់ជនក្បត់ បំផ្លាញ

មូលដ្ឋានយោធារបស់ពួកគេ ជំរុំយោធា សាលាក្រុង មន្ទីររបស់អភិបាលខេត្ត និង បំផ្លាញស្ថាប័នសេដ្ឋកិច្ចនយោបាយ យោធា របស់ពួកគេទាំងអស់ និងផ្តួលរំលំជនក្បត់។ តាមវិធីសាស្ត្រនេះ ទុក្ខវេទនារបស់បងប្អូននឹងចប់យ៉ាងឆាប់រហ័ស ហើយសន្តិភាពនឹងត្រូវស្តារឡើងវិញយ៉ាងឆាប់រហ័ស។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166842]

## អ្នកបាញ់កាំភ្លើងដាក់ពោធិ៍ចិនតុងត្រូវបានកោតសរសើរ

សម្លេងរបស់ រ.រ.ជ.ក. (សម្ងាត់) ដែលផ្សាយជាភាសាខ្មែរទៅកាន់ប្រទេសកម្ពុជា នាម៉ោង៤.00 ម៉ោងសកល នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ បាងកក។

[អត្ថបទ] ដៃដ៏ល្អអស្ចារ្យរបស់អ្នកបាញ់កាំភ្លើងរបស់ ក.រ.ជ.ប.ក. នៅសមរភូមិភាគខាងលិចក្រុងភ្នំពេញ ដែលបានធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាប្រឆាំងពោធិ៍ចិនតុង បានធ្វើឱ្យការទំនាក់ទំនងតាមផ្លូវអាកាសរបស់ចក្រពត្តិអាមេរិកត្រូវបានកាត់ផ្តាច់ទាំងស្រុងចាប់តាំងពីថ្ងៃទី១៣ ខែមីនា។

នៅថ្ងៃទី១៣ ខែមីនា កម្លាំងប្រដាប់អាវុធរបស់យើងបានបាញ់ផ្តោងដាក់មូលដ្ឋានទ័ពអាកាសរបស់ខ្មាំង នៅពោធិ៍ចិនតុង ដោយបាញ់គ្រាប់រ៉ុកកែត និងកាំភ្លើងធំយ៉ាងសន្ធាប់ ដោយបំផ្លាញយន្តហោះ៤គ្រឿង រួមទាំងយន្តហោះប្រតិកម្ម DC-8 មួយគ្រឿង និងយន្តហោះ C-130 មួយគ្រឿង របស់ចក្រពត្តិអាមេរិក។ ឃ្លាំងគ្រាប់រំសេវចំនួន៥ ដែលមានគ្រាប់រំសេវរាប់ពាន់បង់ បានផ្ទុះយ៉ាងកងរំពងនៅក្នុងកំឡុងពេលនៃការផ្ទុះបន្ទាប់យ៉ាងច្រើនដែលកើតមានចាប់ពីម៉ោង៩.00 រហូតដល់ម៉ោង១៧.00។ ឃ្លាំងអង្ករចំនួន២ ត្រូវបានបំផ្លាញដោយអគ្គីភ័យ និងឃ្លាំងស្តុកប្រេងឥន្ធនៈមួយបានឆេះ ដែលបញ្ចេញអណ្តាតភ្លើងនិងផ្សែងខ្មៅទៅលើអាកាសអស់រយៈពេលជាង២៤ម៉ោង។ យន្តហោះមួយចំនួនផ្សេងទៀត ត្រូវបានបំផ្លាញ ហើយអ្នកបើកបរយន្តហោះ អ្នកបច្ចេកទេសគ្រឿងយន្ត និងកម្មករយោធាខ្មាំងជាង១៥0នាក់ដែលត្រូវបានបញ្ជូនទៅជញ្ជូនគ្រាប់រំសេវដែលត្រូវបានដឹកមកតាមយន្តហោះ ត្រូវបានសម្លាប់ ឬរងរបួស។ ហេតុដូច្នេះ ពោធិ៍ចិនតុងត្រូវបានបិទ។ ពុំមានយន្តហោះខ្មាំងណាមួយអាចហោះឡើង នោះឡើយ ហើយពុំមានយន្តហោះដឹកជំនួយអាមេរិកណាមួយហ៊ានចុះចតផងដែរ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

នេះគឺជាភាពអស្ចារ្យមួយទៀតនៃថ្វីដៃរបស់អ្នកកាន់កាំភ្លើងដ៏ក្លាហានរបស់ ក.រ.ជ.ប.ក. នៅសមរភូមិភាគខាងលិចនៃទីក្រុងភ្នំពេញ។ ប្រជាជនរបស់យើងនៅទូទាំងប្រទេស ស្វាគមន៍ជោគជ័យរបស់ពួកគេយ៉ាងកក់ក្តៅ និងអបអរសាទរចំពោះពួកគេអស់ពីដួងចិត្ត។ ជ័យយោ សមរភូមិភាគខាងលិចភ្នំពេញរបស់ ក.រ.ជ.ប.ក. ដ៏អង់អាចនិងជោគជ័យ។

## "សេចក្តីអំពាវនាវបន្ទាន់" ថ្ងៃទី១៧ ខែមីនា

សម្លេងរបស់ រ.រ.ជ.ក. (សម្ងាត់) ដែលផ្សាយជាភាសាខ្មែរទៅកាន់ប្រទេសកម្ពុជា នាម៉ោង៤.00 ម៉ោងសកល នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ បាងកក។

[អត្ថបទ] ព្រះតេជគុណគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិជាទីស្រឡាញ់ ប្រជាជន កម្មករ យុវជនយុវនារី និស្សិត លោកគ្រូអ្នកគ្រូ មន្ត្រី យុទ្ធជន នគរបាល អាវុធហត្ថ កុម្ម៉ង់ដូ ឈ្លប អ្នកនយោបាយ មនុស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់ សមជិកថ្នាក់ទាប និងថ្នាក់ខ្ពស់ទាំងអស់នៃគ្រប់ស្ថាប័ន របស់របបជនក្បត់នៅទីក្រុងភ្នំពេញ និងទីរួមខេត្តដ៏ទៃទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង៖ រ.រ.ជ.ក. រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និង ក.រ.ជ.ប.ក. សូមធ្វើការអំពាវនាវជាបន្ទាន់ដូចខាងក្រោម ទៅកាន់បងប្អូន៖

១. ដល់ពេលវេលាដែលបងប្អូនត្រូវរួបរួមគ្នា និងងើបឡើងដើម្បីផ្តួលរំលំរបបនេះ និងជនក្បត់ទាំង៧នាក់។ ឥឡូវនេះ ក.រ.ជ.ប.ក. របស់យើង កំពុងឡោមព័ទ្ធ និងវាយប្រហារ ជនក្បត់ទាំង៧ ពីគ្រប់ទិសទាំងអស់។ ក.រ.ជ.ប.ក. កំពុងរង់ចាំតែពេលវេលាតែប៉ុណ្ណោះ ដើម្បីកម្ទេចពួកគេទាំងស្រុង។ ផ្លូវទឹកនិងផ្លូវគោកទាំងអស់ត្រូវបានរាំងខ្ទប់ទាំងស្រុង។ ចាប់តាំងពីថ្ងៃទី១៣ ខែមីនា អាកាសយានដ្ឋានពោធិ៍ចិនតុង ក៏ត្រូវបានបិទទាំងស្រុងផងដែរ។ ជនក្បត់មិនមានស្បៀង ប្រេងឥន្ធនៈ ឬគ្រាប់រំសេវ នៅសល់ទៀតនោះឡើយ។

[00166843]

Original EN: 00166779-00166887

Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ប្រជាជនអាមេរិក និងសភាអាមេរិក កំពុងកាត់ផ្តាច់ជំនួយសម្រាប់ពួកក្បត់។ មិនថាពួកចក្រពត្តិអាមេរិក រឹងរូសប៉ុណ្ណានោះឡើយ ពួកគេមិនអាចទប់ស្កាត់បនក្បត់ លន់ ណុល សិរិមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត សូស្តែន ហ្វែរណាង់ដែស (Sostene Fernandez) មិនឲ្យដួលរលំនោះឡើយ។ យើងនឹងបញ្ចប់អត្ថិភាពរបស់ជនក្បត់ទាំង៧នាក់ ដើម្បីបញ្ចប់ទុក្ខវេទនាដែលមិនអាចរៀបរាប់បានរបស់ព្រះសង្ឃ និងបងប្អូនរបស់យើង ជាតិនិងប្រជាជនរបស់យើង និងដើម្បីកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជាភ្លាម។

២. ដើម្បីសម្រេចគោលដៅនេះ បងប្អូនត្រូវប្រើប្រាស់គ្រប់ទម្រង់នៃការតស៊ូទាំងអស់ដើម្បីវាយប្រហារជនក្បត់ពីខាក្នុងទីក្រុងភ្នំពេញ និងពីខាងក្នុងទីរួមខេត្តផ្សេងៗទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ពួកគេ ដូចជាតាមរយៈ ការរៀបចំកិច្ចប្រជុំ ការចេញសេចក្តីថ្លែងការណ៍ថ្កោលទោសនិងបដេសេធពួកគេ ការធ្វើកូដកម្ម ការធ្វើពហិកាមិនចូលរៀន ការធ្វើបាតុកម្មក្នុងទ្រង់ទ្រាយធំនិងតូចដើម្បីប្រឆាំងនឹងកំណែនយោធា ការអត់អាហារនិងការឡើងតម្លៃទំនិញ ការប្រមូលកម្លាំងដើម្បីវាយប្រហារឃ្លាំងអង្ករ ឃ្លាំងសហករណ៍ ឃ្លាំងសូម៉ិចស៊ីម (ក្រុមហ៊ុនអាហារ័ណ នីហរ័ណជាតិ) ឃ្លាំងសុរ៉ាប៉ា (ក្រុមហ៊ុនប្រមូលផលស្រូវ) និងឃ្លាំងរបស់ក្រុងនិងខេត្ត និងតាមរយៈការរឹបអូសអាវុធរបស់ខ្មាំងដើម្បីវាយប្រហារពួកវាវិញ។ បងប្អូនដែលទទួលខុសត្រូវគ្រប់គ្រងអាវុធ រថយន្តការពារគ្រាប់ យន្តហោះ អាវុធធុនតូច ឬកាំភ្លើងធំត្រូវបានស្នើឲ្យវាយប្រហារនិងបំផ្លាញទីតាំង ជំរុំ មូលដ្ឋានជួរមុខ សាលាក្រុង សាលារដ្ឋបាលខេត្ត មន្ទីរ ទីបញ្ជាការជាន់ខ្ពស់ វិមាន ភូមិគ្រឹះ ស្ថានីយ៍វិទ្យុ ទាំងអស់ និងទីតាំងសេដ្ឋកិច្ច នយោបាយ និងយោធារបស់ខ្មាំងទាំងអស់។ នៅពេលអ្នកឃើញជនក្បត់ លន់ ណុល សិរិមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និង សូស្តែន ហ្វែរណាង់ដែស (Sostene Fernandez) នៅទីកន្លែងណាក៏ដោយ អ្នកត្រូវកម្ទេចពួកគេនៅនឹងកន្លែង ដែលនេះនឹងរួមចំណែកយ៉ាងធំធេងដល់ការរំដោះប្រទេសជាតិ និងប្រជាជនរបស់យើង។

៣. អ្នកអាចធ្វើការរួមចំណែកសមរម្យភ្លាមៗតាមរយៈការបដិសេធពុំសហការជាមួយជនក្បត់ទាំង៧។ តាមរយៈការអនុវត្តបែបនេះ អ្នកពិតជាត្រូវចាត់ទុកថាស្ថិតនៅក្នុងចំណោមប្រជាជនរបស់យើង និង រ.រ.ជ.

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ក.។ ប្រសិនបើចាំបាច់ អ្នកត្រូវរត់ឆ្លងចូលទៅតំបន់រំដោះភ្លាម។ ប្រជាជន យុទ្ធជននិងកម្មាភិបាលទាំងពីរភេទ របស់យើងនឹងទទួលស្វាគមន៍អ្នកយ៉ាងកក់ក្តៅ។ ទន្ទឹមគ្នានេះ យើងសូមអំពាវនាវឲ្យមិត្តភក្តិបរទេស និងស្ថានទូតបរទេសទាំងអស់ដែលកំពុងស្ថិតនៅក្នុងទីក្រុងភ្នំពេញ និងទីក្រុងដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ជម្លៀសចេញយ៉ាងឆាប់រហ័សដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ។

[00166845]

## សារព័ត៌មាន AFP រាយការណ៍អំពីសកម្មភាពសង្គ្រាមនៅភ្នំពេញ និងអ្នកលឿង

ទីក្រុងហុងកុង សារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោងសកល ០៩៣០ ថ្ងៃទី២៨ ខែមីនា ឆ្នាំ ៧៥

[សេចក្ដីដកស្រង់] ភ្នំពេញ ថ្ងៃទី២៨ ខែ មីនា (AFP)--កម្លាំងខ្មែរក្រហមបានបង្កើនសម្ពាធប្រឆាំងទីក្រុងភ្នំពេញ ដោយបើកមុខព្រួញពីរថែមទៀតនៅជិតទីក្រុងនេះដែលកំពុងស្ថិតនៅក្រោមការឡោមព័ទ្ធ គឺមុខព្រួញមួយនៅចម្ងាយតែ ៧ គីឡូម៉ែត្រ (៤មៃល៍) ខាងកើតពីកណ្ដាលក្រុងភ្នំពេញ និងមួយទៀតនៅចម្ងាយ ២៥គីឡូម៉ែត្រ (១៥មៃល៍) នៅភាគឥសាន។ ទន្ទឹមពេលនេះដែរ ការប្រយុទ្ធគ្នាកំពុងតែបន្តនៅថ្ងៃនេះ នៅជិតអ្នកលឿន ជាមូលដ្ឋានឆ្លងកាត់ទន្លេមេគង្គដ៏សំខាន់ ចម្ងាយ ៦០គីឡូម៉ែត្រ (៤០មៃល៍)ខាងត្បូងភ្នំពេញ និងនៅភូមិសំខាន់មួយគឺទួលលាប ដែលស្ថិតក្នុងចម្ងាយបាញ់គ្រប់រ៉ុកែត និងកាំភ្លើងធំចូលទៅព្រលានយន្តហោះពោធិ៍ចិនតុង នៅភ្នំពេញ។

ទាហានរដ្ឋាភិបាលចំនួនប្រហែល ៣ ពាន់នាក់ត្រូវបានឡោមព័ទ្ធនៅអ្នកលឿង ហើយសេចក្ដីរាយការណ៍នានាពីយោធាដែលបានទៅដល់ទីនេះ បាននិយាយថា ទាហានទាំងនោះគឺជាគោលដៅនៃការបាញ់កាំភ្លើងធំយ៉ាងខ្លាំងក្លាដែលបានសម្លាប់មនុស្ស ២៣ នាក់ និងធ្វើឱ្យរបួស ៥៦ នាក់នៅអ្នកលឿង ព្រមទាំងសម្លាប់មនុស្ស ១៥ នាក់ផ្សេងទៀត និងធ្វើឱ្យរបួសប្រហែលជាង ១០នាក់ទៀតក្នុងចំណោមកម្លាំងទ័ពជើងទឹកឈរជើងនៅលើកោះមួយនៅជិតអ្នកលឿង។

ទោះបីជាមានការវាយបកវិញពីទាហានរដ្ឋាភិបាលកាលពីម្សិលមិញក៏ដោយ ក៏ខ្មែរក្រហមនៅតែបន្តវាយសម្រុកបាញ់រ៉ុកកែត ១០៨ មម ទៅលើព្រលានយន្តហោះពោធិ៍ចិនតុង គឺបាញ់ពីទីតាំងបាញ់រ៉ុកកែតនៅជិតភូមិទួលលាប។ កាលពីម្សិលមិញ រ៉ុកកែតប្រហែលជា ៥-៦ គ្រាប់បានធ្លាក់ចូលព្រលានយន្តហោះ ដែលជាមធ្យោបាយទំនាក់ទំនងតែមួយគត់របស់ភ្នំពេញ ជាមួយនឹងពិភពលោកខាងក្រៅ។

Original EN: 00166779-00166887

Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

នៅពេលយប់ និងពេលព្រឹកថ្ងៃនេះ រ៉ុកកែតប្រហែល ៣០ គ្រាប់បានបាញ់ចូលមូលដ្ឋានកងទ័ពជើងទឹក ជ្រោយចង្វារ នៅលើតំបន់ជ្រោយរវាងទន្លេមេគង្គ និងទន្លេសាប នៅទល់មុខភ្នំពេញ។ រ៉ុកកែតពីរគ្រាប់ទៀត បានធ្លាក់ចូលតំបន់ស្ថានទូតបារាំង។

**វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា លម្អិតអំពីសកម្មភាពសង្គ្រាមថ្ងៃទី១២-១៦ ខែមីនា**

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ភ្នំពេញ (សម្ងាត់) ជាភាសាខ្មែរប្រចាំប្រទេសកម្ពុជា ម៉ោងសកល ០៧០០ ថ្ងៃទី១៨ ខែ មីនា ឆ្នាំ ៧៥

[សេចក្តីដកស្រង់] អំពីសមរភូមិជួរមុខទន្លេមេគង្គនៅខាងក្រោមភ្នំពេញ៖

១. អ្នកលឿង នៅត្រើយខាងកើតទន្លេងមេគង្គ៖ នៅយប់ថ្ងៃទី១៥-១៦ ខែមីនា យើងបានវាយសម្រុក ជើងគោក និងកាំភ្លើងធំយ៉ាងធ្ងន់ធ្ងរទៅលើខ្មាំង។ យោងតាមសេចក្តីរាយការណ៍ជាដំបូង យើងបានបំផ្លាញ ទីតាំងខ្មាំងពីរកន្លែងនៅភាគអាគ្នេយ៍អ្នកលឿង។ ក្រោយពីបានបំបែកខ្សែការពាររបស់ខ្មាំងពីត្រើយខាងនេះ យើងបានទៅជិតដល់ជំរុំកងពលទី ៤។ នៅត្រើយម្ខាងទៀត យើងជិតដល់ជំនុំខ្មាំងដែលមានឃ្លាំងសម្ភារៈ។

[00166846]

ទន្ទឹមពេលគ្នានេះដែរ យើងបានបាញ់កាំភ្លើងធំយ៉ាងធ្ងន់ធ្ងរទៅលើមូលដ្ឋានកងទ័ពជើងទឹករបស់ខ្មាំង ដោយ បានបំផ្លាញបន្ទាយទាហានមួយចំនួន។ នៅក្នុងការវាយប្រហារជើងគោក និងកាំភ្លើងធំទាំងនេះ យើងបាន សម្លាប់ ឬធ្វើឲ្យរបួសកងទ័ពជើងទឹកចំនួនជាង ១២០ នាក់។ យោងតាមសេចក្តីរាយការណ៍ចុងក្រោយពី មូលដ្ឋានបានឲ្យដឹងថា ក្រោយពីទទួលរងបរាជ័យយ៉ាងឈឺចាប់នៅសមរភូមិមុខអ្នកលឿង រួចមក ឧត្តម សេនីយ៍ ណុប ប៉ារ៉ាម៉ូន (Nob Paramoun) ចៅហ្វាខេត្តស្វាយរៀង និងជាមេបញ្ជាការរួមនៅអ្នកលឿង

បានរត់គេចខ្លួនទៅភ្នំពេញ។ គាត់កំពុងទទួលការព្យាបាលនៅក្នុងមន្ទីរមួយកន្លែងនៅភ្នំពេញ ដោយសារជំងឺចាញ់សង្គ្រាម។ គាត់ត្រូវបានដកតួនាទីដោយឧត្តមសេនីយ៍ លឹម ស៊ីស្អាត់ (Lim Sisaath)។

ប៉ុន្តែ ឧត្តមសេនីយ៍កំសាកនេះមិនហ៊ានទៅអ្នកលឿង ទេ។ ទីបញ្ជាការរបស់គាត់គឺនៅភ្នំពេញ។ ហេតុនេះ អ្នកលឿងត្រូវបានដាក់ឲ្យនៅឯកា និងស្ថិតក្រោមការឡោមព័ទ្ធទាំងស្រុង រងការវាយប្រហារយ៉ាងធ្ងន់ធ្ងរពីគ្រប់ទិសទាំងអស់។ ឥឡូវនេះ គ្មានឧទ្ធម្ភាគចក្រអាចចុះចតនៅអ្នកលឿងបានទេ ដោយសារការបាញ់កាំភ្លើងធំឥតប្រណី និងចំគោលដៅរបស់យើងនៅតាមផ្លូវ។

២. កំពង់ចម្លងអ្នកលឿង នៅត្រើយខាងលិចទន្លេមេគង្គ៖ នៅថ្ងៃទី១៥ ខែមីនា នេះដែរ យើងបានបំផ្លាញខ្មែចខ្មី និងបានរំដោះទាំងស្រុងជាលើកទីពីរនូវទីតាំងមួយប្រព័ន្ធនៅកំពង់ចម្លងអ្នកលឿង នៅត្រើយខាងលិច។ យើងបានរំដោះទីតាំងមួយប្រព័ន្ធនេះម្តងកាលពីថ្ងៃទី២ ខែមីនា ហើយបាន(កម្ចាត់?) កងវរសេនាតូចលេខ ២៩ និង ២៥៨ នៃកងពលលេខ ៦៩ ដែលឈរជើងនៅកំពង់ចម្លងនេះ។ នៅម៉ោង១៨00 ថ្ងៃទី១៥ ខែមីនា យើងបានកម្ចាត់កងវរសេនាតូចទាំងពីរនេះទាំងស្រុង។ កងទ័ពខ្មាំងជាង ៧0 នាក់ត្រូវបានសម្លាប់នៅហ្នឹងកន្លែង ចំណែកឯអ្នកនៅរស់លោតចូលទន្លេ ហើយលង់ទឹកស្លាប់។ យើងដណ្តើមបានកាំភ្លើង ១៤៧ដើម គ្រាប់ជាង ៣ តោន វិទ្យុ ៦ គ្រឿង និងរថយន្តពីរគ្រឿង។

៣. បាណន់៖យោងតាមសេចក្តីរាយការណ៍បន្ថែមបានឲ្យដឹងថា នៅយប់ថ្ងៃទី១២ ខែមីនា យើងបានបង្ក្រាប និងរំដោះទីតាំងខ្មាំងបីកន្លែងនៅខ្សែក្រវ៉ាត់ការពារខាងត្បូងបាណន់។ យើងបានសម្លាប់ទ័ពខ្មាំងចំនួន ៣0 នាក់ ដុតឆេះឡានពាសដែកមួយគ្រឿង ហើយដណ្តើមបានអាវុធ ២១ ដើម និងគ្រាប់ជាងមួយតោន។

៤. នៅតាមដងទន្លេមេគង្គខាងលើអ្នកលឿង៖ យោងតាមសេចក្តីរាយការណ៍បន្ថែមពីមូលដ្ឋានបានឲ្យដឹងថា មានការស្ទាក់ក្បួនកប៉ាល់ខ្មាំងនៅយប់ថ្ងៃទី១៤ និង ១៥ ខែមីនា គឺចាប់បានកប៉ាល់បីគ្រឿង ពន្លិចកប៉ាល់បានមួយគ្រឿង និងធ្វើឲ្យខូចខាតពីរគ្រឿងទៀត។ រួមជាមួយនឹងកប៉ាល់ដែលចាប់បាន យើងក៏ដណ្តើ

មបានកាំភ្លើងធំកាណុង ១០៥ មម មួយដើម។ យើងក៏ដណ្តើមបានគ្រាប់ជាង ២០ តោន និងអង្គុររាប់រយបាវ យើងចាប់បានទ័ពខ្មាំង ១២ នាក់ ហើយទ័ពខ្មាំងសរុបចំនួន ៣០ នាក់ត្រូវបានសម្លាប់ ឬរងរបួស។

តំបន់នៅជុំវិញភ្នំពេញ

១. នៅមុខព្រួញភាគឦសានភ្នំពេញ៖ នៅពុទ្រា និងទួលក្រសាំង៖ នៅថ្ងៃទី១៦ ខែមីនា យើងបានបង្ក្រាប និងរំដោះបានទាំងស្រុងទីតាំងភូមិពុទ្រា។ កងវរសេនាតូចលេខ ២០៥ ត្រូវបានវាយប្រហារ ហើយចាញ់ទាំងស្រុងក៏រត់គេចចេញ។ ខ្មាំងបានរត់គេចចេញ ដោយទុកចោលសាកសពមនុស្ស ១៥ នាក់ដែលត្រូវបានសម្លាប់រួចហើយ ទុកចោលអាវុធ ៩ ដើម ព្រមទាំងគ្រាប់ និងសម្ភារៈជាច្រើន។ ភូមិពុទ្រា មានចម្ងាយតែ ៧ គីឡូម៉ែត្រខាងជើងពោធិ៍ចិនតុង។ នៅថ្ងៃទី ១៦ ខែ មីនា ម៉ោង ១០.០០ យើងក៏បានបាញ់តេ ២៨ មួយគ្រាប់ទៅទួលក្រសាំង ចម្ងាយ៨គីឡូម៉ែត្រខាងជើងពោធិ៍ចិនតុង។ អ្នកបើកយន្តហោះត្រូវបានសម្លាប់។

នៅព្រែកព្នៅ៖ នៅថ្ងៃទី១៥ ខែមីនា យើងបានសម្លាប់ទ័ពខ្មាំង ២៥ នាក់ និងធ្វើឲ្យរបួសប៉ុន្មាននាក់ផ្សេងទៀត នៅខាងលិចព្រែកព្នៅ។ អ្នកនៅរស់បានរត់គេចទៅព្រែកព្នៅ។

២. នៅមុខព្រួញខាងលិចភ្នំពេញ៖ នៅថ្ងៃទី ១៥ ខែ មីនា យើងស្ទាក់ផ្លូវ និងកម្ទេចបានពីរកងនៅកងពលលេខ ៨០ នៅខាងលិច និងនិរតីស្ថានីយ៍រថភ្លើងសំរោង ធ្វើឲ្យពួកវាត្រឡប់ទៅស្ថានីយ៍វិញ។ យើងបានសម្លាប់ទ័ពខ្មាំងចំនួន ១៥ នាក់ និងដណ្តើមបានអាវុធ ៥ ដើម។ យើងបន្តឡោមព័ទ្ធស្ថានីយ៍នេះនៅគ្រប់ទិស។ នៅថ្ងៃទី១៦ ខែមីនា កងកាំភ្លើងធំរបស់យើងបានបន្តបាញ់រ៉ុកកែត និងកាំភ្លើងធំចូលព្រលានយន្តហោះពោធិ៍ចិនតុង។

[00166847]

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

៣. នៅមុខព្រួញភាគនិរតីភ្នំពេញ៖ យើងបន្តរក្សាការគ្រប់គ្រងយ៉ាងរឹងមាំនៅកំណាត់ផ្លូវលេខ ៤ រវាង អង្គស្នួល ទៅកំពង់ស្ពឺ។ យើងក៏បន្តធ្វើឲ្យកងពលលេខ ១៣ និងលេខ ២៧ នៅឯកកាពីមូលដ្ឋានរបស់ខ្លួននៅ ទីរួមខេត្តកំពង់ស្ពឺ។ ទ័ពខ្មាំងដែលនៅកងពលទាំងពីរនេះ បានព្យាយាមធ្វើប្រតិបត្តិការ [ពាក្យអត់ច្បាស់] ប៉ុន្តែ ពួកគេជាប់គាំងនៅតំបន់នោះ។

៤. នៅមុខព្រួញភាគអាគ្នេយ៍ភ្នំពេញ៖ នៅយប់ថ្ងៃទី១៥-១៦ ខែមីនា យើងបានចាប់ផ្តើមធ្វើការវាយ ប្រហារជាបន្តបន្ទាប់លើខ្មាំង នៅត្រើយទាំងសងខាងនៃទន្លេបាសាក់។ នៅត្រើយខាងកើត យើងបានដាក់ សម្ពាធធ្ងន់ធ្ងរលើឫស្សីស្រុក។ នៅត្រើយម្ខាងទៀត យើងបានវាយប្រហារលើខ្មាំងពីកណ្តាលកោះអន្លង់ចិ ន។ សមរភូមិនេះមានទីតាំងចម្ងាយពី ៧ ទៅ ៨ គីឡូម៉ែត្រភាគអាគ្នេយ៍ក្រុងតាខ្មៅ។

[00166849]

**សារព័ត៌មាន AFP៖ កម្លាំងខ្មែរក្រហម កាន់កាប់អ្នកលឿងបានពាក់កណ្តាល**

ទីក្រុងហុងកុង សារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោងសកល ០៤០៨ ថ្ងៃទី២០ ខែមីនា ឆ្នាំ៧៥

[សេចក្តីដកស្រង់] ភ្នំពេញ ថ្ងៃទី២០ ខែមីនា(AFP)--កម្លាំងខ្មែរក្រហមបានចូលកាន់កាប់បានពាក់កណ្តាល នៃតំបន់អ្នកលឿង ជាកំពង់ផែតូចមួយនៅតាមដងទន្លេមេគង្គ ហើយជាតំបន់គ្រប់គ្រងចុងក្រោយរបស់រដ្ឋា ភិបាលនៅត្រើយខាងត្បូងទន្លេ នេះបើតាមសេចក្តីរាយការណ៍ពីប្រភពយោធាបានបង្ហាញនៅព្រឹកថ្ងៃនេះ។ សេចក្តីរាយការណ៍ទាំងនេះនិយាយថា កងទ័ពរដ្ឋាភិបាលចំនួន ២៥០០ នៅអ្នកលឿង បានប្រមូលផ្តុំគ្នាឡើង វិញនៅក្នុងផ្សារ ហើយនៅជុំវិញផ្សារនេះមានការប្រយុទ្ធគ្នាហិង្សាកំពុងកើតឡើងតាំងពីល្ងាចម្សិលម៉ិញ។ គេនិយាយថា កងទ័ពការពាររដ្ឋាភិបាលទាំងនេះបានទទួលរងការស្លាប់ និងរបួសយ៉ាងធ្ងន់ធ្ងរ។

អ្នកលឿងបានស្ថិតនៅក្រោមការឡោមព័ទ្ធរយៈពេលជាងមួយខែមកហើយ ហើយក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ ការបាញ់កាំភ្លើងធំ និងការវាយប្រហារយ៉ាងខ្លាំងលើទីប្រជុំនេះស្ទើរតែធ្វើឲ្យខ្សែការពាររដ្ឋាភិបាលកម្រើកលែងរួចហើយ។ ការបាញ់កាំភ្លើងធំ និងការវាយប្រហារយ៉ាងខ្លាំងនេះធ្វើឲ្យមានការលំបាកកាន់តែខ្លាំងដើម្បីផ្គត់ផ្គង់ទីប្រជុំជនតាមផ្លូវអាកាស។

[00166850]

**លន់ នល់ ប្រកាសគណៈរដ្ឋមន្ត្រីថ្មី នៅថ្ងៃទី២១ ខែមីនា**

សេវាសារព័ត៌មានជាតិនៅភ្នំពេញ(Phnom Penh Domestic Services)ជាភាសាខ្មែរ ម៉ោងសកល ១០៣៨ ថ្ងៃទី២១ ខែមីនា

[អត្ថបទនៃដីកាប្រធានាធិបតីថ្ងៃទី២១ ខែមីនា--អានដោយអ្នកប្រកាសព័ត៌មាន]

[អត្ថបទ] ស្របតាមក្រឹត្យលេខ ១៣៩-៧៥ បរក[PRK] ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៥ ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ --បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ និងក្រឹត្យលេខ ៤៧៤-៧៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៤ វិសោធនកម្មដោយមាត្រាជាបន្តបន្ទាប់អំពីការតែងតាំងគណៈរដ្ឋមន្ត្រី-- ចេញដីកាបង្គាប់ដូចខាងក្រោម៖

| | |
|---|---|
| រដ្ឋមន្ត្រីទីមួយ | ឡុង បូរ៉េត (Long Boret) |
| អនុរដ្ឋមន្ត្រីទីមួយទទួលបន្ទុកកិច្ចការនយោបាយនិងបេសកកម្មពិសេស | ហ្សុង ធនហាក់ |
| អនុរដ្ឋមន្ត្រីទីមួយ និងរដ្ឋមន្ត្រីការពារជាតិ | ឧត្តមសេនីយ៍ឯក សក់ ស៊ុតសាខន (Sak SutSakhan) |
| អនុរដ្ឋមន្ត្រីទីមួយទទួលបន្ទុកការអប់រំ និងទំនាក់ទំនងជាមួយសភា | ប៉ាន សុទ្ធី (Pan Sothiy) |

| | |
|---|---|
| ទេសរដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យរដ្ឋមន្ត្រីទីមួយ កិច្ចការមហាផ្ទៃ ការកៀងគរទូទៅ និងកិច្ចការសាសនា | ហ៊ូ ហុង (Hou Hong) |
| ទេសរដ្ឋមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ផែនការ និងផលិតកម្ម | ឃី តាំងលីម (Khy Taing Lim) |
| ទេសរដ្ឋមន្ត្រីទទួលបន្ទុកសាធារណការ និងពាណិជ្ជកម្ម | ហែម កែតសាណា (Hem Kethsana) |
| រដ្ឋមន្ត្រីក្រសួងកិច្ចការបរទេស | កឹគី លីម (Keuky Lim) |
| រដ្ឋមន្ត្រីក្រសួងសម្របសម្រួលជាតិ | គាម រ៉េត (Keam Reth) |
| រដ្ឋមន្ត្រីក្រសួងជនភៀសខ្លួន សំណង់ និងការអភិវឌ្ឍសហគមន៍ | គង់ អ៊ិន (Kong Orn) |
| រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | លី ខ្វាងប៉ាន់ (Li Khvang Pann) |
| រដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ | លឿង ណាល់ (Loeung Nal) |
| រដ្ឋមន្ត្រីក្រសួងផ្គត់ផ្គង់ និងដឹកជញ្ជូន | អ៊ីវ យ៉ាង (Iv Yang) |
| រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងទេសចរណ៍ | ជាវ ស៊ាងលាន (Cheav Seang Lean) |
| រដ្ឋមន្ត្រីក្រសួងកិច្ចការវប្បធម៌ | ឡុង បុត្រតា (Long Botta) |
| រដ្ឋមន្ត្រីក្រសួងព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍ | ថុង លឹមហួង(ថុង លឹមហួង) |
| រដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ | យ៉ាន ស (Yan Sar) |
| រដ្ឋលេខាធិការផ្នែកពលកម្ម និងសង្គម | ងួន ជាន (Nguon Chean) |
| រដ្ឋលេខាធិការផ្នែកពាណិជ្ជកម្ម | សាំង សារ៉ាត់ (Saing Sarath) |
| រដ្ឋលេខាធិកាផ្នែកកសិកម្ម | អ៊ុង ស៊ីឃុន (Ung Sikhun) |

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

២. សកម្មភាពរបស់គណៈរដ្ឋមន្ត្រីនេះត្រូវស្ថិតនៅក្នុង ៥ ក្រុម ពាក់ព័ន្ធនឹងគោលដៅដែលរដ្ឋាភិបាលត្រូវសម្រេច៖

ក្រុមទី១៖ គោលនយោបាយ និងការកៀងគរទូទៅ៖ ក្រុមនេះធ្វើគោលនយោបាយសម្រាប់ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការសាសនា ក្រសួងកិច្ចការបរទេស ក្រសួងសម្របសម្រួលជាតិ ក្រសួងព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសន្តិសុខជាតិ។

ក្រុមទី២៖ ការពារជាតិ និងប្រព័ន្ធយុត្តិធម៌៖ ក្រុមនេះរួមមានក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ និងក្រសួងសន្តិសុខជាតិ។

ក្រុមទី៣៖ ផ្នែកសង្គម វប្បធម៌ និងយុវជន៖ ក្រុមនេះរួមមានក្រសួងអប់រំ ក្រសួងកិច្ចការវប្បធម៌ ក្រសួងជនភៀសខ្លួន សំណង់ និងការអភិវឌ្ឍសហគមន៍ ក្រសួងសុខាភិបាលសាធារណៈ ផ្នែកពលកម្ម និងកិច្ចការសង្គម។

[00166851]

ក្រុមទី៤៖ ហិរញ្ញវត្ថុ ផែនការ និងផលិតកម្ម៖ ក្រុមនេះរួមមានក្រសួងហិរញ្ញវត្ថុ ផែនការ ក្រសួងឧស្សាហកម្ម ផ្នែកកសិកម្ម និងទេសចរណ៍។

ក្រុមទី៥៖ ផ្គត់ផ្គង់ ដឹកជញ្ជូន និងសាធារណការ៖ ក្រុមនេះមានក្រសួងសាធារណការ ក្រសួងផ្គត់ផ្គង់ និងដឹកជញ្ជូន និងក្រសួងពាណិជ្ជកម្ម។

៣. ឧត្តមសេនីយ៍ឯក សក់ ស៊ុតសាខន ទទួលមុខងារជាអនុរដ្ឋមន្ត្រីទីមួយ និងជារដ្ឋមន្ត្រីការពារជាតិ បន្ថែមពីលើមុខងារជាប្រធានអគ្គសេនាធិការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

៤. នាយកឧទ្ទកាល័យរបស់ប្រធានាធិបតី និងអគ្គលេខាធិការរបស់រដ្ឋាភិបាល ទទួលខុសត្រូវអនុវត្តក្រឹត្យនេះជាបន្ទាន់។

ភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៥

[ហត្ថលេខា] លន់ នល់

**សារព័ត៌មាន AFP៖ ទ័ពរដ្ឋាភិបាល ដកចេញពីទួលលាប**

ទីក្រុងហុងកុង សារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោងសកល ១៤៥៦ ថ្ងៃទី២០ ខែមីនា ឆ្នាំ៧៥ បាងកក

[សេចក្តីដកស្រង់] ភ្នំពេញ ថ្ងៃទី២០ ខែមីនា(AFP)--ប្រភពយោធាមួយបាននិយាយថា នៅថ្ងៃនេះ កងទ័ពរបស់រដ្ឋាភិបាលកម្ពុជា បានបោះបង់ចោលទីតាំងគន្លឹះទួលលាប នៅជិតព្រលានយន្តហោះពោធិ៍ចិនតុង ដែលខ្មែរក្រហម គាំទ្រដោយពួកកុម្មុយនិស្ត ប្រើប្រាស់ជាមូលដ្ឋានដើម្បីវាយប្រហារព្រលានយន្តហោះ រហូតដល់ពេលដែលសម្បានកាន់កាប់វិញកាលពីថ្ងៃសៅរ៍មុន។

[00166864]

## សូមអបអរសាទរយុទ្ធជនទាំងអស់នៃកងទ័ពរំដោះជាតិប្រជាជនកម្ពុជា

សំឡេងវណសិរ្សរួបរួមជាតិកម្ពុជា (សម្ងាត់) ជាភាសាខ្មែរប្រចាំប្រទេសកម្ពុជា ម៉ោងសកល ០៤០០ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ៧៥

[ថ្ងៃទី២៣ ខែមីនា "សារអបអរសាទរ"ពីខៀវ សំផន អនុរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងទ័ពរំដោះជាតិប្រជាជនកម្ពុជា អានដោយអ្នកប្រកាសព័ត៌មាន]

[អត្ថបទ] មិត្តបញ្ជាការគ្រប់ជាន់ថ្នាក់ទាំងអស់ជាទីរាប់អាន! កម្មាភិបាល យុទ្ធជន យុទ្ធនារីទាំងបីប្រភេទនៃកងទ័ពរំដោះជាតិប្រជាជនកម្ពុជានៅក្នុងសមរភូមិទាំងអស់នៅទូទាំងប្រទេសជាទីរាប់អាន! មហាចលនាវាយសម្រុករបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនយើងនៅក្នុងរដូវប្រាំងឆ្នាំ ១៩៧៥ ឥឡូវនេះគឺមានរយៈពេលពីរខែ ២៣ថ្ងៃហើយ។ នៅក្នុងរយៈពេលនេះ មិត្តទាំងឡាយ រួមមាន មិត្តបញ្ជាការគ្រប់ជាន់ថ្នាក់ទាំងអស់ កម្មាភិបាល យុទ្ធជន យុទ្ធនារីទាំងបីប្រភេទនៃកងទ័ពរំដោះជាតិប្រជាជនកម្ពុជា បានធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាបំផុតទៅលើខ្មាំងនៅគ្រប់មុខព្រួញយុទ្ធសាស្ត្រទាំងអស់ គឺទន្លេមេគង្គ និងផ្លូវគមនាគមន៍ផ្សេងទៀត ព្រមទាំងនៅភ្នំពេញ តំបន់ជុំវិញភ្នំពេញ និងទីរួមខេត្តផ្សេងៗ។

នៅក្នុងរយៈពេលដ៏ខ្លីនេះ មិត្តទាំងអស់បានបំផ្លាញទីតាំងខ្មាំងជាច្រើនកន្លែងណាស់ និងទ័ពខ្មាំងអស់ជាច្រើននាក់ណាស់។ ពីខែមករា ដល់ពាក់កណ្តាលខែមីនា ទ័ពខ្មាំងចំនួនជាង ៤៦ ៥០០ នាក់ត្រូវបានសម្លាប់ រងរបួស ចាប់ខ្លួនបាន ឬក៏ចុះចាញ់។ ទីតាំងខ្មាំងតូចធំទាំងអស់គ្រប់ចំនួនជាង ៨០០ កន្លែង ត្រូវបានបង្ក្រាប និងរំដោះ។ តំបន់ទន្លេមេគង្គនៅខាងក្រោមភ្នំពេញ ត្រូវបានរំដោះ ហើយតំបន់ទន្លេងមេគង្គរវាងភ្នំពេញ ទៅព្រំដែនវៀតណាមខាងត្បូង ស្ថិតនៅក្រោមការកាន់កាប់យ៉ាងរឹងមាំរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជា

យើង។ កំណាត់ផ្លូវជាង ៣០គីឡូម៉ែត្រនៅលើផ្លូវលេខ ១ និងទីតាំងខ្មាំងចំនួន ២៥៣ កន្លែងនៅជុំវិញភ្នំពេញ ត្រូវបានរំដោះផងដែរ។

យើងកំពុងបន្តវាយសម្រុកយ៉ាងខ្លាំងក្លាលើខ្មាំង ដើម្បីគ្រប់គ្រងតំបន់នៅតទល់មុខភ្នំពេញ នៅត្រើយខាងកើតទន្លេមេគង្គ ក្រោយពីបានបំផ្លាញ និងរំដោះទីតាំងខ្មាំងជាច្រើនកន្លែងពីព្រែកឡៅ ទៅព្រែកតាមះ។ យើងកំពុងវាយប្រហារខ្មាំងពីទិសឥសាន និងពាយ័ព្យនៅជិតព្រែកលាប ជ្រោយចង្វារ និងគីឡូលេខ ៦។ ពីទិសខាងលិច យើងនៅជិតពោធិ៍ចិនតុង។ នៅទិសនិរតី យើងបន្តវាយសម្រុក និងបោសសម្អាតខ្មាំងនៅផ្លូវលេខ ៤ និងលេខ ៣៨។ នៅទិសអាគ្នេយ៍ យើងនៅជិតក្រុងតាខ្មៅ ហើយកំពុងបន្តបោសសម្អាតខ្មាំងនៅម្តុំដីឥដ្ឋ និងតំបន់ពីដីឥដ្ឋទៅ កៀនស្វាយ។

នៅសមរភូមិមុខនៅទីរួមខេត្តផ្សេងៗ  មិត្តទាំងអស់ក៏បានវាយប្រហារខ្មាំងយ៉ាងខ្លាំងក្លាផងដែរ រំដោះបានទីតាំងរាប់រយ រួមមានទីរួមខេត្តនៅឧដុង្គ និងទីរួមស្រុកមួយចំនួន ដូចជា [អក្សរអត់ច្បាស់] គាស់ក្រឡ កំពង់លួង រលាប្អៀរ ស្រុកបន្ទាយឆ្មារ ស្រុកថ្មពួក ។ល។

[00166865]

តំបន់រំដោះរបស់យើងបានរីកធំទៅៗ។ គិតត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩៧៥ តំបន់រំដោះរបស់យើងមានចំនួន ៩៧ភាគរយនៃដែនដីទាំងមូលរបស់ប្រទេសកម្ពុជា ហើយប្រជាជនចំនួន ៦លាននាក់ត្រូវរំដោះបានទាំងស្រុង។

ចំពោះខ្មាំង កំពុងតែដួលរំលំ ហើយកាន់តែនៅឯកាជាងមុនទៀត។ កងពលខ្មាំងអស់ទាំងស់ត្រូវបានបំបាក់រត់គេចចេញ ឬត្រូវកម្ទេចដោយកងទ័ពរំដោះជាតិប្រជាជនកម្ពុជារបស់យើង ម្តងមួយម្តងមួយ។ ទឹកចិត្តចំនួនទ័ព យុទ្ធសាស្ត្រ វិធីប្រយុទ្ធ ការចាត់ចែង និងការបញ្ជារបស់កងកម្លាំងប្រដាប់អាវុធខ្មាំងកំពុងតែដួលរំលំ។ សូស្តែន ហ្វែរណង់ដេស អគ្គមេបញ្ជាការ និងសេនាធិការក្បត់ជាតិ បានដួលរំលំយ៉ាងឈឺចាប់ ខណៈ

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ដែលរដ្ឋាភិបាលរបស់ លន់ នល់ ត្រូវបានរំលាយ។ ខ្មាំងមានបញ្ហារុកគួនដោយសារខ្វះកម្លាំង ខ្វះស្បៀង ហើយកំពុងអស់គ្រាប់។ យើងបានបិទខ្ទប់ផ្លូវដឹកជញ្ជូនរបស់ខ្មាំងស្ទើរតែទាំងអស់។ ទន្លេមេគង្គត្រូវបានបិទខ្ទប់។ ផ្លូវលើគោកទាំងអស់ត្រូវបានបិទ ហើយពោធិ៍ចិនតុងរងការវាយប្រហារកាំភ្លើងធំរបស់យើងជាបន្តបន្ទាប់។ នៅភ្នំពេញ និងតំបន់ស្ថិតក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់ខ្មាំង ប្រជាជន កម្មករ យុវជន សិស្សនិស្សិត គ្រូបង្រៀន មន្ត្រីបម្រើការងារ និងទាហាន កំពុងក្រោកឡើង ធ្វើកុបកម្ម និងតស៊ូយ៉ាងខ្លាំងក្លាប្រឆាំងពួកក្បត់ជាតិទាំង ៧ នាក់គឺលន់ នល់, សេរី មតៈ, សឺន ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ,ឡុង បូរ៉េត និង ស្វស្តែន ហ្វែរណង់ដេស។

សមមិត្តបញ្ជាការគ្រប់ជាន់ថ្នាក់ទាំងអស់ កម្មាភិបាល និងយុទ្ធជនទាំងបីប្រភេទរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជានៅសមរភូមិមុខទាំងអស់នៅទូទាំងប្រទេស ជាទីរាប់អាន!

ប្រជាជនយើងនៅទូទាំងប្រទេស និងប្រជាជាតិជាមិត្ត នៅជិត នៅឆ្ងាយ នៅលើពិភពលោក មានសេចក្ដីរីករាយយ៉ាងខ្លាំងជាមួយនឹងមហាជ័យជម្នះរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនយើង។ ជ័យជម្នះនេះមានសារៈសំខាន់ណាស់ ហើយមានសក្ដានុពលល្អក្រៃលែង។ កម្លាំងបដិវត្តន៍របស់យើងគ្រប់ប្រភេទទាំងអស់ បានកើនឡើងទាំងចំនួន ទាំងគុណភាព បង្កើតបានជាលក្ខខណ្ឌអំណោយផលសម្រាប់យើងបន្តឆ្ពោះទៅមុខកាន់តែខ្លាំងក្លាថែមទៀត ហើយសម្រេចជ័យជម្នះកាន់តែច្រើន និងមហាធំធេងថែមទៀតរហូតដល់សម្រេចបានគោលដៅចុងក្រោយគឺរំដោះប្រទេសជាតិ និងប្រជាជនយើងបានទាំងស្រុង។

សមមិត្តជាទីស្នេហា! បទពិសោធន៍ដែលបានឆ្លងកាត់នៅក្នុងដំណាក់កាលដំបូងនៃការវាយសម្រុករដូវប្រាំងឆ្នាំ ១៩៧៥ នេះ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ និងឈ្លាសវៃពីភាពត្រឹមត្រូវនៃមាគ៌ាដ៏ត្រឹមត្រូវទាំងអស់របស់យើង រួមមានជំហរតស៊ូដាច់ខាត អធិបតេយ្យភាព និងភាពច្នៃប្រឌិតក្នុងការប្រយុទ្ធ ព្រមទាំងការឯកភាពគ្នា និងសាមគ្គីភាពដ៏រឹងមាំក្នុងចំណោមកងទាំងឡាយ សមរភូមិ បញ្ជាការគ្រប់ជាន់ថ្នាក់ កម្មាភិបាល

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

យុទ្ធជន យុទ្ធនារី និងរវាងជួរមុខ ជាមួយនឹងជួរក្រោយ ដែលប្តេជ្ញាអនុវត្តពាក្យស្លោកទាំងអស់របស់យើង ហើយគាំទ្រជួរមុខដោយគ្មានលក្ខខណ្ឌ។ ចំណេះដឹងបន្ថែមជាពិសេសដែលយើងបានរៀនសូត្រពីដំណាក់កាលវាយសម្រុក    រដូវប្រាំងនេះគឺជាទិសដៅដ៏មានប្រសិទ្ធភាព និងជិតស្និទ្ធរបស់បញ្ហាការ និងសមរភូមិ។

មិត្តទាំងអស់ជាទាប់អាន! ចក្រពត្តិអាមេរិក មានភាពរឹងរូស និងឃោរឃៅយ៉ាងខ្លាំង។ ទោះបីជាថា ពួកក្បត់ជាតិទាំង ៧ នាក់ ជាបរិវារ ជិតដួលរលំហើយ ហើយខ្លួនដឹងថា មិនមានមធ្យោបាយសង្គ្រោះពួកនេះក៏ដោយ ក៏ចក្រពត្តិអាមេរិក នៅតែបន្តអនុវត្តផែនការព្រៃផ្សៃគ្រប់ប្រភេទ។

ជាទំនៀមទម្លាប់ប្រពៃណី ប្រជាជនយើង យុទ្ធជន យុទ្ធនារីយើង និងកម្មាភិបាលយើង បានប្រកាន់ខ្ជាប់នូវគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុតប្រឆាំងនឹងផែនការខ្មាំងទាំងអស់ ហើយទន្ទឹមពេលនេះដែរ ប្រកាន់ខ្ជាប់ដាច់ខាតនូវពាក្យស្លោកបដិវត្តន៍របស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជារបស់យើង គឺ “ពេលយើងកាន់តែឈ្នះ យើងកាន់តែសុភាព”។

មិត្តទាំងអស់របស់យើងនៅមុខព្រួញយុទ្ធសាស្ត្រទាំងបី គឺទន្លេមេគង្គ ភ្នំពេញ និងតំបន់ជុំវិញភ្នំពេញ និងទីរួមខេត្តផ្សេងៗ នឹងបន្តដាច់ខាតប្រកាន់ខ្ជាប់នូវគោលជំហរទាំងនេះ ហេតុនេះនឹងក្លាយជាកម្លាំងវាយប្រហារដ៏ខ្លាំងក្លាបំផុតប្រឆាំងខ្មាំង រហូតដល់ប្រទេសកម្ពុជា ត្រូវបានរំដោះ ១០០ ភាគរយ។

[00166866]

ក្នុងស្មារតីនេះ និងអារម្មណ៍បែបនេះរបស់បងប្អូនបដិវត្តន៍ដ៏ជ្រាលជ្រៅ តាងនាមឲ្យប្រទេសកម្ពុជា ប្រជាជនកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ខ្ញុំសូមសម្តែងការអបអរសាទរយ៉ាងកក់ក្តៅបំផុត និងជូនពរសព្ទសាធុការពរ។ ខ្ញុំសូមជូនពរឲ្យមានសុខភាពល្អ កម្លាំងរឹងមាំ ទទួលបានជ័យជម្នះថ្មី និងកាន់តែធំធេង។ ទន្ទឹមពេលនេះ ខ្ញុំសូមឱនគោរពវិញ្ញាណក្ខន្ធ

របស់មិត្តយើងដែលបានពលីជីវិតដ៏មានតម្លៃដើម្បីបុព្វហេតុរំដោះជាតិ និងប្រជាជន។ ខ្ញុំសូមជូនពរមិត្តដែលរងរបួស ឲ្យបានឆាប់ជាឡើងវិញ ដើម្បីបន្តបំពេញភារកិច្ចបដិវត្តន៍ឲ្យបានជោគជ័យ។

យើងប្រាកដជារំដោះភ្នំពេញ បាន ១០០ ភាគរយ!

តំបន់រំដោះកម្ពុជា ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ (ហត្ថលេខា) ខៀវ សំផន អនុនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រដ្ឋមន្ត្រីការពារជាតិ និងអគ្គមេបញ្ជាការកងទ័ពរំដោះជាតិប្រជាជនកម្ពុជា។

[00166867]

## ឡុង បូរ៉េត៖ ត្រៀមខ្លួនរួចរាល់“ធ្វើពលីកម្ម”ដើម្បីកិច្ចចរចាសន្តិភាព

ទីក្រុងហុងកុង សារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោងសកល ១៥០៣ ថ្ងៃទី២៤ ខែមីនា ឆ្នាំ ៧៥ ហុងកុង

[សេចក្ដីដកស្រង់] ភ្នំពេញ ថ្ងៃទី២៤ ខែ មីនា (AFP)--នៅថ្ងៃទីនេះនៅពេលដែលបង្ហាញគណៈរដ្ឋមន្ត្រីថ្មីជូនសភាកម្ពុជា នាយករដ្ឋមន្ត្រីកម្ពុជា ឡុង បូរ៉េត បានប្រកាសថា រដ្ឋាភិបាលរបស់លោកដែលកំពុងមានបញ្ហាច្រើន បាន “ត្រៀមខ្លួនរួចរាល់ធ្វើពលីកម្មដែលគេទាមទារពីយើងដើម្បីប្រយោជន៍កិច្ចចរចាសន្តិភាព”។

គាត់បានបន្ថែមថា រដ្ឋាភិបាលជឿជាក់ថា “រវាងខ្មែរ និងខ្មែរ” យើងអាចឈានទៅរកការយោគយល់គ្នាបាន (ជាមួយនឹងក្រុមបះបោរខ្មែរក្រហមដែលគាំទ្រដោយពួកកុម្មុយនិស្ត) ក្នុងគោលបំណងដើម្បីទម្លាក់អាវុធយើងចុះ ហើយដោះស្រាយបញ្ហាខ្វែងយោបល់គ្នារវាងពួកយើង តាមរយៈមធ្យោបាយនយោបាយសន្តិភាព។

អ្នកសង្កេតការណ៍នៅទីនេះបានកត់សម្គាល់ថា ប្រធានបទនៃការធ្វើពលីកម្មគឺជាបញ្ហាមួយដែលឧស្សាហ៍លើកឡើងនៅក្នុងកិច្ចជជែកអំពីការលាលែងតំណែងរបស់សេនាប្រមុខ លន់ នល់ ជាប្រធានាធិបតីកម្ពុជា

មានឈ្មោះលើគេនៅក្នុងបញ្ជីឈ្មោះមេដឹកនាំកម្ពុជាដែលខ្មែរក្រហមបានប្តេជ្ញាថានឹងត្រូវប្រហារជីវិត។ ខ្មែរក្រហម ឥឡូវនេះកំពុងឡោមព័ទ្ធទីក្រុងភ្នំពេញ។

**ពួកកុម្មុយនិស្តចូលកាន់តែខិតជិតដល់ព្រលានយន្តហោះពោធិ៍ចិនតុង**

ទីក្រុងហុងកុង សារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោងសកល ១៣០៨ ថ្ងៃទី២៤ ខែមីនា ឆ្នាំ ៧៥ ហុងកុង

[សេចក្តីដកស្រង់] ភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ៧៥ (AFP)--នៅថ្ងៃនេះ ខ្មែរក្រហម ដែលគាំទ្រដោយពួកកុម្មុយនិស្ត បានវាយបំបែកខ្សែការពាររបស់រដ្ឋាភិបាល ចូលកាន់តែខិតជិតដល់ព្រលានយន្តហោះទីក្រុងភ្នំពេញ ជាទីក្រុងដែលកំពុងស្ថិតក្រោមការឡោមព័ទ្ធ ហើយព្រលានយន្តហោះនេះគឺជាខ្សែរយៈទំនាក់ទំនងចុងក្រោយបង្អស់របស់ទីក្រុងភ្នំពេញដើម្បីទាក់ទងជាមួយនឹងពិភពលោកខាងក្រៅ។ នេះបើតាមការលើកឡើងពីប្រភពយោធានៅក្នុងសមរភូមិ។

ការវាយចូលរបស់ខ្មែរក្រហមនេះនៅសល់ពីរគីឡូម៉ែត្រ (ជាងមួយម៉ៃល៍) កាន់តែខិតជិតដល់ព្រលានយន្តហោះហើយ គឺស្ថិតនៅក្នុងចម្ងាយដែលខ្មែរក្រហមអាចប្រើគ្រាប់រ៉ុកកែត និងកាំភ្លើងធំបាន។

ប្រភពខាងលើបាននិយាយថា ឧត្តមសេនីយ៍ចន្ទារង្សី ដែលជាមេបញ្ជាប្រចាំមូលដ្ឋានរបស់ទីបញ្ជាការ រដ្ឋាភិបាល ត្រូវបានដកតំណែងបញ្ជាការភ្លាមៗ។ ឧត្តមសេនីយ៍នេះគឺជាព្រះបិតុលារបស់ព្រះអង្គម្ចាស់នរោត្តមសីហនុ ដែលជាមេដឹកនាំខ្មែរក្រហម និងជាអតីតអ្នកគ្រប់គ្រងប្រទេសកម្ពុជា។

ការវាយសម្រុកជោគជ័យរបស់ខ្មែរក្រហមនេះគឺនៅម្តុំទួលលាប ដែលធ្លាប់ជាទីតាំងគន្លឹះមួយនៅក្នុងខ្សែការពារព្រលានយន្តហោះ ស្ថិតនៅចម្ងាយ ១០គីឡូម៉ែត្រ (៦ម៉ៃល៍) នៅភាគពាយ័ព្យព្រលានយន្តហោះ។ ឧត្តមសេនីយ៍ ចន្ទារង្សី និងទាហានរបស់គាត់បាននិងកំពុងប្រយុទ្ធដើម្បីដណ្តើមកាន់កាន់វិញ។

ប្រភពយោធាបាននិយាយថា ទីតាំងបាញ់គ្រាប់រ៉ុកកែតនៅទួលលាប មានខ្សែការពាររឹងមាំ ហើយមានដាក់មីនច្រើនមែនទែនដែលនាំឲ្យមានការលំបាកយ៉ាងខ្លាំងទម្រាំវាយដណ្ដើមយកតំបន់នេះបាន។ នៅថ្ងៃនេះទាហានរដ្ឋាភិបាលដែលប្រត្តិបត្តិការនៅខាងជើងផ្លូវជាតិលេខ ៤ បានដកថយពីទីតាំងដែលពួកគេបានកាន់កាប់នៅពេលប្រយុទ្ធគ្នាកាលពីម្សិលមិុញ។

[00166868]

ពិធីនេះបានធ្វើឡើងក្រោមអធិបតីភាពរបស់ឧបនាយករដ្ឋមន្ត្រីខៀវ សំផន និងចូលរួមដោយរដ្ឋមន្ត្រី និងអនុរដ្ឋមន្ត្រីប៉ុន្មាននាក់។ ពិធីនេះចាប់ផ្ដើមនៅម៉ោង ០៨.០០។ ខណៈដែលមានការទះដៃអបអរសាទរយ៉ាងលាន់រំពង លោក ខៀវ សំផន បានថ្លែងសុន្ទរកថាយ៉ាងលម្អិតដោយសង្ខេបអំពីមហាជ័យជម្នះជាប្រវត្តិសាស្ត្រដែលរណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ទទួលបាននៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះទាំងនៅជួរមុខ ទាំងនៅជួរក្រោយ ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស។ ក្នុងពេលដំណាលគ្នានេះដែរ គាត់បានធ្វើសេចក្ដីរាយការណ៍អំពីមហាចលនាវាយសម្រុកលើខ្មាំងនៅក្នុងរដូវប្រាំងនេះ ដែលក្នុងនេះ កងកម្លាំងប្រដាប់អាវុធ និងប្រជាជនយើងកំពុងប្រយុទ្ធកម្ចាត់ខ្មាំង ដោយប្ដេជ្ញាចិត្តត្រូវតែប្រយុទ្ធឲ្យឈ្នះដាច់ខាត មិនរាថយឡើយ។ ស្របតាមសេចក្ដីប្រកាសរបស់មហាសន្និបាតជាតិលើកទីពីរ ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ក៏បានអំពាវនាវឲ្យប្រជាជន និងកងកម្លាំងប្រដាប់អាវុធគ្រប់រូបរបស់យើង បន្តវាយសម្រុកឲ្យខ្លាំងក្លាប្រឆាំងខ្មាំង ដោយលើកកម្ពស់ស្មារតីទទួលខុសត្រូវ និងការប្រុងប្រយ័ត្នបដិវត្តន៍ប្រឆាំងនឹងផែនការខ្មាំងទាំងអស់។

ចុងបញ្ចប់ ឧបនាយករដ្ឋមន្ត្រីបានជូនពរសព្ទសាធុកាពរថ្វាយសម្ដេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ និងជាព្រះប្រធានរណសិរ្សរួបរួមជាតិកម្ពុជា សម្ដេចប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រះសង្ឃគ្រប់ព្រះអង្គ កម្មាភិបាល និងយុទ្ធជនទាំងបីប្រភេទនៅក្នុងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ព្រមទាំងជនរួមជាតិទាំងអស់នៅក្នុងតំបន់រំដោះ នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់ខ្មាំង

នៅក្នុងប្រទេស និងក្រៅប្រទេស។ គាត់ជូនពរឲ្យមានសុខភាពល្អ កម្លាំងពលៈ និងមហាជ័យជម្នះថែម ទៀតនៅក្នុងភារកិច្ចបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិយើង និងប្រជាជនយើង។ គាត់ក៏បានថ្លែងអំណរគុណ ដល់ប្រជាជាតិ រដ្ឋាភិបាល និងប្រទេសជាមិត្តទាំងអស់ទាំងជិត ទាំងឆ្ងាយ ព្រមទាំងប្រជាជាតិទាំងអស់ ដែលស្រលាញ់សន្តិភាពនៅក្នុងពិភពលោក រួមមាន ជនជាតិអាមេរិកចម្រើននិយម ផងដែរ ដែលបានជួយ ជ្រោមជ្រែងជាបន្តបន្ទាប់ដល់ប្រជាជនកម្ពុជា នៅក្នុងបុព្វហេតុដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជាប្រឆាំងនឹង ចក្រពត្តិអាមេរិក និងបរិវារ--ពួកក្បត់ជាតិ លន់ នល់, សេរី មតៈ, សឹង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្តែន ហ្វែរណង់ដេស។

បន្ទាប់មក តំណាងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ក្រសួងបដិវត្តន៍ មន្ទីរបដិវត្តន៍ និងអង្គការមហាជន ស្នេហាជាតិផ្សេងៗ បានឡើងសម្តែងមតិយោបល់របស់ខ្លួន។ នៅចុងបញ្ចប់នៃកម្មវិធីនយោបាយនេះ មហា សន្និបាតបានអនុវត្តសេចក្តីសម្រេចដូចខាងក្រោម៖

១. យើងប្តេជ្ញាចិត្តតស៊ូបំពេញភារកិច្ចបដិវត្តន៍ទាំងអស់ក្នុងស្មារតីពលីខ្ពស់បំផុតដើម្បីបំផុសមហាចលនា វាយសម្រុកប្រឆាំងនឹងខ្មាំងនៅជួរមុខ និងបំផុសមហាចលនាដោះស្រាយបញ្ហាទឹក និងបង្កើនការបង្កបង្កើន ផលនៅជួរក្រោយ។

២. យើងប្តេជ្ញាចិត្តប្រកាន់ខ្ជាប់នូវជំហរឯករាជ្យភាព និងអធិបតេយ្យភាព ជម្នះរាល់ការលំបាក និង ឧបសគ្គទាំងអស់ និងប្រកាន់ខ្ជាប់នូវជំហរប្តេជ្ញាប្រយុទ្ធដាច់ខាត មិនរាថយរហូតដល់ទទួលបានជ័យជម្នះ ទាំងស្រុង និងជានិរន្តរ៍។

៣. យើងប្តេជ្ញាចិត្តជំរុញការប្រុងប្រយ័ត្នបដិវត្តន៍ និងកម្ចាត់ផែនការខ្មាំងទាំងអស់។

៤.  យើងប្តេជ្ញាបំផុសសាមគ្គីភាព និងឯកភាពនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ និងនៅក្នុងចំណោមប្រជាតិទាំងមូល ហើយប្រកាន់ខ្ជាប់នូវជំហរបដិវត្តន៍សុភាពរាបសាជានិច្ច។

ចុងក្រោយ មហាសន្និបាតមានការសម្តែងសិល្បៈដោយក្រុមសិល្បៈជាយុទ្ធជន យុទ្ធនារីមកពីក្រសួងព័ត៌មាន និងឃោសនាការនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាកិច្ចបញ្ចប់កម្មវិធីនៅក្នុងបរិយាកាដ៏សប្បាយរីករាយនៃសាមគ្គីភាពយោធា ហើយមានសំឡេងស្រែកអបអរសាទរថា៖ “ជយោ! ខួបលើកទី ៥ នៃរណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ដ៏រុងរឿង និងជ័យជម្នះជានិច្ច!”។

[00166869]

**ហ៊ូ នឹម មកពីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចេញសេចក្តីអំពាវនាវថ្វាយព្រះសង្ឃអំពីសភាពការណ៍បច្ចុប្បន្ន**

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ទីក្រុងភ្នំពេញ (សម្ងាត់) ជាភាសាខ្មែរប្រចាំប្រទេសកម្ពុជា ម៉ោងសកល ០១០០ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ៧៥

[អត្ថបទចុះថ្ងៃទី២២ ខែមីនា “សេចក្តីអំពាវនាវថាយព្រះសង្ឃគង់នៅភ្នំពេញ និងទីរួមខេត្តដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ចេញដោយ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា”]--ផ្សាយផ្ទាល់ ឬថតចម្លង]

[អត្ថបទ]៖ ខ្ញុំព្រះករុណាសូមគោរពពីចម្ងាយដល់ព្រះសង្ឃគ្រប់ព្រះអង្គជាទីសក្ការៈដែលគង់នៅភ្នំពេញ និងទីរួមខេត្តផ្សេងៗដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង។ ព្រះអង្គជាទីសក្ការៈ ដូចដែលព្រះអង្គបានជ្រាបហើយ សភាពការណ៍ផ្លូវការបច្ចុប្បន្ននេះនៅភ្នំពេញ និងទីក្រុងផ្សេងទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង កំពុងតែយ៉ាប់យ៉ឺនពីមួយថ្ងៃទៅមួយថ្ងៃ។ អង្ករ និងស្បៀង

ផ្សេងទៀតកំពុងតែអស់ហើយ ហើយនៅពេលអនាគតនឹងកាន់តែលំបាកថែមទាំងទម្រាំបានស្បៀង។ មិនមែនតែពួកក្បត់ជាតិទាំង ៧ នាក់ដែលនៅភ្នំពេញ ពុករលួយខ្លាំង ហើយមិនអាចដោះស្រាយបញ្ហាជីវភាព និងបញ្ហាកង្វះស្បៀងសម្រាប់ព្រះសង្ឃ និងជនរួមជាតិយើងប៉ុណ្ណោះទេ ប៉ុន្តែ ពួកក្បត់ជាតិនេះក៏បានបង្កើនសកម្មភាពហ្វាស៊ីស ជិះជាន់មកលើព្រះសង្ឃ និងជនរួមជាតិយើងថែមទៀតផង។ នៅថ្ងៃទី១១ ខែ មីនា នេះ ជនក្បត់ជាតិ លន់ នល់ បានប្រកាសថា គាត់បានបញ្ជាឲ្យបាញ់សម្លាប់ជនរួមជាតិយើងទាំងអស់ដែលបានធ្វើបាតុកម្មដើម្បីទាមទារអង្គរ ឬប្រឆាំងគាត់។ ជាងនេះទៀត ពួកក្បត់ជាតិឧស្សាហ៍បំផុសសកម្មភាពសម្ពុត។ ពួកក្បត់ជាតិធ្វើការកេណ្ឌទ័ពដោយបង្ខំ រួមមាន កុមារអាយុ១២ ឆ្នាំ សិស្សនិស្សិត នារី និងព្រះសង្ឃផងដែរ ដោយកេណ្ឌខ្លះឲ្យទៅប្រយុទ្ធនៅជួរមុខ ខ្លះទៀតឲ្យទៅការពារបក្សពួករបស់គេនៅជួរក្រោយ។ ពួកក្បត់ជាតិបានបែងចែកទីក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងៗដែលនៅស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្លួនទៅជាផ្នែកការពារតូចៗ ហើយបង្ខំប្រជាជនឲ្យជីកត្រង់សេការពារជាច្រើនកន្លែងនៅភ្នំពេញ និងទីរួមខេត្ត ដើម្បីប្រយុទ្ធ និងស្លាប់ជំនួសពួកគេ។

ព្រះអង្គជាទីសក្ការៈ នេះគឺជាសភាពការណ៍ធ្ងន់ធ្ងរណាស់ និងគ្រោះថ្នាក់បំផុតដែលប៉ះពាល់ដល់សន្តិសុខ និងជីវិតរបស់យើង ព្រមទាំងសន្តិសុខ និងជីវិតរបស់ជនរួមជាតិយើងគ្រប់រូបនៅភ្នំពេញ និងទីរួមខេត្តផ្សេងៗដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង។ បើអត់អាហារ យើងនឹងស្លាប់។ បើគេកេណ្ឌយើងឲ្យចូលទ័ព យើងក៏នឹងស្លាប់ដែរ។ បច្ចុប្បន្ននេះ គ្មាននរណាម្នាក់អាចនៅស្ងៀម ឬមិនចូលរួមឡើយ។ ពួកក្បត់ជាតិមិនអនុញ្ញាតឲ្យព្រះសង្ឃ និងប្រជាជនយើងនៅស្ងៀមមិនចូលរួមឡើយ។ ហេតុនេះ ឥឡូវនេះ ជាពេលបន្ទាន់ជាងពេលណាទាំងអស់ ខ្ញុំព្រះករុណាសូមស្នើសុំព្រះសង្ឃគ្រប់ព្រះអង្គពិចារណាលើសភាពការណ៍បច្ចុប្បន្ននេះ ហើយសម្រេចរួបរួមជាមួយប្រជាជន យុវជន សិស្សសាលា និស្សិត គ្រូបង្រៀន មន្ត្រីបម្រើការងារ និងទាហានដែលបានក្រោកឡើងរួចហើយធ្វើកុបកម្មហិង្សាជាបន្តបន្ទាប់។

១. ចំនួន ៩៧ ភាគរយនៃប្រទេសកម្ពុជាយើង ត្រូវបានរំដោះរួចហើយ ហើយប្រជាជនចំនួន ៦ លាននាក់ ក្នុងចំណោមប្រជាជនយើង ត្រូវបានរំដោះរួចហើយ។ ប្រជាជនយើងនៅក្នុងតំបន់រំដោះដ៏ធំធេង ដោយមានការចូលរួមយ៉ាងរំដើបរំជួលពីព្រះសង្ឃគ្រប់ព្រះអង្គ កំពុងតែកសាងប្រទេសកម្ពុជាមួយដែលមានមុខមាត់ថ្មី ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ អធិបតេយ្យ ប្រជាធិបតេយ្យ និងសម្បូររុងរឿង។ មុខមាត់ថ្មីរបស់កម្ពុជានេះ បានបង្កើតឡើងរួចហើយ។ ខាងនយោបាយ យោធា សង្គម សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋអំណាចប្រជាធិបតេយ្យរបស់ប្រជាជនយើង បានចាក់ឫកគុលយ៉ាងរឹងមាំ និងមានការអភិវឌ្ឍមិនធ្លាប់ពីមុនមក មហាលោតផ្លោះ។ ប្រជាជនយើងបានគ្រប់គ្រង និងអភិវឌ្ឍជាបណ្តើរៗលើធនធានធម្មជាតិរបស់យើង រួមមានចម្ការកៅស៊ូ ជាដើម។ ធារាសាស្ត្រ និងការបង្កបង្កើនផល ព្រមទាំងវាលស្រែចម្ការផ្សេងៗ កំពុងលូតលាស់យ៉ាងល្អ ហើយរំពឹងថានឹងមានការប្រមូលផលបានល្អ។

ប្រជាជនយើងនៅតំបន់រំដោះ មិនត្រឹមតែអាចបំពេញតម្រូវការប្រចាំថ្ងៃរបស់ខ្លួនបានទេ ប៉ុន្តែ ក៏អាចជួយសមរភូមិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួនបានទៀតផង។ ឥឡូវនេះ ក្នុងនាមជារដ្ឋ និងជាប្រទេសមួយដែលមានឯករាជ្យភាព និងអធិបតេយ្យភាពពេញលេញ តំបន់រំដោះរបស់យើងបានសម្រេចមហាសមិទ្ធផល ហើយមានស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ការបង្កើតក្រុមសាមគ្គីសម្រាប់ការបង្កបង្កើនផល និងយុទ្ធនាការដ៏ជោគជ័យក្នុងការដោះស្រាយបញ្ហាទឹកនៅទូទាំងតំបន់រំដោះ ធានាថា នៅពេលអនាគតប្រទេសកម្ពុជាយើងនឹងត្រូវរំដោះបាន ១០០ ភាគរយ។ ទាំងអស់នេះគឺដោយសារស្នាដៃរបស់ប្រជាជន និងព្រះសង្ឃរបស់យើងនៅក្នុងតំបន់រំដោះដែលបានចូលរួមកិច្ចខិតខំប្រឹងប្រែងកសាង ក្នុងស្មារតីស្អាតស្អំ និងលះបង់ខ្ពស់បំផុត។

[00166870]

២. ដូចព្រះអង្គបានជ្រាបហើយ សំឡេងកាំភ្លើងកំពុងលាន់ញ៉ូរលំនៅស្ថានរបស់យើងនាពេលបច្ចុប្បន្ននេះ គឺជាសំឡេងជ័យជម្នះរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង ដែលបាននិងកំពុងវាយសម្រុក

យ៉ាងខ្លាំងក្លាណាស់នៅគ្រប់ទីកន្លែង។ យើងកំពុងវាយសម្រុកនៅតាមដងទន្លេមេគង្គ នៅភ្នំពេញ នៅជុំវិញភ្នំពេញ និងនៅទីរួមខេត្តដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង។ យើងកំពុងវាយសម្រុកដោយខ្លួនឯងយ៉ាងខ្លាំងក្លាបំផុត។ កម្លាំងរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង មានច្រើនលើសលុប។ ប្រជាជន និងព្រះសង្ឃរបស់យើងនៅទូទាំងប្រទេស មានសេចក្តីត្រេកអរ និងមោទនភាពយ៉ាងខ្លាំងចំពោះកម្លាំងនេះ ដែលទទួលបានការកោតសរសើរពីប្រជាជាតិជាមិត្តរបស់យើងទាំងជិត ទាំងឆ្ងាយនៅទូទាំងពិភពលោក។

ព្រះអង្គជាទីសក្ការៈ បានជ្រាបហើយថា យើងបានរំដោះ និងគ្រប់គ្រងទន្លេមេគង្គទាំងស្រុង។ ខ្មាំងមិនអាចដណ្តើមទន្លេមេគង្គបានវិញឡើយ ពីព្រោះថា ខ្មាំងមិនមានកម្លាំង ឬមធ្យោបានដើម្បីដណ្តើមវិញឡើយ។ ក្នុងស្មារតីទទួលខុសត្រូវ និងការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុត យុទ្ធជន និងកម្មាភិបាលរបស់យើង ជាកូនដ៏ល្អបំផុតរបស់ប្រជាជនកម្ពុជាយើង តែងតែត្រៀមខ្លួនកម្ចាត់ខ្មាំងនៅតាមដងទន្លេមេគង្គ ប្រហែលជិត ១០០ គីឡូម៉ែត្រ ពីភ្នំពេញ ទៅព្រំដែនវៀតណាមខាងត្បូង។ រយៈពេលជាងពីរខែកន្លះ គ្មានក្បួនកប៉ាល់ណាគេចផុតពីកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើងឡើយ។ ចាប់តាំងពីដើមខែនេះ ទន្លេមេគង្គនៅខាងក្រោមអ្នកលឿង មានសភាពស្ងៀមស្ងាត់ទាំងស្រុង ហើយកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង បានពន្លិច ឬដុតក្បួនកប៉ាល់ខ្មាំងទាំងអស់ដែលឃើញមាននៅខាងលើអ្នកលឿងម្តងម្កាល។ ខ្មាំងធ្លាប់សង្ឃឹមលើពោធិ៍ចិនតុង ប៉ុន្តែ ឥឡូវនេះ ពោធិ៍ចិនតុង ក៏លែងដំណើរការដែរ។ កងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង ឥឡូវនេះកំពុងវាយសម្រុកយ៉ាងខ្លាំងក្លាលើពោធិ៍ចិនតុង នៅភ្នំពេញ និងទីរួមខេត្តទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង។ ដូចព្រះអង្គបានជ្រាបហើយ នៅក្នុងក្រុងខ្លះ កងកម្លាំងប្រដាប់អាវុធរបស់យើង បានចូលដល់ផ្សារ ឬជិតទីស្នាក់ការខេត្ត។ នៅរង់ចាំតែពេលវេលាប៉ុណ្ណោះ ប្រជាជនយើង និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើងនឹងរំដោះក្រុងទាំងនេះបានជាស្ថាពរ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

៣. ដោយសារព្រះអង្គ បានស្តាប់វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជារបស់យើង ព្រះអង្គបានជ្រាបហើយថា មហាសន្និបាតជាតិលើកទីពីរបានប្រារព្ធធ្វើឡើងក្រោមបរិយាកាសអំណោយផលបំផុតនៅក្នុងតំបន់រំដោះរបស់យើង នៅថ្ងៃទី ២៤ និង ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៥។ សេចក្តីសម្រេចចម្បងនៃមហាសន្និបាតនេះ ដែលតំណាងឲ្យប្រជាជនកម្ពុជា និងប្រទេសកម្ពុជា ព្រមទាំងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទាំងមូល បានបង្ហាញថា បដិវត្តន៍កម្ពុជារបស់យើង បានឈានដល់ដំណាក់កាលថ្មីមួយ។ នៅក្នុងដំណាក់កាលថ្មីនេះ ប្រជាជនកម្ពុជា ប្រទេសកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានវាយសម្រុកលើខ្មាំងដល់កម្រិតមិនធ្លាប់មានពីមុនមក ដើម្បីរំដោះដែនដី ៣ ភាគរយ និងប្រជាជនដែលនៅសល់ រួមទាំងព្រះអង្គជាទីសក្ការៈផងដែរ ដែលកំពុងរងទុក្ខលំបាកមិនអាចបានថ្លែងបាន នៅភ្នំពេញ និងតំបន់នានាដែលស្ថិតនៅក្រោមការគ្រប់គ្រង បណ្តោះអាសន្នរបស់ខ្មាំង។ ប្រជាជនកម្ពុជា ប្រទេសកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នឹងទទួលបានជ័យជម្នះទាំងស្រុង យ៉ាងច្បាស់ ជាដាច់ខាត។

ព្រះអង្គជាទីសក្ការៈ៖ មានតែជនក្បត់ជាតិ ៧ នាក់ប៉ុណ្ណោះ គឺ លន់ នល់, សេរី មតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ,ឡុង បូរ៉េត និង ស្វ៊ស្តែន ហ្វែរណង់ដេស។ ពួកគេបានបង្កឲ្យមានការបំផ្លិចបំផ្លាញ និងវិនាសកម្មមិនធ្លាប់មានពីមុនមក និងមិនអាចគិតឃើញមកលើប្រទេសជាតិយើង ប្រជាជនយើង ព្រះសង្ឃ និងព្រះពុទ្ធសាសនាយើង។ ឧក្រិដ្ឋកម្មដ៏ឃោរឃៅដែលបានប្រព្រឹត្តឡើងដោយបនក្បត់ជាតិនេះនៅក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះចាប់តាំងពីរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មក បានធ្វើឲ្យប្រទេសកម្ពុជា ដែលឯករាជ្យ សន្តិភាព និងអព្យាក្រឹត្យទៅជាក្រឡាប់ចាក់ ពោលគឺជាឧក្រិដ្ឋកម្មធំជាងមហាសមុទ្រ ហើយធ្ងន់ជាងភ្នំទៀត។ ហេតុនេះ តាងនាមឲ្យប្រជាជនកម្ពុជា និងប្រទេសកម្ពុជាទាំងមូល មហាសន្និបាតជាតិ

លើកទីពីរនេះបានធ្វើ  សេចក្ដីសម្រេចយ៉ាងយុត្តិធម៌បំផុតថា ជនក្បត់ជាតិទាំងនេះគួរត្រូវបញ្ចប់ឲ្យលែងមានវត្តមាន។

ឥឡូវនេះ ពួកក្បត់ជាតិនេះបានចូលដល់ដំណាក់កាលចុងក្រោយជិតបាត់វត្តមានហើយ។ បច្ចុប្បន្ននេះ ដូចព្រះអង្គជាទីសក្ការៈ និងពិភពលោកទាំងមូល បានជ្រាបហើយ ពួកក្បត់ជាតិនេះត្រូវបានឡោមព័ទ្ធទាំងស្រុងដោយកងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនយើង គឺនៅរង់ចាំតែពេលវេលាប៉ុណ្ណោះ កម្លាំងរបស់យើង និងប្រជាជនយើង នឹងកម្ចាត់ពួកក្បត់ជាតិនេះ ដោយដាក់ទោសពួកនេះទៅតាមទំហំនៃឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្តនាពេលកន្លងមក។ ដូចព្រះអង្គជាទីសក្ការៈ បានជ្រាបហើយ ភ្នំពេញ និងទីក្រុងទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់ខ្មាំង ត្រូវបានដាក់ឲ្យនៅឯកាទាំងស្រុងហើយ។ ទន្លេមេគង្គ ត្រូវបានបិទផ្លូវខ្ទប់។ ផ្លូវទំនាក់ទំនងលើគោកទាំងអស់ត្រូវបានកាត់ផ្ដាច់ ពោធិ៍ចិនតុងលែងដំណើរការ ហើយប្រជាជនអាមេរិក និងអ្នកនយោបាយអាមេរិកកំពុងតែប្រឆាំងនឹងសំណើរបស់រដ្ឋបាលសហរដ្ឋអាមេរិកសុំជំនួយជួយពួកក្បត់ជាតិនេះ។ ថ្ងៃឱវសាន្តពួកក្បត់ជាតិនេះបានមកដល់ហើយ។ ឥឡូវនេះ យើងត្រូវតែបំបាត់វត្តមានពួកក្បត់ជាតិនេះ។

[00166871]

ព្រះអង្គជាទីសក្ការៈ ដូចបានបញ្ជាក់យ៉ាងច្បាស់តាមរយៈសេចក្ដីសម្រេចរបស់មហាសន្និបាតជាតិលើកទីពីរ មន្ត្រីបម្រើការងារជាន់ទាបខ្ពស់ទាំងអស់ អ្នកនយោបាយ ឥស្សរជន មន្ត្រីនានា ទាហាន និងកងកម្លាំងប្រដាប់អាវុធផ្សេងទៀតគ្រប់ប្រភេទទាំងអស់ដែលកំពុងបម្រើរបបពួកក្បត់ជាតិ លើកលែងតែពួកក្បត់ជាតិទាំង ៧ នាក់ចេញ គឺអាចចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ឲ្យតែពួកគាត់លះបង់ឈប់សហការជាមួយនឹងពួកក្បត់ជាតិទាំង ៧ នាក់នេះ។ ឥឡូវនេះគឺជាពេលវេលាដ៏ល្អបំផុត។ ព្រះអង្គគ្រប់ព្រះអង្គជាទីសក្ការៈដែលមានទំនៀមទម្លាប់តស៊ូស្នេហាជាតិ គប្បីចូលរួមចំណែកបញ្ចប់មហាវិនាសកម្ម និងការឈឺចាប់ដែលចក្រពត្តិអាមេរិក និងបក្សពួករបស់វា បានបង្កឡើងនៅក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះមកលើ

Original EN: 00166779-00166887

Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ប្រទេសជាតិយើង ប្រជាជនយើង ព្រះសង្ឃ និងព្រះពុទ្ធសាសនាយើង។ ព្រះអង្គគប្បីចូលរួមចំណែកបញ្ចប់សង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវាររបស់វានៅក្នុងប្រទេសកម្ពុជា ចូលរួមចំណែករំដោះប្រទេសជាតិយើង ប្រជាជនយើង និងព្រះពុទ្ធសាសនាយើង ព្រមទាំងចូលរួមចំណែកសម្រេចសន្តិភាពឲ្យបានឆាប់រហ័សនៅក្នុងប្រទេសកម្ពុជាយើង។

ដោយគិតពីបញ្ហានេះ ខ្ញុំព្រះករុណា សូមធ្វើសេចក្តីអំពាវនាវដូចខាងក្រោមស្នើសុំព្រះអង្គជាទីសក្ការៈគ្រប់ព្រះអង្គ ដែលគង់នៅក្នុងវត្តអារ៉ាមទាំងអស់នៅភ្នំពេញ និងទីរួមខេត្តផ្សេងៗដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង៖

១. សាមណេរសិស្សនិស្សិតនៅសាលាពុទ្ធកសិក្សា និងមហាវិទ្យាលពុទ្ធកសិក្សាទាំងអស់សាស្ត្រាចារ្យពុទ្ធកសិក្សា និងព្រះសង្ឃជាន់ទាបខ្ពស់ទាំងអស់ សូមបន្តទំនៀមទម្លាប់តស៊ូដ៏ក្លាហានរបស់ព្រះសង្ឃស្នេហាជាតិដែលបានចូលរួមចលនាតស៊ូទាំងអស់របស់ប្រជាជន កម្មករ យុវជន សិស្សនិស្សិត គ្រូបង្រៀន មន្ត្រីបម្រើការងារ និងទាហាន ដូចជា ចេញសេចក្តីថ្លែងការណ៍ ធ្វើសិក្ខាសិលា ធ្វើសន្និបាត ធ្វើអង្គប្រជុំ ធ្វើពហិការមិនចូលរៀន ធ្វើបាតុកម្ម ធ្វើការប្រឆាំងការកេណ្ឌទ័ព អំពើពុករលួយ អំពើអយុត្តិធម៌ និងហ្វាស៊ីសនិយម បំផ្លាញឃ្លាំងអង្ករ និងសហករណ៍របស់ពួកក្បត់ជាតិ ថែមទៀតវាយប្រហារខ្មាំង ដណ្តើមអាវុធពីខ្មាំងដើម្បីវាយខ្មាំងវិញ ហើយធ្វើកុបកម្មដើម្បីផ្តួលរំលំពួកក្បត់ជាតិទាំង ៧ នាក់ និងរបបរបស់ពួកវា។

២. ព្រះអង្គដែលមានតួនាទីខ្ពស់ បព្វជិតព្រះពុទ្ធសាសនាគ្រប់ជាន់ថ្នាក់ គណៈសង្ឃប្រចាំខេត្ត ប្រចាំស្រុក ចៅអធិការនៅតាមវត្តអារ៉ាម និងវិហារនៅគ្រប់តំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មាំង សូមជួយព្រះសង្ឃដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ព្រមទាំងប្រជាជន កម្មករ យុវជន និងសិស្សនិស្សិតរស់នៅជិតវត្តអារ៉ាម ឬនៅក្នុងវត្តអារ៉ាមដែលចូលរួមកុបកម្ម និងការតស៊ូរបស់ប្រជាជនយើង។

ជាងនេះទៀត សូមនិមន្តអញ្ជើញព្រះអង្គមេត្តាចូលរួមការតស៊ូនេះ ឬជួយបំផុសឲ្យមានការតស៊ូច្រើនរូបភាពពីសំណាក់ព្រះសង្ឃ និងជនរួមជាតិយើង។

៣. ព្រះអង្គជាទីសក្ការៈគ្រប់ព្រះអង្គ សូមមេត្តាផ្តល់ជំនួយឲ្យបានច្រើនតាមដែលអាចធ្វើទៅបានដល់យុទ្ធជនភាតរភាព និងកម្មាភិបាលរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង ដែលកំពុងវាយសម្រុកលើខ្មាំងនៅគ្រប់ទីកន្លែង ហើយសូមចូលរួមកម្ចាត់ពួកក្បត់ជាតិទាំង ៧ នាក់ ដើម្បីរំដោះភ្នំពេញ និងទីរួមខេត្តទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង។

៤. ដើម្បីចៀសវាងកុំឲ្យមានឧបទ្ទវហេតុដែលអាចឲ្យព្រះអង្គគ្រោះថ្នាក់ សូមព្រះអង្គគង់ឲ្យឆ្ងាយពីទីតាំងយោធា នយោបាយ និងសេដ្ឋកិច្ចទាំងអស់របស់ខ្មាំង។ តំបន់រំដោះស្ថិតនៅជិតព្រះអង្គទេ ហើយប្រសិនបើចាំបាច់ សូមព្រះអង្គយាងដំណើរទៅតំបន់រំដោះ។ ប្រជាជនយើង យុទ្ធជន យុទ្ធនារីរបស់យើង កម្មាភិបាល និងអង្គការរណសិរ្សរួបរួមជាតិកម្ពុជានៅគ្រប់ទីកន្លែង នឹងស្វាគមន៍ និងប្រគេនជូនព្រះអង្គនូវស្បៀងកន្លែងគង់នៅ និងសន្តិសុខ។ ព្រះអង្គជាទីសក្ការៈ សូមព្រះអង្គយាងទៅកន្លែងដែលព្រះអង្គអាចចូលរួមជាមួយព្រះសង្ឃ និងប្រជាជនចំនួន ៦ លាននាក់របស់យើងនៅក្នុងតំបន់រំដោះ ដើម្បីកសាងប្រទេសកម្ពុជាដែលមានមុខមាត់ថ្មី ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ ប្រជាធិបតេយ្យ និងសម្បូររុងរឿងពិតប្រាកដ ហើយគោរពព្រះពុទ្ធសាសនា ដែលរណសិរ្សរួបរួមជាតិកម្ពុជាយើង ចាត់ទុកថាជាសាសនារបស់រដ្ឋត្រូវថែរក្សាជានិច្ច។

ពេលវេលានៅខ្លីណាស់។ ព្រះអង្គជាទីសក្ការៈ ព្រះអង្គត្រូវតែសម្រេចព្រះទ័យឲ្យបានឆាប់រហ័ស។ ដោយសេចក្តីស្រលាញ់យ៉ាងជ្រាលជ្រៅ និងភក្តីភាពដោយស្មោះត្រង់ ខ្ញុំព្រះករុណា សូមជូនពរព្រះអង្គឲ្យមានព្រះជន្មយឺនយូរ ព្រះសុខភាពល្អ សុភមង្គល កម្លាំងពលៈពេញបរិបូរ និងជ័យជម្នះក្នុងភារកិច្ចរំដោះប្រទេសជាតិយើង និងប្រជាជនយើង។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ជយោ ប្រជាជនកម្ពុជាដ៏អស្ចារ្យ! ជយោ ព្រះពុទ្ធសាសនា! ជយោ កងទ័ពរំដោះជាតិប្រជាជនកម្ពុជា ដ៏ក្លាហាន និងជ័យជម្នះជានិច្ច! ជយោ រណសិរ្សរួបរួមជាតិកម្ពុជា ដ៏រឹងមាំ និងខ្លាំងក្លា!

[00166872]

ជយោ មហាសាមគ្គីភាពរវាងព្រះសង្ឃស្នេហាជាតិ ជាមួយនឹងប្រជាជននៅតំបន់ក្រោមការគ្រប់គ្រង បណ្តោះអាសន្នរបស់ខ្មាំង ដែលកំពុងតែប្រយុទ្ធកម្ចាត់ចក្រពត្តិអាមេរិក និងបរិវារទាំង ៧ នាក់។ ប្រជាជនយើងប្រាកដជារំដោះប្រទេសកម្ពុជាបានទាំងស្រុងនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។

ពីតំបន់រំដោះកម្ពុជា ថ្ងៃទី២២ ខែ មីនា ឆ្នាំ ១៩៧៥

ដោយសេចក្តីគោរព

**សេចក្តីអត្ថាធិប្បាយរបស់វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា សរសើរខួបរណសិរ្សរួបរួមជាតិកម្ពុជា-កងទ័ពរំដោះជាតិប្រជាជនកម្ពុជា**

សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា (សម្ងាត់) ជាភាសាខ្មែរទៅប្រជាជនកម្ពុជា ម៉ោងសកល ០៤០០ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ៧៥

[សេចក្តីអត្ថាធិប្បាយ៖ "មហាជ័យជម្នះជាប្រវត្តិសាស្ត្រដែលប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ទទួលបាននៅក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ"]

[អត្ថបទ] នៅថ្ងៃនេះ ទី២២ ខែមីនា ឆ្នាំ១៩៧៥ គឺមានរយៈពេល ៥ ឆ្នាំគត់ ចាប់តាំងពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ជារយៈពេល ៥ ឆ្នាំដែលឃើញមានមហាជ័យជម្នះលក្ខណៈជាប្រវត្តិសាស្ត្រ។ នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនេះនៃសង្គ្រាមមហាបដិវត្តន៍ដើម្បីរំដោះ

ប្រទេសជាតិ យើងទទួលបានបទពិសោធន៍នៃការតស៊ូបដិវត្តន៍របស់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ជាការតស៊ូដែលកុលបុត្រកុលធីតារបស់ប្រជាជនយើងបានបង្ហូរឈាមនៅលើទឹកដីមាតុភូមិជាទីស្រលាញ់របស់យើង។ ពួកចក្រពត្តិចាស់ថ្មី បារាំង ជប៉ុន និងសហរដ្ឋអាមេរិក បានគ្រប់ដណ្តប់ប្រទេសកម្ពុជា និងវាយប្រហារប្រទេសកម្ពុជា។ ជាពិសេសនៅក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះនៅពេលដែលចក្រពត្តិអាមេរិក និងអាយ៉ងរបស់វា គឺបក្សពួកលន់ នល់ បានសាបព្រួសទុក្ខវេទនា និងមហាវិនាសកម្មមកលើប្រទេសកម្ពុជា និងប្រជាជនកម្ពុជា។ នៅក្នុងរយៈពេលនេះ ដោយសេចក្តីខិតខំប្រឹងប្រែង កុលបុត្រកុលធីតាដ៏ច្រើនសន្ធឹករបស់យើងបានពលីជីវិតដើម្បីរំដោះប្រទេសជាតិមាតុភូមិជាទីស្រលាញ់បំផុតរបស់យើង។

នៅក្នុងជំហរតស៊ូដាច់ខាត ម្ចាស់ការខ្លួនឯង ប្រឈមមុខនឹងគ្រោះអកុសល និងការឈឺចាប់ជាបន្តបន្ទាប់ គឺមានការបែងចែកយ៉ាងច្បាស់រវាងមិត្ត និងសត្រូវ ប្រជាជនយើង ក៏ដូចជា យុទ្ធជន យុទ្ធនារី និងកម្មាភិបាលរបស់យើង ដែលបានឆ្លងកាត់ការតស៊ូបដិវត្តន៍ជាច្រើនឆ្នាំមកហើយ បានក្រោកឡើងដាច់ខាតប្រយុទ្ធវាយខ្លាំង នៅពេលដែលចក្រពត្តិអាមេរិក និងពួកក្បត់ជាតិ លន់ នល់, សេរី មតៈ, សឹង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ,ឡុង បូរ៉េត និង សូស្តែន ហ្វែរណង់ដេស បានធ្វើរដ្ឋប្រហារប្រតិកិរិយា ហ្វាស៊ីសនិយមនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយផ្តួលរំលំប្រទេសកម្ពុជាដែលឯករាជ្យ សន្តិភាព និងអព្យាក្រឹត្យ។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ ១៩៧០ គឺជាថ្ងៃប្រវត្តិសាស្ត្រដែលសម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ និងជាព្រះប្រធានរណសិរ្សរួបរួមជាតិកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍ ៥ ចំណុចជាឱឡារិក អំពាវនាវឲ្យប្រទេសកម្ពុជា និងប្រជាជនកម្ពុជា រួបរួមគ្នា និងពង្រឹងសាមគ្គីភាពគ្នាដើម្បីកម្ចាត់ខ្មាំង ហើយជាថ្ងៃដែលប្រជាជនកម្ពុជា រួមមានព្រះសង្ឃ កម្មករ ពលករ យុវជន កូនសិស្ស និស្សិត បញ្ញាវន្ត និងប្រជាជនផ្សេងទៀតមកពីវណ្ណៈផ្សេងៗ បានក្រោកឡើងធ្វើមហាបាតុកម្មនៅក្នុងការបះបោរដើម្បីកម្ចាត់ផែនការក្បត់ជាតិនៃរដ្ឋ

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

ប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០។ នោះគឺជាពេលបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ហើយកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ត្រូវបានប្រកាសបង្កើតឡើងដោយជោគជ័យ។

នៅក្រោមទង់ដ៏រឹងមាំ និងអស្ចារ្យនៃរណសិរ្សរួបរួមជាតិកម្ពុជា ប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា បានវាយប្រហារចក្រពត្តិអាមេរិក និងបរិវារយ៉ាងខ្លាំងបំផុត និងក្លាហានបំផុត ដោយរក្សាជំហរតស៊ូបដិវត្តន៍ដាច់ខាត មិនរាថយរហូតដល់ទទួលបានជ័យជម្នះដ៏ត្រចះត្រចង់ និងជាប្រវត្តិសាស្ត្រសព្វថ្ងៃនេះ។

ប្រជាជនចំនួន ៦ លាននាក់ត្រូវបានរំដោះទាំងស្រុង។ តំបន់រំដោះដ៏ធំធេងបានក្លាយទៅជាតំបន់រួបរួមគ្នាក្លាយជាប្រទេសពិតប្រាកដដែលមានសមិទ្ធផល ស្ថាប័នយ៉ាងច្រើន និងមានរចនាសម្ព័ន្ធនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងរូបិយវត្ថុពេញលេញនៅគ្រប់កម្រិត។ ឥឡូវនេះ កម្ពុជាគឺជារដ្ឋឯករាជ្យ អធិបតេយ្យ និងម្ចាស់ការខ្ពស់។ ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ យើងកំពុងកសាងប្រទេសកម្ពុជាមួយដែលឯករាជ្យ សន្តិភាព អព្យាក្រឹត្យ និងប្រជាធិបតេយ្យនៅលើទឹកដីអង្គរដ៏បវរ។

[00166873]

នៅក្នុងអំឡុងពេល ៥ ឆ្នាំកន្លងមកនេះ តំបន់រំដោះដ៏រឹងមាំ និងធំធេង បានរីកចម្រើនយ៉ាងខ្លាំង ជាពិសេសក្នុងការកសាងទំនប់ ប្រឡាយ និងអាងទឹក ដើម្បីដោះស្រាយបញ្ហាទឹក និងការបង្កើតក្រុមសាមគ្គីបង្កើនផល។ ទាំងអស់នេះត្រូវបានសម្រេចយ៉ាងឆាប់រហ័សនៅទូទាំងតំបន់រំដោះនៅក្នុងប្រទេសកម្ពុជា ហេតុនេះនាំឱ្យមានការផ្លាស់ប្តូរមិនធ្លាប់មានពីមុនមកកែប្រែតំបន់ជនបទនៅក្នុងប្រទេស។

សមិទ្ធផលទាំងនេះបានពង្រឹងអំណាចគ្រប់គ្រងរបស់យើងថែមទៀត ជាមូលដ្ឋាននៃប្រទេសកម្ពុជាដែលមានមុខមាត់ថ្មី ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធ រឹងប៉ឹង និងសម្បូររុងរឿង ដើម្បីសុភមង្គលរបស់ប្រជាពលរដ្ឋជនជាតិផ្សេងៗ ជាពិសេសប្រជាជនក្រីក្រ កម្មករ កសិករ ដែលជាម្ចាស់

ប្រទេស និងជាម្ចាស់ដី។ នៅពេលដំណាលគ្នានេះដែរ សមិទ្ធផលនេះគឺការអះអាងធានាយ៉ាងអស្ចារ្យ សម្រាប់មហាចលនាវាយសម្រុកនាពេលបច្ចុប្បន្ននេះប្រឆាំងនឹងខ្មាំងនៅជួរមុខ នៅក្នុងសង្គ្រាមប្រជាជនដ៏អស្ចារ្យ និងជ័យជម្នះដែលកំពុងវាយសម្រុកយ៉ាងសន្ធាប់ទៅលើពួកក្បត់ជាតិទាំង ៧ នាក់។

ខួបលើកទី ៥ នៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា បានប្រារព្ធធ្វើឡើងក្នុងពេលមួយដែលល្អបំផុតនៅពេលដែលកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង បានរំដោះទន្លេមេគង្គទាំងស្រុង គ្រប់គ្រងសភាពការណ៍នៅមូលដ្ឋានអ្នកលឿង និងនៅតាមទន្លេមេគង្គចម្ងាយប្រហែលជិត ១០០ ម៉ែត្រ ពីភ្នំពេញ ទៅព្រំដែនវៀតណាមខាងត្បូង បានឡោមព័ទ្ធវាយប្រហារភ្នំពេញ និងពោធិ៍ចិនតុង ពីគ្រប់ទិស ហើយបានបោសសម្អាតខ្មាំងជាបន្តបន្ទាប់ឲ្យចេញពីតំបន់នៅជុំវិញភ្នំពេញ ហេតុនេះធ្វើឲ្យភ្នំពេញនៅឯកា បានផ្តាច់ច្រកផ្លូវទឹកតាមទន្លេ និងលើគោកទាំងអស់ ព្រមទាំងឲ្យទីក្រុងនេះក្លាយជាតំបន់តូចមួយដែលរងការបាញ់កាំភ្លើងធំយ៉ាងធ្ងន់ធ្ងរ យ៉ាងខ្លាំងក្លាពីកងទ័ពយើង និងជាកន្លែងដែលប្រជាជន យុវជន សិស្ស និស្សិត គ្រូបង្រៀន មន្ត្រីបម្រើការងារ និងទាហាន កំពុងក្រោកឡើងធ្វើកុបកម្មដូចភ្នំភ្លើងកំពុងផ្ទុះឡើង។ ដោយសារមិនមានអង្ករ គ្រាប់សព្វាវុធ ប្រេងឥន្ធនៈ ហើយទទួលរងការវាយសម្រុកដ៏អស្ចារ្យរបស់យើងនៅភ្នំពេញ និងទីរួមខេត្តទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំងនោះ ពួកក្បត់ជាតិ ៧ នាក់នេះ នឹងត្រូវកម្ចាត់ចោលទាំងស្រុងដោយប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង នៅក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។

ជាមួយនឹងមហាជ័យជម្នះដែលទទួលបាននៅក្នុងប្រទេស ប្រទេសកម្ពុជា ប្រជាជនកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក៏សម្រេចបានជ័យជម្នះដ៏ត្រចះត្រចង់នៅលើឆាកអន្តរជាតិផងដែរ។ អត្តសញ្ញាណបដិវត្តន៍របស់ប្រទេសកម្ពុជានិងប្រជាជនកម្ពុជា បានលេចឡើងខ្ពស់ត្រដែតនៅទូទាំងពិភពលោក។ ប្រជាជាតិជាមិត្តទាំងអស់ នៅជិត នៅឆ្ងាយ និងប្រជាជាតិដែលស្រលាញ់សន្តិភាពទាំងអស់នៅលើពិភពលោក មានសេចក្តីរីករាយជាមួយនឹងជ័យជម្នះ

របស់យើង ហើយបង្ហាញភាពរំជើបរំជួល និងការគាំទ្រជាបន្តបន្ទាប់ដល់យើង។ ជ័យជម្នះដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្ររបស់ប្រជាជនយើង គឺបានដោយសារមាគ៌ាបដិវត្តន៍ដ៏ត្រឹមត្រូវ ឈ្លាសវៃ ភាពក្លាហានរបស់ប្រជាជនកម្ពុជាយើង និងអំណាចនៃកងទ័ពរំដោះជាតិប្រជាជនកម្ពុជា វីរភាពបដិវត្តន៍ដ៏ខ្ពស់ខ្ពង់របស់យុទ្ធជន និងកម្មាភិបាលរបស់យើង បុរស នារី កម្មករ កសិករក្រីក្រ មហាកម្លាំងដ៏រឹងប៉ឹងរបស់កងនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងដោយសារការចាត់ចែង និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃកម្លាំងបដិវត្តន៍ដែលសម្រេចបានដោយ រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅក្នុងវិស័យផ្សេងៗ ជាពិសេស ជំហរ និងមាគ៌ាប្តេជ្ញាវាយសម្រុកឲ្យបានជ័យជម្នះ ទទួលបានឯករាជ្យភាព អធិបតេយ្យភាព និងជម្នះគ្រប់ការលំបាក និងឧបសគ្គទាំងអស់។

ការតស៊ូអូសបន្លាយពេលយូររបស់ប្រជាជនកម្ពុជាយើង បានជួយយើងឲ្យមើលឃើញយ៉ាងច្បាស់ថែមទៀតអំពីលក្ខណៈរឹងរូសរបស់ខ្មាំង ចក្រពត្តិអាមេរិក និងបរិវារទាំងអស់។ ហេតុនេះ ប្រទេសកម្ពុជា និងប្រជាជនកម្ពុជាទាំងមូល កងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រមទាំងយុទ្ធជន យុទ្ធនារី កម្មាភិបាលយើងទាំងអស់ ប្តេជ្ញាចិត្តរក្សាការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ថែមទៀត ហើយបន្តវាយសម្រុកដាច់ខាតរហូតបោសសម្អាតខ្មាំងបានទាំងស្រុង និងបង្កើតបានប្រទេសកម្ពុជាមួយដែលមាមុខមាត់ថ្មី ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ អធិបតេយ្យ ប្រជាធិបតេយ្យ និងសម្បូររុងរឿង មានបរណភាពទឹកដីពិតប្រាកដជានិរន្ត។

នៅក្នុងឱកាសនេះ ប្រទេសកម្ពុជា ប្រជាជនកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ប្រជាជាតិ និងប្រទេសជាមិត្តទាំងអស់ នៅជិត នៅឆ្ងាយ ព្រមទាំងប្រជាជាតិទាំងអស់ដែលស្រលាញ់សន្តិភាពរួមមានជនជាតិអាមេរិកចម្រើននិយម ដែលបានជួយគាំទ្របុព្វហេតុដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជាយើង។ នៅពេលអនាគតដ៏ខ្លីខាងមុខនេះ ដោយមានការគាំទ្រពីប្រជាជននៅលើពិភពលោក ប្រជាជនកម្ពុជាយើង

និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ប្រាកដជារំដោះភ្នំពេញ និងប្រទេសកម្ពុជា បានទាំងស្រុង។ ជយោ ខួបលើកទី ៥ ដ៏ជោគជ័យនៃរណសិរ្សរួមរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា!

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[00166874]

**សេចក្តីថ្លែងការណ៍ថ្ងៃទី២២ ខែមីនា របស់រាជរដ្ឋាភិបាលរួមរួមជាតិកម្ពុជា នៅខួបរណសិរ្សរួបរួមជាតិកម្ពុជា-កងទ័ពរំដោះជាតិប្រជាជនកម្ពុជា**

ទីភ្នាក់ងារព័ត៌មានកម្ពុជា (សម្ងាត់) ជាភាសាបារាំង ប្រចាំអាស៊ីខាងកើត ម៉ោងសកល ១១១៦ ថ្ងៃទី២៥ ខែមីនា ឆ្នាំ៧៥ បាងកក

[សេចក្តីថ្លែងការណ៍ថ្ងៃទី២២ ខែមីនា របស់រាជរដ្ឋាភិបាលរួមរួមជាតិកម្ពុជា នៅខួបរណសិរ្សរួបរួមជាតិកម្ពុជា-កងទ័ពរំដោះជាតិប្រជាជនកម្ពុជា]

[អត្ថបទ] ប្រទេសកម្ពុជា ថ្ងៃទី ២៥ ខែ មីនា AKI-ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ គឺជាខួបលើកទី ៥ នៃការបង្កើតរណសិរ្សរួមរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា។ ក្នុងរយៈ ៥ឆ្នាំកន្លងមកនេះនៃការតស៊ូប្តូរផ្តាច់ដាច់ខាតប្រឆាំងនឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិក និងពួកក្បត់ជាតិនៅភ្នំពេញ រណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា បានធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់លើរាល់ប្រតិបត្តិការ និងយុទ្ធសាស្ត្រយោធាទាំងអស់របស់ខ្មាំង។

[00166875]

នៅថ្ងៃទីនេះ រណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា បានរំដោះដែនដីជាតិចំនួន ៩៧ ភាគរយ និងប្រជាជនចំនួន ៦ លាននាក់។ រណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាគឺកម្លាំងជំរុញទឹកចិត្តយ៉ាងខ្លាំងសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ក្រៅពីពួកក្បត់ជាតិមួយក្តាប់តូចចេញ ដែលជាឧបករណ៍នៃអាណានិគមនិយមថ្មីរបស់ចក្រពត្តិអាមេរិកនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានគុណសម្បត្តិ និងទទួលខុសត្រូវជារដ្ឋកម្ពុជា ដែលឯករាជ្យ អធិបតេយ្យ អ

ព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធ និងប្រជាធិបតេយ្យ ដែលបានបង្កើតឡើងនៅក្នុងតំបន់រំដោះ ហើយមានទំនាក់ទំនងការទូតជាមួយនឹងរដ្ឋអធិបតេយ្យចំនួនជាង ៦០។

បច្ចុប្បន្ននេះ ដោយសារកំពុងរងការវាយប្រហារហិង្សា និងឥតប្រណីពីប្រជាជនយើង និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង ពួកក្បត់ជាតិមួយក្តាប់តូចនៅភ្នំពេញកំពុងប្រឈមមុខនឹងសភាពការណ៍លំបាកយ៉ាងខ្លាំង។ គ្រប់គ្នាយល់ស្របថា ពេលចុងបញ្ចប់របស់ពួកវាជិតចូលមកដល់ហើយចៀសមិនរួចឡើយ។

ប៉ុន្តែ ទោះបីជាមានការប្រឆាំងពីប្រជាជនអាមេរិក ឥស្សរជន និងប្រជាជាតិដែលស្រលាញ់សន្តិភាព និងយុត្តិធម៌នៅទូទាំងពិភពលោកក៏ដោយ ក៏រដ្ឋបាលហ្វដ- ឃីសស៊ីងហ្គ័រ (Ford-Kissinger) នៅតែបន្តធ្វើអន្តរាគមន៍នៅក្នុងប្រទេសកម្ពុជាដែរ ដោយបង្កើនប្រតិបត្តិការតាមយន្តហោះ និងប្រើប្រាស់ពាក្យកុហក និងការលាក់បាំងដើម្បីបន្តជួយពួកក្បត់ជាតិនៅភ្នំពេញ។ លើសពីនេះទៀត វាបានបញ្ជូនកងនាវាចម្បាំងទី ៧ រួមមាននាវាដឹកឧទ្ធម្ភាគចក្រ Okinawa ដោយមានទ័ពម៉ារីនប៉ុន្មានពាន់នាក់មកឈូងសមុទ្រថៃ ដើម្បីត្រៀមធ្វើអន្តរាគមន៍នៅក្នុងប្រទេសកម្ពុជា នៅពេលណាមួយ។

ដូច្នេះ ជាជាងបញ្ចប់ការឈ្លានពានរបស់ចក្រពត្តិអាមេរិក រដ្ឋបាលហ្វដ- ឃីសស៊ីងហ្គ័រ នៅតែបន្តធ្វើសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ហើយសាបព្រួសវិនាសកម្ម និងទុក្ខវេទនា ដើម្បីរក្សាអាណានិគមនិយមរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងឱកាសដ៏ឱឡារិកនៃខួបលើកទី ៥ នៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាសូមបញ្ជាក់សាជាថ្មីថា គោលបំណងរបស់ប្រជាជនកម្ពុជា និងការតស៊ូរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជា ក្រោមការណែនាំរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺដើម្បីបង្កើតឡើងវិញនូវប្រទេសកម្ពុជាមួយ ដែលឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធ។ តាមពិត ប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ប្តេជ្ញាចិត្តបន្តការតស៊ូ

ដ៏ត្រឹមត្រូវរបស់ខ្លួនរហូតដល់បានបញ្ឈប់អន្តរាគមន៍ដោយផ្ទាល់ ឬដោយប្រយោងទាំងអស់របស់ចក្រពត្តិអាមេរិក។ ការបន្តអន្តរាគមន៍ដ៏ឆ្កួតលីលារបស់រដ្ឋបាលហ្វដ- ឃីសស៊ីងហ្គ័រ ការផ្តល់ជំនួយ និងការគាំទ្រដ៏រឹងរូសរបស់រដ្ឋបាលនេះដែលជួយដល់ពួកជនក្បត់ជាតិនៅភ្នំពេញ មិនអាចរារាំងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មិនឲ្យបញ្ចប់វត្តមានរបស់ពួកក្បត់ជាតិបានឡើយ ទោះត្រូវចំណាយអស់អ្វីក៏ដោយ ហើយទាំងអស់នេះពង្រឹងការប្តេជ្ញាចិត្តត្រូវបន្តការតស៊ូដ៏ត្រឹមត្រូវ ជាដាច់ខាត មិនរាថយឡើយរហូតដល់សម្រេចបានជាស្ថាពរនូវចំណុចទាំង ៥ នៅក្នុងសេចក្តីថ្លែងការណ៍ថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧០ របស់សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ និងជាព្រះប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា។ កិច្ចការរបស់ប្រទេសកម្ពុជាត្រូវតែដោះស្រាយ ដោយគ្មានការជ្រៀតជ្រែកពីបរទេស ត្រូវតែដោះស្រាយដោយប្រជាជនកម្ពុជាខ្លួនឯង ដែលមានតំណាងស្របច្បាប់តែមួយគត់គឺរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយមានសម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រី និងលោកខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានកម្លាំងស្នេហាជាតិទាំងអស់នៅក្នុងប្រទេស ដែលមានតំណាងរបស់ខ្លួននៅក្នុងជួរ។ នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះនៃការតស៊ូ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានបង្ហាញភាពចាស់ទុំ និងគុណសម្បត្តិពេញលេញដើម្បីគ្រប់គ្រងកិច្ចការរដ្ឋប្រកបដោយជោគជ័យ។

សង្គ្រាមនៅក្នុងប្រទេសកម្ពុជានឹងត្រូវបញ្ចប់ ហើយសន្តិភាពពិតប្រាកដនឹងស្តារបានឡើងវិញ ក្រោយពីអន្តរាគមន៍ទាំងអស់របស់រដ្ឋបាលហ្វដ- ឃីសស៊ីងហ្គ័រ បានបញ្ចប់។ កិច្ចការកម្ពុជានឹងត្រូវដោះស្រាយដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតជាតិលើកទីពីរ។ សមាជិកទាំងអស់នៃអង្គការយោធា និងពាក់កណ្តាលយោធាដែលបម្រើពួកក្បាត់ជាតិនៅភ្នំពេញ ត្រូវតែទម្លាប់អាវុធចុះ ហើយចុះចាញ់ជាមួយកងទ័ពរំដោះជាតិប្រជាជនកម្ពុជា។ ក្រៅពីពួកក្បត់ជាតិមួយក្តាប់តូច

នៅភ្នំពេញចេញ ពលរដ្ឋគ្រប់រូបនឹងស្ថិតនៅក្នុងសហគមន៍ជាតិដើម្បីកសាងប្រទេសកម្ពុជាមួយដែលឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធ និងសម្បូររុងរឿង។

រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បញ្ជាក់សាឡើងវិញថា ខ្លួននឹងប្រកាន់ខ្ជាប់ជានិច្ចនូវគោលនយោបាយជាតិ គឺការរួបរួមជាតិទាំងមូល ដោយមិនរើសអើងវណ្ណៈ និន្នាការនយោបាយ ឬជំនឿសាសនា ហើយមិនគិតពីអតីតកាលរបស់ពលរដ្ឋគ្រប់រូបឡើយ ក្រៅពីពួកក្បត់ជាតិមួយក្តាប់តូចនៅភ្នំពេញ។

[00166876]

ចំពោះគោលនយោបាយការបរទេស រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បញ្ជាក់សាជាថ្មីនូវការបន្តគោលនយោបាយអព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធ ហើយប្រកាន់ខ្ជាប់ជាដាច់ខាតនូវគោលការណ៍ទាំងប្រាំនៃសហអត្ថិភាពដោយសន្តិភាពនៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងប្រទេសទាំងអស់ផ្សេងទៀត នៅជិតឬឆ្ងាយ ដោយមិនប្រកាន់ប្រព័ន្ធនយោបាយ និងសង្គមឡើយ ហើយដោយផ្អែកលើគោលការណ៍សមភាព ការគោរពគ្នា ផលប្រយោជន៍ទៅវិញទៅមក មិនឈ្លានពាន និងមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសផ្សេង។

ប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា សូមអរគុណយ៉ាងច្រើនជាថ្មីម្តងទៀតដល់រដ្ឋាភិបាល និងប្រទេសជាមិត្តទាំងអស់ ប្រជាជាតិដែលស្រលាញ់សន្តិភាព និងយុត្តិធម៌នៅសហរដ្ឋអាមេរិក និងនៅទូទាំងពិភពលោក ព្រមទាំងអង្គការអន្តរជាតិ និងប្រជាធិបតេយ្យទាំអស់ ដែលបានជួយគាំទ្រការតស៊ូដ៏ត្រឹមត្រូវដើម្បីរំដោះជាតិកម្ពុជា ហើយជឿជាក់ថា ជំនួយ និងការគាំទ្រនេះនឹងបន្តកើនឡើងថែមទៀតរហូតដល់ទទួលបានជ័យជម្នះទាំងស្រុង។

ដើម្បីកាត់បន្ថយការឈឺចាប់ និងគ្រោះអកុសលរបស់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជា និងដើម្បីស្តារឡើងវិញនូវសន្តិភាពពិតប្រាកដយូរអង្វែងនៅក្នុងប្រទេសកម្ពុជាឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន

រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមអំពាវនាវដល់សមាជិកទាំងអស់នៃអង្គការឃោធា និងពាក់កណ្តាលឃោធារបស់របបក្បត់ជាតិនៅភ្នំពេញ លះបង់ឋានៈរបស់ខ្លួន ហើយបង្វែរអាវុធទៅប្រឆាំងពួកក្បត់ជាតិវិញ។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សូមអំពាវនាវដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈទាំងអស់នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង សូមរួបរួមគ្នាធ្វើការវាយប្រហារផ្សេងៗឲ្យបានច្រើនប្រឆាំងនឹងពួកក្បត់ជាតិ ដើម្បីកម្ចាត់ពួកវាចោល។ សូមប្រជាជនកម្ពុជាទាំងអស់ ដែលរួបរួមគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងកងទ័ពរំដោះជាតិប្រជាជានកម្ពុជា នៅជួរមុខ និងនៅជួរក្រោយ នៅក្នុងតំបន់រំដោះ ព្រមទាំងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង មេត្តាបង្កើនលទ្ធភាពប្រយុទ្ធទ្វេដង និងបង្កើនការតស៊ូប្រឆាំងនឹងពួកឈ្លានពានចក្រពត្តិអាមេរិក និងបរិវារ គឺពួកក្បត់ជាតិនៅភ្នំពេញ ដើម្បីរំដោះប្រទេសកម្ពុជា និងប្រជាជនកម្ពុជាឲ្យបានទាំងស្រុង និងជានិរន្ត!

[00166878]

## សីហនុ ប្រកាសនៅថ្ងៃទី២១ ខែមីនា ថា "ជនមហាក្បត់ជាតិ"នឹងត្រូវកាត់ទោស

ទីក្រុងប៉ារីស សារព័ត៌មាន AFP ជាភាសាអង់គ្លេស ម៉ោងសកល ១១៥១ ថ្ងៃទី២៦ ខែ មីនា ឆ្នាំ ៧៥

[អត្ថបទ] ទីក្រុងប៉េកាំង ថ្ងៃទី២៦ ខែមីនា (AFP)-- នៅថ្ងៃនេះ ព្រះអង្គម្ចាស់នរោត្តម សីហនុ ព្រះប្រធានរណសិរ្សរួបរួមជាតិកម្ពុជា បានប្រកាសឈ្មោះ"ជនមហាក្បត់ជាតិ"កម្ពុជាចំនួន ២១ នាក់ដែលនឹងត្រូវកាត់ទោសជា "ឧក្រិដ្ឋកម្មសង្គ្រាម"។ ព្រះអង្គបានបន្ថែមឈ្មោះទាំងនេះចូលក្នុងបញ្ជីឈ្មោះ "ជនមហាក្បត់ជាតិ" ចំនួន ៧ នាក់ដែលខ្មែរក្រហមបានថ្កោលទោសឲ្យប្រហារជីវិតរួចហើយ។

នៅក្នុងសេចក្តីថ្លែងការណ៍មុនៗ ព្រះអង្គម្ចាស់ធ្លាប់មានបន្ទូលថា ក្រៅពីក្រុមទីមួយនៃជនក្បត់ជាតិចំនួន ៧ នាក់ រួមមានប្រធានាធិបតី លន់ នល់ និងនាយករដ្ឋមន្ត្រី ឡុង បូរ៉េត នោះ "ជនក្បត់ជាតិ" ទាំងអស់ផ្សេងទៀតនឹងត្រូវលើកលែងទោសប្រសិនបើពួកគេចូលរួមខាងរណសិរ្សរួបរួមជាតិកម្ពុជា។

Original EN: 00166779-00166887

Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

សេចក្តីថ្លែងការណ៍របស់ព្រះអង្គម្ចាស់ បានលើកឡើងថា ក្រុមទីពីរនៃជនក្បត់ជាតិនេះគឺជាឧក្រិដ្ឋកម្មសង្គ្រាមសុទ្ធសាធដែលក្រោយពីរំដោះភ្នំពេញ ត្រូវតែមកឆ្លើយនៅចំពោះមុខតុលាការរបស់រដ្ឋចំពោះអំពើព្រៃផ្សៃ និងឧក្រិដ្ឋកម្មគួរភ័យរន្ធត់មិនអាចគណនាបានដែលជនរងគ្រោះក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះគឺប្រទេសជាតិ ប្រជាជន ជាតិ និងរដ្ឋកម្ពុជា”។

[00166881]

**សេចថ្លែងការណ៍ថ្ងៃទី២៦ ខែមីនារបស់ សីហនុ បន្ថែមឈ្មោះឧក្រិដ្ឋកម្មសង្គ្រាម**

ទីក្រុងប៉េកាំង NCNA ជាភាសាអង់គ្លេស ម៉ោងសកល ១៥៥៨ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ៧៥

[អត្ថបទ] ទីក្រុងប៉េកាំង ថ្ងៃទី២៧ ខែមីនា ឆ្នាំ ១៩៧៥ (ស៊ីនហួរ)--នៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីម្សិលម៉ិញ សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា បានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់ប្រជាជនកម្ពុជាក្នុងការតស៊ូរហូតដល់ទីបញ្ចប់។

សេចក្តីថ្លែងការណ៍នេះបានចេញពាក់ព័ន្ធនឹងការពិតដែលថា សហរដ្ឋអាមេរិក នាពេលថ្មីៗនេះ បានជំរុញឲ្យលោក ឡុង បូរ៉េត ធ្វើការអំពាវនាវក្នុងនាមជា “នាយករដ្ឋមន្ត្រី” នៃរដ្ឋាភិបាលថ្មីរបស់ “សាធារណរដ្ឋខ្មែរ” ឲ្យ “ប្រជាជនកម្ពុជាភាគីម្ខាងទៀត” ចរចាឈប់បាញ់គ្នា និង “ផ្សះផ្សាជាតិ”។

សេចក្តីថ្លែងការណ៍នេះលើកឡើងថា៖ “ឡុង បូរ៉េត ខ្លួនគាត់ ត្រូវបានកាត់ទោសប្រហារជីវិតរួចហើយដោយប្រជាជនកម្ពុជា នៅក្នុងមហាសន្និបាតជាតិ (នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៥)”។ ចក្រពត្តិអាមេរិក នឹងមានការយល់ច្រឡំធំប្រសិនបើខ្លួនជឿថា ឡុង បូរ៉េត ដឹងច្បាស់ជាង លន់ នល់ [អំពីវិធី]បន្ទន់ឆន្ទៈរបស់ជនស្នេហាជាតិខ្មែរក្រហម ហើយឲ្យជនស្នេហាជាតិខ្មែរក្រហម ចូលរួមជាមួយនឹង “សាធារណរដ្ឋ” ក៏ស្មោគគ្រោគរបស់គាត់”។

សេចក្តីថ្លែងការណ៍នេះលើកឡើងថា ទោះបីជា ហង្ស ធនហាក់, ប៉ាន់ សុទ្ធី (Pan Sothi), សាក ស៊ុតសាខន (Sak Sutsakhan), លន់ នល់ និងជនមហាក្បត់ជាតិផ្សេងទៀតមិនត្រូវបានកាត់ទោសប្រហារជីវិតដោយមហាសន្និបាតជាតិរបស់ប្រជាជនកម្ពុជាក៏ដោយ ក៏ពួកគេគឺជាឧក្រិដ្ឋកម្មសង្គ្រាមពិតប្រាកដ ហើយនឹងសារភាពពីឧក្រិដ្ឋកម្មរបស់ខ្លួននៅចំពោះមុខតុលាការយុត្តិធម៌របស់រដ្ឋក្រោយពីរំដោះភ្នំពេញ។

សេចក្តីថ្លែងការណ៍នេះលើកឡើងថា៖ "ដោយឲ្យជនមហាក្បត់ជាតិទាំងនេះដែលពុករលួយ និងហ្វាស៊ីសជនមហាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋជនដ៏ថោកទាប" ធ្វើជាដៃគូសន្ទនាជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ចក្រពត្តិអាមេរិកកំពុងតែមើលងាយមិនអាចអត់ទោសឲ្យបានឡើយមកលើវិញ្ញាណក្ខន្ធរបស់ជនស្នេហាជាតិកម្ពុជា បុរស នារី ដែលបានពលីជីវិតដើម្បីឧត្តមភាពស្អាតស្អំបំផុត និងខ្ពស់ខ្ពង់បំផុតរបស់ប្រជាជនកម្ពុជា"។

សេចក្តីថ្លែងការណ៍នេះលើកឡើងថា៖ "រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងសម្តេចនរោត្តម សីហនុ ស្បថថានឹងប្រយុទ្ធរហូតដល់ស្លាប់ប្រឆាំងនឹងចក្រពត្តិអាមេរិក និងដៃជើងរបស់ចក្រពត្តិអាមេរិក ដរាបណាយើងនៅមានដង្ហើម"។

សេចក្តីថ្លែងការណ៍នេះលើកឡើងថា "ប្រសិនបើជនឈ្លានពានអាមេរិក ប៉ិនចាប់ផ្តើមប្រផុយប្រឆាំងនឹងប្រជាជនយើង នោះប្រជាជនយើងអាចទប់ទល់ដោយជោគជ័យប្រឆាំងនឹងការឈ្លានពានមហាឧក្រិដ្ឋ និងគួរឲ្យស្អប់ខ្ពើមនេះ"។

[00166883]

**អតីតមេដឹកនាំចេង ហេង នៅបាងកក ក្នុងដំណើរទៅប៉ារីស**

បាងកកប៉ុស្តិ៍ ជាភាសាអង់គ្លេស ថ្ងៃទី៣០ ខែ មីនា ឆ្នាំ ៧៥ ទំព័រ ១ បាងកក

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[អត្ថបទ] លោក ចេង ហេង អតីតប្រមុខរដ្ឋកម្ពុជា និងគ្រួសារ បានចាកចេញពីភ្នំពេញ ហើយជិះយន្តហោះចូលបាងកក តាមជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍អ៊ែរកាំបូជ នៅវេលាម៉ោង ៥ ល្ងាចកាលពីម្សិលម៉ិញ។

[00166884]

លោក ចេង ហេង អាយុ ៥៩ ឆ្នាំ ជាឥស្សរជនម្នាក់ក្នុងចំណោមឥស្សរជនដែលមានឈ្មោះក្នុងបញ្ជីមរណៈរបស់ក្រុមបះបោរខ្មែរ។ លោក ចេង ហេង ត្រូវបានបញ្ជូនយ៉ាងប្រញាប់ប្រញាល់ទៅសណ្ឋាគារអាម៉ារីន ប៉ុន្តែ មិនមានបន្ទប់ទំនេរសម្រាប់គាត់ទេ។ មានសេចក្តីរាយការណ៍ថា បន្ទាប់មក គាត់ផ្លាស់ទៅសណ្ឋាគារនាគមាស នៅទីកដីសុខុមវីត។

ប្រភពនានាពីព្រលានយន្តហោះ បាននិយាយថា គេរំពឹងថា លោក ចេង ហេង នឹងចាកចេញទៅប៉ារីស នៅថ្ងៃនេះ តាមជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍អ៊ែរហ្វ្រង់។

យោងតាម UPI បានឲ្យដឹងថា លោក ចេង ហេង បានជិះយន្តហោះនៅភ្នំពេញ ដោយពាក់មួកដែក និងអាវគ្រោះ។

[00166885]

**ហ៊ូ យន់ នៅរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចេញសេចក្តីអំពាវនាវទៅតំបន់ "ក្រោមការគ្រប់គ្រងរបស់ខ្មាំង"**

ទីភ្នាក់ងារព័ត៌មានកម្ពុជា (សម្ងាត់)ជាភាសាបារាំង ប្រចាំអាស៊ីខាងកើត ម៉ោងសកល ១៣០០ ថ្ងៃទី២៩ ខែមីនា ឆ្នាំ៧៥ បាងកក

[ថ្ងៃទី២០ ខែ មីនា "សេចក្តីអំពាវនាវរបស់ ហ៊ូ យន់ ទៅប្រជាជននៅតំបន់ក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង"]

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

[អត្ថបទ] ប្រទេសកម្ពុជា ថ្ងៃទី២០ ខែមីនា AKI--នៅថ្ងៃនេះ ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កំណែទម្រង់រួម និងសហករណ៍នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានធ្វើការអំពាវនាវទៅមន្ត្រីបម្រើការងារនៅវិស័យផ្សេងៗ ទាហាន និងនគរបាលនៅក្នុងឋានៈ និងក្រុមផ្សេងៗ ព្រមទាំង យុវជន សិស្សសាលា និស្សិត និងបញ្ញវន្តនៅភ្នំពេញ និងតំបន់មួយចំនួនតូចដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង ដោយស្នើសុំអ្នកទាំងនោះពង្រឹងការតស៊ូរបស់ខ្លួនដើម្បីបញ្ចប់របបប្រឆាំងជាតិស៊ូពួជ ហ្វាស៊ីសស៊ូពួជ និងពុករលួយស៊ូពួជរបស់បនក្បត់ជាតិលន់ នល់ នៅភ្នំពេញ។

សេចក្តីអំពាវនាវនេះមានខ្លឹមសារទាំងស្រុងដូចខាងក្រោម៖ ជូនចំពោះមន្ត្រីបម្រើការងារនៅក្នុងឋានៈ និងវិស័យផ្សេងៗ ទាហាន និងនគរបាលនៅក្នុងឋានៈ និងក្រុមផ្សេងៗ៖

មិត្ត យុវជន សិស្សសាលា និស្សិត និងបញ្ញវន្ត ជាទីរាប់អាន!

នៅក្នុងការប្រឈមមុខនឹងការវាយសម្រុកដ៏មហិមា និងលាន់រំពងរបស់កងទ័ពរំដោះជាតិប្រជាជានកម្ពុជាពីគ្រប់ទិសទាំងអស់នៅក្នុងរយៈពេលបីខែនៅរដូវប្រាំងនេះ ពួកក្បត់ជាតិ លន់ នល់, សេរី មតៈ, សឹង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្តែន ហ្វែរណាង់ដេស ត្រូវស្ថិតនៅក្នុងសភាពទាស់ទែងគ្នា និងច្របូកច្របល់កាន់តែធ្ងន់ធ្ងរ ហើយកំពុងតែប្រកាច់ប្រកិនឈឺចាប់នៅតាមដងទន្លេមេគង្គខាងក្រោមភ្នំពេញនៅភ្នំពេញ និងនៅទីរួមខេត្តមួយចំនួនដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ពួកគេ។

នៅគ្រប់មុខព្រួញទាំងអស់ កងទ័ពរបស់ពួកគេស្ថិតនៅក្នុងសភាពបាក់ទឹកចិត្ត និងអស់សង្ឃឹម ហើយដួលរំលំជាច្រើននាក់ជារៀងរាល់ថ្ងៃ។ កងទ័ពរបស់ពួកគេកំពុងបន្តប្រយុទ្ធដកថយ តែផ្ទុយមកវិញ កងទ័ពរំដោះជាតិប្រជាជនកម្ពុជារបស់យើងកំពុងឈានទៅមុខជានិច្ច។ ភ្នំពេញ ដែលជាជម្រកចុងក្រោយរបស់ពួកក្បត់ជាតិត្រូវបានឡោមព័ទ្ធយ៉ាងតឹងរឹង ហើយដាក់ឲ្យនៅឯកាទាំងស្រុងដោយសារប្រជាជនយើង និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាយើង ដែលកំពុងជាន់ខ្នាំងឲ្យនៅក្រោមជើងជាប់ណែន មិនឲ្យរួចចេញឡើយ។

Original EN: 00166779-00166887
Translated: [00166785]; [00166786]; [00166787]; [00166788]; [00166791]; [00166792]; [00166793]; [00166794]; [00166795]; [00166796]; [00166798]; [00166803]; [00166804]; [00166807]; [00166808]; [00166811]; [00166812]; [00166813]; [00166814]; [00166815]; [00166816]; [00166817]; [00166819]; [00166820]; [00166821]; [00166822]; [00166823]; [00166824]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166849]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]; [00166830]; [00166837]; [00166838]; [00166839]; [00166840]; [00166841]; [00166842]; [00166843]; [00166845]; [00166846]; [00166847]; [00166850]; [00166851]; [00166864]; [00166865]; [00166866]; [00166867]; [00166868]; [00166869]; [00166870]; [00166871]; [00166872]; [00166873]; [00166874]; [00166875]; [00166876]; [00166878]; [00166881]; [00166883]; [00166884]; [00166885]; [00166886]; [00166887]

នៅក្នុងខែមីនា នេះ ពួកក្បត់ជាតិទាំង ៧ នាក់នៅភ្នំពេញ លន់ នល់, សេរី មតៈ, សឹង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វែរណង់ដេស បានចាញ់រួចទៅហើយ។ សាធារណរដ្ឋក្លែងក្លាយរបស់ពួកគេនឹងត្រូវដួលរលំចៀសមិនរួចឡើយ។ នៅសហរដ្ឋអាមេរិក មនុស្សគ្រប់គ្នា ចាប់ពីប្រជាពលរដ្ឋសាមញ្ញ សមាជិកសភា ប្រមុខរដ្ឋ និងអ្នកសារព័ត៌មាន រហូតដល់Gerald Ford និង Henry Kissinger ខ្លួនពួកគេផ្ទាល់ដែលជាមេខ្លោងដ៏សាហាវ និងរឹងរូសបំផុតរបស់ចក្រពត្តិអាមេរិក សុទ្ធតែមានអារម្មណ៍ថា ពួកបនលន់ នល់ នឹងដួលរលំហើយ។ នៅទូទាំងពិភពលោក មិត្ត និងសត្រូវរបស់ពួកក្បត់ជាតិនេះសុទ្ធតែមានការយល់ឃើញដូចគ្នានេះដែរ។

[00166886]

ពួកបនក្បត់ជាតិនឹងដួលរលំ ពីព្រោះថា ពួកវាគ្មានផ្លូវដឹកជញ្ជូនទៅភ្នំពេញឡើយ ជាពិសេស ទន្លេមេគង្គ ត្រូវបានបិទខ្ទប់ទាំងស្រុងអស់ជាច្រើនខែមកហើយ។ ពួកវានឹងដួលរលំ ពីព្រោះថា ពួកវា លែងមានសេដ្ឋកិច្ចស្ថិតស្ថេរ ឬស្បៀង ប្រេងឥន្ធនៈ លុយ ឬអង្ករដឹកទៅអ្នកបម្រើការងារ នគរបាល និងទាហានរបស់ពួកវាហើយ ដោយសារថា ពួកវាកំពុងតែខ្វះទាហានក្រោយពីបាត់បង់ទ័ពជាច្រើននាក់--គឺមានការស្លាប់ធ្ងន់ធ្ងរ ការរត់ចោលជួរ និងការចុះចាញ់ជាច្រើននាក់ និងដោយសារថា ពួកវាមិនអាចជ្រើសរើសទ័ពថ្មីដើម្បីបង្គ្រប់ចំនួនដែលបានបាត់បង់ជាច្រើននាក់បានវិញលើយ។ ចុងក្រោយ ពួកវានឹងដួលរលំ ដោយសារថា ប្រជាជន និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាកំពុងបន្តវាយពួកវា និងដោយសារថា ប្រជាជនអាមេរិក និងសភាអាមេរិកប្រឆាំងការផ្តល់ជំនួយទៅពួកបនក្បត់ជាតិនេះ។

នៅខែនេះ ពួកក្បត់ជាតិ លន់ នល់, សេរី មតៈ, សឹង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វែរណង់ដេស ដែលបានទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ មិនអាចងើបឡើងវិញបានទេ គឺមិនអាចសង្គ្រោះស្ថានការណ៍បានដាច់ខាត។ ខាងយោធា ពួកក្បត់ជាតិកំពុងខ្វះកម្លាំង ទីតាំង សម្ភារៈ រថគ្រោះ កប៉ាល់

យន្តហោះ គ្រាប់សព្វាវុធ អាវុធធន់ស្រាល ធន់ធ្ងន់ និងមេបញ្ជាការ។ កងទ័ពរបស់ពួកវាកំពុងដួលរលំជាបណ្ដើរៗពីមួយកន្លែងទៅមួយកន្លែង។

ខាងនយោបាយ មហាជន កម្មករ ព្រះសង្ឃ ទាហាន នគរបាល អ្នកបម្រើការងារ គ្រួសាររបស់ទាហាន យុវជន សិស្សនិស្សិត បញ្ញាវន្ត និងឥស្សរជនមកពីគ្រប់មជ្ឈដ្ឋាននៅភ្នំពេញ និងទីរួមខេត្តមួយចំនួនតូចដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្ដោះអាសន្នរបស់ខ្មាំង បានច្រានចោលពួកក្បត់ជាតិនេះ ហើយក្រោកឡើងជាបន្តបន្ទាប់ប្រឆាំងនឹងពួកវា។ ប្រជាជនអាមេរិក និងសភាអាមេរិក ព្រមទាំងប្រជាជនផ្សេងទៀតនៅទូទាំងពិភពលោក ក៏បានប្រកាសថ្កោលទោស ធ្វើការថ្កោលទោស និងច្រានចោលពួកវាដែរ។ បុគ្គលិកស្ថានទូត និងកុងស៊ុលបរទេសដែលបានបង្ហាញសារតាំងទៅសាធារណរដ្ឋក្បត់ជាតិនេះ ព្រមទាំងពលរដ្ឋបរទេស និងអ្នកឆ្លើយឆ្លងព័ត៌មាននៅភ្នំពេញ បានបោះបង់ចោលពួកវាហើយ ឬក៏ឥឡូវនេះ កំពុងតែបោះបង់ចោលពួកវាហើយ ទុកឲ្យពួកវានៅឯកាតែឯងទាំងស្រុងដើម្បីរងទុក្ខជោគវាសនារបស់ពួកវា។ គ្មាននរណាអាចសង្គ្រោះពួកវាបានឡើយ។

អ្នកបម្រើការងារនៅក្នុងឋានៈ និងវិស័យផ្សេងៗ ទាហាន និងនគរបាលនៅក្នុងឋានៈ និងក្រុមផ្សេងៗ៖

មិត្ត យុវជន សិស្សនិស្សិត និងបញ្ញាវន្ត ជាទីរាប់អាន!

ទិន្នាការស្ថានការណ៍របស់ពួកក្បត់ជាតិទាំង ៧ នាក់ដូចបានលើកឡើងខាងលើ ត្រូវបានយកមកពិភាក្សាយ៉ាងលម្អិតនៅក្នុងមហាសន្និបាតជាតិលើកទីពីរ របស់ប្រទេសកម្ពុជា ដែលបានធ្វើឡើងនៅថ្ងៃទី២៤ និង ២៥ ខែ កុម្ភៈ។ ពួកក្បត់ជាតិទាំង ៧ នាក់នេះ ចៀសមិនរួចឡើយនឹងត្រូវបរាជ័យ ហើយប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា ប្រាកដជាទទួលបានជ័យជម្នះជាមិនខាន។

ដោយគិតពីស្ថានការណ៍បែបនេះ មហាសន្និបាតជាតិលើកទីពីរ បានប្រកាសថា៖ លន់ នល់, សេរី មតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វែរណង់ដេស គឺជាមេខ្លោងជនក្បត់ជាតិ និងអ្នកបំផុសរដ្ឋប្រហារដែលបានបញ្ចប់ឯករាជ្យភាព សន្តិភាព និងអព្យាក្រឹត្យភាពរបស់កម្ពុជា។ ពួកគេបាននាំមកនូវការឈ្លានពានរបស់ចក្រពត្តិអាមេរិក ដែលបានដាក់កម្ពុជាឲ្យចូលក្នុងភ្លើង និងកាប់ចាក់គ្នា។ វត្តមានរបស់ជនក្បត់ជាតិហ្វាសស៊ីស របបនេះត្រូវតែបញ្ចប់ទោះត្រូវចំណាយអស់អ្វីក៏ដោយ ពីព្រោះថាពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃមិនធ្លាប់មានពីមុនមកនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។

ចំពោះអ្នកបម្រើការងារក្នុងឋានៈ និងវិស័យផ្សេងៗ មន្ត្រី និងទាហាន មន្ត្រីនគរបាល និងភ្នាក់ងារនគរបាលគ្រប់ប្រភេទទាំងអស់ អ្នកនយោបាយ និងឥស្សរជនផ្សេងទៀត ព្រមទាំងសមាជិកនៅអង្គការផ្សេងៗនៃរបបជនក្បត់ជាតិនេះ មហាសន្និបាតជាតិបានប្រកាសថា ពួកគាត់ទាំងអស់នេះអាចចូលរួមជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជា ប្រទេសជាតិ និងប្រជាជនកម្ពុជា ដោយមិនគិតពីអតីតកាលរបស់ពួកគាត់ឡើយដរាបណា ពួកគាត់បញ្ឈប់សកម្មភាពដែលអាចបម្រើពួកក្បត់ជាតិទាំង ៧ នាក់នេះ។

មន្ត្រីបម្រើការងារនៅក្នុងឋានៈ និងវិស័យផ្សេងៗ ទាហាន និងភ្នាក់ងារនគរបាលក្នុងឋានៈ និងក្រុមផ្សេងៗ៖

[00166887]

**មិត្ត យុវជន សិស្សនិស្សិត និងបញ្ញាវន្ត ជាទីរាប់អាន!**

ពេលវេលាបានមកដល់ហើយ។ នេះគឺជាឱកាសដ៏ល្អអស្ចារ្យសម្រាប់យើងដើម្បីប្រមូលផ្តុំកម្លាំងរបស់យើងរួមមានការរួបរួមគ្នាជាមួយប្រទេសជាតិទាំងមូល និងប្រជាជនទាំងអស់ ដោយមិនគិតពីវណ្ណៈ និន្នាការនយោបាយ ជំនឿសាសនា ឬអតីតកាលឡើយ ដើម្បីផ្តួលរំលំរបបយោធានិយម ផ្តាច់ការ និងហ្វាស៊ីស ហើយបញ្ចប់វត្តមានរបស់ពួកក្បត់ជាតិទាំង ៧ នាក់ដែលប្រឆាំងជាតិស្ងួពូជ រល្បួយស្ងួពូជ ជាបរិវារសំខាន់របស់ចក្រពត្តិអាមេរិក ហើយក្នុងពេលដំណាលគ្នានេះដែរ គឺដើម្បីបញ្ចប់សង្គ្រាមឈ្លានពានរបស់ចក្រពត្តិ

អាមេរិកនៅក្នុងប្រទេសកម្ពុជា ដូច្នេះនឹងបញ្ចប់មហាវិនាសកម្ម និងការឈឺចាប់របស់ប្រទេសជាតិយើង និងប្រជាជនយើង នៅក្រោមកណ្តាប់ដៃរបស់ពួកក្បត់ជាតិទាំង ៧ នាក់នេះ។

នៅក្នុងស្ថានការណ៍សំខាន់យ៉ាងខ្លាំងនេះ តាងនាមឲ្យរណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ខ្ញុំសូមធ្វើការអំពាវនាវទៅជនរួមជាតិទាំងអស់នៅភ្នំពេញ និងទីរួមខេត្តមួយចំនួនតូចដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំង។

១. ធ្វើការបះបោរកាន់តែខ្លាំងក្លាប្រឆាំងនឹងពួកក្បត់ជាតិទាំង ៧ នាក់នេះ ព្យាយាមគ្រប់មធ្យោបាយដើម្បីកម្ចាត់ពួកវា និងអង្គការប្រឆាំងជាតិរបស់ពួកវា ដោយដើរតាមគំរូដ៏ល្អនៃស្មារតីស្នេហាជាតិដ៏ឧត្តមរបស់ប្រជាជន និងយុវជននៅបាត់ដំបង ក្រុងព្រះសីហនុ សៀមរាប ភ្នំពេញ និងក្រុងផ្សេងទៀត ដែលបានក្រោកឡើងប្រឆាំងនឹងពួកក្បត់ជាតិនេះ៖ ដើរតាមគំរូដ៏ល្អនៃស្មារតីស្នេហាជាតិដ៏ឧត្តមរបស់ទាហាននៅលើកោះពាមរាំង នៅគួយជីកដី នៅអង្គ្រង និងនៅដូនទ្រី ដែលបានទម្លាក់អាវុធ ហើយចុះចាញ់ជាមួយប្រជាជនយើង និងកងទ័ពរំដោះជាតិប្រជាជាកម្ពុជា ទាន់ពេលវេលា ហើយចុងក្រោយបង្អស់ ដើរតាមគំរូនៃស្មារតីស្នេហាជាតិដ៏ឧត្តមរបស់ទាហាន នគរបាល និងមន្ត្រីបម្រើការងារជាច្រើននាក់ដែលបានរត់ចោលសមរភូមិបោះបង់ទីតាំង និងជំរុំរបស់ខ្លួន ហើយមិនព្រមទៅជួរមុខ មិនព្រមការពារពួកក្បត់ជាតិ មិនព្រមធ្វើជាអ្នកការពារស្វ័យត្រាណ ឬបម្រើពួកក្បត់ជាតិឡើយ។

២. ក្រោកឡើងរួបរួមជាមួយព្រះសង្ឃ អ្នកប្រតិបត្តិសាសនា កម្មករ និងពលករផ្សេងៗទៀត ដោយប្រើប្រាស់ការតស៊ូគ្រប់រូបភាពដើម្បីផ្តួលរំលំពួកក្បត់ជាតិ និងរបបរបស់ពួកវា។ ចាប់ផ្តើមរៀបចំអង្គប្រជុំសន្និបាត ការប្រមូលផ្តុំគ្នា បាតុកម្ម និងកូដកម្មប្រឆាំងនឹងអំពើហ្វាស៊ីសគ្រប់ប្រភេទ ប្រឆាំងនឹងការកេណ្ឌទ័ពដោយបង្ខំ ប្រឆាំងនឹងការខ្វះអង្ករ ហើយបំផ្លាញឃ្លាំងអង្ករ និងស្បៀងផ្សេងទៀត ព្រមទាំងធ្វើការបះបោរដោយប្រើប្រាស់អាវុធគ្រប់ប្រភេទដើម្បីកម្ចាត់ពួកក្បត់ជាតិទាំង ៧ នាក់ ទោះត្រូវចំណាយអស់អ្វីក៏

ដោយ ហើយសម្រេចស្នាដៃស្នេហាជាតិលក្ខណៈជាប្រដាប់អាវុធ។ យើងនឹងទទួលបានការកោតសរសើរ ការអបអរសាទរ និងរង្វាន់ជាទីគាប់ចិត្តពីប្រទេសជាតិ ប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

៣. ប្រសិនបើចាំបាច់ ត្រូវឆ្លងទៅតំបន់រំដោះ កុំស្ទាក់ស្ទើរ ឬបារម្ភអំពីការរកចំណូលនៅក្នុងតំបន់រំដោះ។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងគណៈកម្មាធិការគ្រប់ជាន់ថ្នាក់នៃរណសិរ្សរួបរួមជាតិកម្ពុជា នឹងស្វាគមន៍យ៉ាងកក់ក្តៅ ហើយផ្តល់ជូននូវសម្ភារៈ និងការគាំទ្រទឹកចិត្តដោយអស់ពីចិត្ត ព្រមទាំងជួយបង្កើតជីវិតថ្មីនៅក្នុងតំបន់រំដោះ។ បន្ថែមពីលើនេះទៀត ជនរួមជាតិនឹងទទួលបានអំណោចផលគ្រប់យ៉ាងណាដើម្បីបន្តការតស៊ូ ដោយសម្របសម្រួលជាមួយនឹងប្រជាជនយើងទាំងអស់។

ជនោ កម្លាំងរួបរួមជាតិទាំងមូល និងប្រជាជនកម្ពុជាទាំងអស់នៅក្នុងការតស៊ូផ្តួលរំលំពួកក្បត់ជាតិទាំង ៧ នាក់ គឺលន់ នល់, សេរី មតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ,ឡុង បូរ៉េត និង ស្វស្តែន ហ្វៃរណង់ដេស!

ភ្នំពេញ នឹងត្រូវរំដោះជាមិនខាន!

ប្រទេសកម្ពុជាទាំងអស់ ប្រាកដជារំដោះបានទាំងស្រុងជានិរន្តរ៍!

ប្រទេសកម្ពុជាដែលមានមុខមាត់ថ្មី ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ អធិបតេយ្យ ប្រជាធិបតេយ្យ មិនចូលបក្សសម្ព័ន្ធ និងសម្បូររុងរឿងមានបូរណភាពទឹកដីពិតប្រាកដ នឹងត្រូវកសាងឡើងជាមិនខាននៅលើទឹកដីអង្គរដ៏ពិសិដ្ឋរុងរឿងរបស់ប្រទេសកម្ពុជា។